ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# ផែនទីបង្ហាញទិសរបស់សម្ព័ន្ធកសិកម្មអភិរក្ស និងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា (ភាស៊ីក) ២០២២ – ២០២៦

*ឆ្ពោះទៅរកទំនើបកម្មនិងកសិកម្មអេកូឡូស៊ីនៅកម្ពុជា*



*រៀបចំដោយគណៈកម្មការប្រតិបត្តិនិងក្រោមការដឹកនាំរបស់គណៈកម្មការតម្រង់ទិសនៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា*

*រាជធានីភ្នំពេញ, ខែសីហា ឆ្នាំ២០២១*

# មាតិកា


| | |
|---|---|
| បញ្ជីតារាង | iii |
| បញ្ជីរូប | iii |
| បញ្ជីពាក្យកាត់ | iv |
| អារម្ភកថា | vii |
| សេចក្តីថ្លែងអំណរគុណ | viii |
| សមាសភាពគណៈកម្មការរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា | x |
| **១. សេចក្តីផ្តើម** | 1 |
| ១.១ គោលបំណងនៃផែនទីតម្រង់ទិស | 2 |
| ១.២ គោលការណ៍ណែនាំ | 3 |
| ១.៣ ដំណើរការរៀបចំ | 3 |
| **២. សាវតានៃកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី** | 5 |
| ២.១ គំនិតនិងសារៈសំខាន់ នៃកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី | 5 |
| ២.២ ប្រវត្តនៃការអភិវឌ្ឍកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ីនៅកម្ពុជា | 8 |
| ២.៣ លទ្ធផលនៃការអភិវឌ្ឍកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ីនៅកម្ពុជា | 13 |
| **៣ ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍កសិកម្មប្រកបដោយនិរន្តរភាព** | 17 |
| **៤. ទម្រង់ស្ថាប័ននិងរចនាសម្ព័ន្ធរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា** | 20 |
| ៤.១ ចក្ខុវិស័យ | 21 |
| ៤.២ បេសកកម្ម | 22 |
| ៤.៣ អភិបាលកិច្ចនិងរចនាសម្ព័ន្ធប្រតិបត្តិរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា | 22 |
| **៥. ការវិភាគ SWOT នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា** | 25 |
| **៦. ផែនទីតម្រង់ទិសរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជាសម្រាប់ឆ្នាំ ២០២២-២០២៦** | 27 |
| ៦.១ គោលបំណងរួម | 27 |
| ៦.២ គោលបំណងយុទ្ធសាស្ត្រ | 27 |

៦.៣ គោលបំណងយុទ្ធសាស្ត្រទី១៖ សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព កម្ពុជា និងភាគីពាក់ព័ន្ធត្រូវបានពង្រឹងនិងសម្របសម្រួល 30
៦.៤ គោលបំណងយុទ្ធសាស្ត្រទី២៖ ចំណេះដឹងនិងការស្រាវជ្រាវលើកសិកម្មអភិរក្ស និងប្រពលវប្បកម្មនិរន្តរភាព និងកសិកម្មអេកូឡូស៊ី ត្រូវបានលើកកម្ពស់ 32
៦.៥ គោលបំណងយុទ្ធសាស្ត្រទី ៣៖ សេវាកម្មកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងកសិកម្មអេកូឡូស៊ីមានភាពប្រសើរឡើងនិងត្រូវបានពង្រីក 34
**៧. តួនាទីនិងចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធក្នុងការអនុវត្តផែនទីតម្រង់ទិស របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា** 35
៧.១ អ្នកពាក់ព័ន្ធផ្ទៃក្នុងរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា 35
៧.២ អ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត 36
**៨. យន្តការយុទ្ធសាស្ត្រសម្រាប់ការអនុវត្តផែនទីតម្រង់ទិស** 40
៨.១ លក្ខខណ្ឌអនុញ្ញាត 40
៨.២ ការកៀរគរធនធាន 41
៨.៣ ការវាយតម្លៃហានិភ័យនិងការគ្រប់គ្រង 42
៨.៤ ការរួមបញ្ចូលរបស់កសិករខ្នាតតូចនិងស្ត្រី 44
**៩ .ការត្រួតពិនិត្យនិងការវាយតម្លៃ** 45
**ឯកសារយោង** 47
**ឧបសម្ព័ន្ធទី១** សេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតគណៈកម្មការតម្រង់ទិសនិងគណៈកម្មការប្រតិបត្តិសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា 50
**ឧបសម្ព័ន្ធទី២** ម៉ាទ្រីសផែនទីតម្រង់ផ្លូវរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព កម្ពុជា (២០២២-២០២៦) 53
**ឧបសម្ព័ន្ធទី៣** ការប៉ាន់ស្មានថវិកាផែនទីតម្រង់ទិសរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា (២០២២-២០២៦) 63
**ឧបសម្ព័ន្ធទី៤** បញ្ជីអ្នកផ្តល់ព័ត៌មានសំខាន់ៗ ដែលបានពិគ្រោះយោបល់ 72

## បញ្ជីតារាង

**តារាងទី១** សង្ខេបវិធីសាស្ត្រកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី 7
**តារាងទី២** ភស្តុតាងនៃឥទ្ធិពលសេដ្ឋកិច្ច កសិកម្ម និង បរិស្ថាននៃការអនុវត្តកសិកម្មអភិរក្ស 15
**តារាងទី៣** ការវិភាគ SWOT របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា 25
**តារាងទី៤** សកម្មភាពអាទិភាពនៅក្រោមគោលបំណងយុទ្ធសាស្ត្រទី១ 30
**តារាងទី៥** សកម្មភាពអាទិភាពក្រោមគោលបំណងយុទ្ធសាស្ត្រ ២ 32
**តារាងទី៦** សកម្មភាពអាទិភាពក្រោមគោលបំណងយុទ្ធសាស្ត្រ ៣ 34
**តារាងទី៧** ការសន្មត់ហានិភ័យនិងយុទ្ធសាស្ត្រកាត់បន្ថយ 43

## បញ្ជីរូប

***រូបទី១*** តារាងពេលវេលានៃការអភិវឌ្ឍកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅកម្ពុជា 8
***រូបទី២*** រចនាសម្ព័ន្ធរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា 23
***រូបទី៣*** គោលបំណងនិងលទ្ធផលរំពឹងទុកនៃផែនទីតម្រង់ទិសរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជាសម្រាប់ឆ្នាំ ២០២២-២០២៦ 29

## បញ្ជីពាក្យកាត់

| | |
|---|---|
| ACIAR | មជ្ឈមណ្ឌលអូស្ត្រាលីដើម្បីការស្រាវជ្រាវកសិកម្មអន្តរជាតិ |
| ACTAE | ដំណើរឆ្ពោះទៅរកការផ្លាស់ប្តូរកសិកម្មអេកូឡូស៊ីអន្តរកាលនៅអាស៊ីអាគ្នេយ៍ |
| AFD | ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ |
| AIMS | គម្រោងជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច |
| ALiSEA | បណ្តាញសិក្សាកសិកម្មអេកូឡូស៊ីនៅតំបន់អាស៊ីអាគ្នេយ៍ |
| ASEA | កសិកម្មអេកូឡូស៊ីនៅអាស៊ីអាគ្នេយ៍ (ឈ្មោះចាស់គឺ CANSEA) |
| ASMC | គម្រោងសម្ព័ន្ធគ្រឿងយន្តកសិកម្មសមស្របសម្រាប់ប្រពលវប្បកម្មប្រកបដោយនិរន្តរភាព |
| ASPIRE | កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មី ដែលធន់ទៅនឹងការប្រែប្រួលអាកាសធាតុ |
| ASSET | គម្រោងផ្លាស់ប្តូរប្រព័ន្ធសុវត្ថិភាពស្បៀងអាហារនិងកសិកម្មអេកូឡូស៊ី |
| CA | កសិកម្មអភិរក្ស |
| CARD | ក្រុមប្រឹក្សាស្តារអភិវឌ្ឍវិស័យកសិកម្មនិងជនបទ |
| CARDI | វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា |
| CASC | មជ្ឈមណ្ឌលសេវាកម្មកសិកម្មអភិរក្ស (DALRM/GDA/MAFF) |
| CASF | គម្រោងការផ្តល់សេវាបច្ចេកទេសកសិកម្មអភិរក្សដោយមានការបង់ថ្លៃសេវាកម្ម |
| CASIC | សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា |
| CAVAC | កម្មវិធីខ្សែសង្វាក់តម្លៃកសិកម្មកម្ពុជា-អូស្ត្រាលី |
| CCC | សភាពាណិជ្ជកម្មកម្ពុជា |
| CCCA | កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា |
| CCCSP | ផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ |
| CE SAIN | មជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាពនិងអាហារូបត្ថម្ភ |
| CHAIN | គម្រោងសាកវប្បកម្មកម្ពុជា ដើម្បីបង្កើនប្រាក់ចំណូលនិងអាហារូបត្ថម្ភ |
| CHIP | វេទិកាវិនិយោគសាកវប្បកម្មនៅកម្ពុជា |
| CICT | វិទ្យាស្ថានចិនសម្រាប់ការអភិរក្សការភ្ជួររាស់ដី |
| CIMMYT | មជ្ឈមណ្ឌលវឌ្ឍនភាពពោតនិងស្រូវសាលីអន្តរជាតិ |
| CIRAD | មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ |
| CPSA | អង្គការភាពជាដៃគូរដើម្បីចីរភាពកសិកម្មកម្ពុជា |
| CSAM | មជ្ឈមណ្ឌលគ្រឿងយន្តកសិកម្មសមស្រប នៃអង្គការសហប្រជាជាតិ (UN ESCAP) |
| DALRM | នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម |
| ECAF | សហព័ន្ធកសិកម្មអភិរក្សអឺរ៉ុប |

| | |
|---|---|
| EISOFUN | គម្រោងប្រព្រលវប្បកម្មអេកូឡូស៊ីនិងសេវាកម្មនៃប្រព័ន្ធអេកូឡូស៊ីដី |
| ERECON | វិទ្យាស្ថានស្តារនីតិសម្បទានិងអភិរក្សបរិស្ថាននៃសាកលវិទ្យាល័យកសិកម្មនៃក្រុងតូក្យូ |
| ESCAP | គណៈកម្មាធិការអង្គការសហប្រជាជាតិផ្នែកសេដ្ឋកិច្ច សង្គម ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក |
| EU | សហភាពអឺរ៉ុប |
| FA | រដ្ឋបាលព្រៃឈើ |
| GDA | អគ្គនាយកដ្ឋានកសិកម្ម |
| GDAHP | អគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ |
| GEF | មូលនិធិបរិស្ថានពិភពលោក |
| GHG | ឧស្ម័នផ្ទះកញ្ចក់ |
| GIZ | អង្គការកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ |
| GRA | សម្ព័ន្ធស្រាវជ្រាវសកល |
| GRET | ក្រុមសម្រាប់ផ្លាស់ប្តូរការស្រាវជ្រាវនិងបច្ចេកវិទ្យា |
| ICERD | សន្និសីទអន្តរជាតិស្តីអំពីបរិស្ថាននិងការអភិវឌ្ឍជនបទ |
| IPM | វិធានការចម្រុះគ្រប់គ្រងដំណាំ |
| ISA | នវានុវត្តសម្រាប់វិស័យកសិកម្មប្រកបដោយនិរន្តរភាព (គម្រោង) |
| ITC | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| KCNIA | វិទ្យាស្ថានជាតិកសិកម្មកំពង់ចាម |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MIGIP | កម្មវិធីកំណើនដោយបរិយាប័ន្ននិងនវានុវត្តន៍នៃតំបន់មេគង្គ |
| MoE | ក្រសួងបរិស្ថាន |
| MoEYS | ក្រសួងអប់រំ យុវជន និងកីឡា |
| MoI | ក្រសួងមហាផ្ទៃ |
| MoWA | ក្រសួងកិច្ចការនារី |
| MoWRAM | ក្រសួងធនធានទឹកនិងឧតុនិយម |
| NAP | កម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងការរិចរិលដីធ្លី |
| NBSAP | ផែនការសកម្មភាពនិងយុទ្ធសាស្រ្តជីវៈចម្រុះជាតិ |
| NCARD | សន្និសីទថ្នាក់ជាតិស្តីពីការអភិវឌ្ឍកសិកម្មនិងជនបទ |
| NCSD | ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព |
| NDC | របាយការណ៍ចូលរួមចំណែករបស់កម្ពុជា |

| | |
|---|---|
| NC A&T | សាកលវិទ្យាល័យបច្ចេកវិទ្យានិងកសិកម្មរដ្ឋការ៉ូលីណាខាងជើង |
| NUBB | សាកលវិទ្យាល័យជាតិបាត់ដំបង |
| PADAC | គម្រោងកែលម្អកសិកម្មកម្ពុជា |
| PDAFF | មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត |
| PLNIA | វិទ្យាស្ថានជាតិកសិកម្មព្រែកលៀប |
| PAMPA | កម្មវិធីសកម្មភាពកសិអេកូឡូស៊ីពហុប្រទេស |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RUA | សាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| S3 | គម្រោងជំរុញបច្ចេកទេសកសិកម្មសមស្របឲ្យមាននិរន្តរភាព |
| SANREM-CSRP | កម្មវិធីគ្រប់គ្រងកសិកម្មនិងធម្មជាតិប្រកបដោយនិរន្តរភាព សហការគាំទ្រការស្រាវជ្រាវ |
| SDC | ទីភ្នាក់ងារស្វីស សម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ |
| SI | ប្រពលវប្បកម្មនិរន្តរភាព |
| SIIL | មន្ទីរពិសោធន៍នវានុវត្តន៍ប្រកបដោយនិរន្តរភាព |
| SRU | សាកលវិទ្យាល័យស្វាយរៀង |
| UHST | សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ |
| UN | អង្គការសហប្រជាជាតិ |
| UNCBD | អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីជីវចម្រុះ |
| UNCCD | អនុសញ្ញារបស់អង្គការសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែ ក្លាយជាវាលរហោឋាន |
| UNFCCC | អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ |
| USAID | ទីភ្នាក់ងារជំនួយអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ |
| WAgN | គម្រោងស្ត្រីក្នុងបណ្តាញកសិកម្ម |
| WAT4CAM | ការគ្រប់គ្រងធនធានទឹកនិងដំណើការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីនៅកម្ពុជា |

## អារម្ភកថា

កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងកសិកម្មអេកូឡូស៊ី បានបង្ហាញនូវមាគ៌ាថ្មីមួយសម្រាប់ផលិតកម្មកសិកម្មនិងការគ្រប់គ្រងដីធ្លីប្រកបដោយនិរន្តរភាព ខណៈកំពុងមានកិច្ចការពារនូវជីវចម្រុះនិងការប្រមូលកាបូនសរីរាង្គក្នុងដី។ កសិកម្មអភិរក្ស បង្ហាញពីការអនុវត្តប្រកបដោយភាពច្នៃប្រឌិតនៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម ដែលនាំឱ្យជីវភាពរស់នៅកាន់តែប្រសើរឡើងនិងសមត្ថភាពកាន់តែច្រើនរបស់កសិករនិងសហគមន៍ក្នុងការទ្រាំទ្រនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនិងវិបត្តិសេដ្ឋកិច្ច។ គោលដៅចម្បងរបស់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព គឺការប្រើប្រាស់ធនធានធម្មជាតិនិងធនធានមនុស្សឱ្យកាន់តែប្រសើរឡើង ដូចជាដី ទឹក ជីវៈចម្រុះ ចំណេះដឹង និងបច្ចេកវិទ្យា។ ដូចនេះ ការធ្វើកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព គឺជាការបង្កើនភាពធន់នៃប្រព័ន្ធផលិតកម្មនិងពង្រឹងសមត្ថភាពកសិករ ដើម្បីទប់ទល់នឹងវិបត្តិសេដ្ឋកិច្ច អាកាសធាតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

ផែនទីតម្រង់ទិសរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងនិរន្តរភាពប្រពលវប្បកម្មកម្ពុជា ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃក្របខ័ណ្ឌច្បាប់ និងដោយការវិភាគយ៉ាងត្រឹមត្រូវលើចំណុចខ្លាំងនិងចំណុចខ្សោយ កាលានុវត្តភាព ការគំរាមកំហែង និងបញ្ហាប្រឈមនានា ដែលមានក្នុងការអនុវត្តកសិកម្មអភិរក្សនិងនិរន្តរភាពប្រពលវប្បកម្មនៅកម្ពុជាចាប់តាំងពីឆ្នាំ២០០៤។ មេរៀននិងបទពិសោធន៍ពីប្រទេសផ្សេងៗនិងកិច្ចប្រជុំជាច្រើនជាមួយភាគីពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ត្រូវបានដាក់បញ្ចូលនៅពេលរៀបចំឯកសារនេះ។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងស្មោះចំពោះគណៈកម្មការតម្រង់ទិសនិងគណៈកម្មការប្រតិបត្តិ នៃសម្ព័ន្ធកសិកម្មអភិរក្សនិងនិរន្តរភាពប្រពលវប្បកម្មកម្ពុជានិងដៃគូអភិវឌ្ឍន៍នានា ដែលបានរៀបចំផែនទីតម្រង់ទិស ជាពិសេសទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ទីភ្នាក់ងារសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការស្វីស (SDC) សម្រាប់ផ្តល់ការគាំទ្រ។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរដល់មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD) អង្គការស្វីសខនថាក់ (Swisscontact) និងមជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាពនិងអាហារូបត្ថម្ភ (CE-SAIN) នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដែលបានចូលរួមសហការយ៉ាងសកម្ម ក្នុងការបង្កើតសម្ព័ន្ធកសិកម្មអភិរក្សនិងនិរន្តរភាពប្រពលវប្បកម្មកម្ពុជានិងផែនទីតម្រង់ទិសរយៈពេល៥ឆ្នាំ របស់សម្ព័ន្ធកសិកម្មអភិរក្សនិងនិរន្តរភាពប្រពលវប្បកម្មកម្ពុជា។ ផែនទីតម្រង់ទិសនឹងគាំទ្រក្នុងការលើកកម្ពស់កសិកម្មអភិរក្សនិងនិរន្តរភាពប្រពលវប្បកម្ម និងការផ្លាស់ប្តូរទៅកសិកម្មអេកូឡូស៊ីនៅកម្ពុជា។ ផែនទីតម្រង់ទិសនេះ ក៏មានគោលបំណងឱ្យប្រទេសកម្ពុជាក្លាយជា " ម៉ូដែលសម្រាប់ការ ផ្លាស់ប្តូរ" នៅអាស៊ីអាគ្នេយ៍ផងដែរ។

ខ្ញុំសូមស្នើដល់អង្គភាពពាក់ព័ន្ធនិងដៃគូអភិវឌ្ឍន៍ សូមចូលរួមនិងសហការក្នុងការអនុវត្តផែនទីតម្រង់ទិសនេះ ព្រមទាំងអំពាវនាវដល់សហគមន៍អន្តរជាតិ សូមផ្តល់ការគាំទ្របន្ថែមទៀតទាំងជំនួយហិរញ្ញវត្ថុនិងបច្ចេកទេសសម្រាប់ការអនុវត្តប្រកបដោយជោគជ័យនិងប្រសិទ្ធភាព នៃផែនទីតម្រង់ទិសរយៈពេល៥ឆ្នាំរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងនិរន្តរភាពប្រពលវប្បកម្មកម្ពុជា។

ថ្ងៃ [illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែសីហា ឆ្នាំ២០២១

**វេង សាខុន**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

## សេចក្តីថ្លែងអំណរគុណ


ផែនទីតម្រង់ទិសរយៈពេល៥ឆ្នាំរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ត្រូវបានរៀបរៀងឡើងក្រោមការដឹកនាំរបស់គណៈកម្មការតម្រង់ទិសនិងការសម្របសម្រួលរបស់គណៈកម្មការប្រតិបត្តិ នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា (ដូចដែលមានបញ្ជាក់សមាសភាពនៅក្នុងតារាងខាងក្រោម) ក្រោមការផ្តត់ផ្គង់ហិរញ្ញវត្ថុពីអង្គការស្វីសខនថាក់ (Swiss-contact) ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងមជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាពនិងអាហារូបត្ថម្ភ (CE-SAIN)។ ដំណើរការនៃការរៀបចំឡើង ត្រូវបានសម្របសម្រួលដោយក្រុមអ្នកប្រឹក្សានៃក្រុមហ៊ុន BD trus។

ជាដំបូងនិងជាសំខាន់បំផុត សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា សូមសម្តែងអំណរគុណដ៏ជ្រាលជ្រៅជូនចំពោះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលបានអនុញ្ញាតយល់ព្រមបង្កើតឱ្យមានសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ព្រមទាំងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការគាំទ្រនូវការជំរុញកសិកម្មអភិរក្ស និងប្រពលវប្បកម្មនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា។ កត្តានេះបាននាំមកនូវព្រឹត្តិការណ៍ដ៏សំខាន់នៅក្នុងប្រវត្តិសាស្ត្រដ៏យូរអង្វែងនៃការអភិវឌ្ឍកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព។

ទីពីរផែនទីផែនទីតម្រង់ទិសនេះ ទទួលផលយ៉ាងច្រើនពីការចូលរួមនិងអ្នកជំនាញបច្ចេកទេសរបស់សមាជិកនៃគណៈកម្មការប្រតិបត្តិទាំងអស់និងអនុគណៈកម្មការទាំង៤ នៅក្នុងការរៀបចំក្របខណ្ឌផែនទីបង្ហាញផ្លូវនិងវិស័យអាទិភាពសំខាន់ៗផ្សេងងទៀត។ ការរួមចំណែកផ្តួចផ្តើមនាជំណាក់កាលដំបូង ក៏ត្រូវបានទទួលពីក្រុមអ្នកជំនាញផ្នែកកសិកម្មអេកូឡូស៊ីក្នុងតំបន់និងអន្តរជាតិ ដែលក្នុងនោះមានការិយាល័យប្រចាំតំបន់ នៃមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD) ក្រុមសម្រាប់ផ្លាស់ប្តូរការស្រាវជ្រាវនិងបច្ចេកវិទ្យា (GRET) និងអង្គការស្បៀងនិងកសិកម្មនៃ អង្គការសហប្រជាជាតិ (FAO) រួមទាំងសកលវិទ្យាល័យ Kansas State university អង្គការសម្ព័ន្ធស្រាវជ្រាវសកល (GRA) និងមជ្ឈមណ្ឌលគ្រឿងយន្តកសិកម្មសមស្រប នៃអង្គការសហប្រជាជាតិ (CSAM)។ ដោយមានមូលដ្ឋានទាំងនេះហើយ ទើបសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា អាចបង្ហាញពីសក្តានុពលសាជីវកម្មនិងអាទិភាពរបស់ខ្លួនទៅកាន់ភាគីពាក់ព័ន្ធកាន់តែច្រើននិងសម្រាប់វិសាលភាពការប្រឹក្សាកាន់តែទូលំទូលាយ។

ទីបី សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា សូមថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍ដែលមានដូចជា ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការ(SDC) និងទីភ្នាក់ងារជំនួយអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID)

ដែលបានគាំទ្រយ៉ាងសកម្មនូវគំនិតផ្តួចផ្តើមនិងការអន្តរាគមន៍ចំពោះកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅប្រទេសកម្ពុជា ព្រមទាំងផ្តល់នូវការចូលរួមនិងសេចក្តីណែនាំប្រកបដោយយុទ្ធសាស្ត្រមកដល់ឯកសារផែនទីតម្រង់ទិសនេះ។ ក្រៅពីនេះ ដៃគូអភិវឌ្ឍន៍សំខាន់ៗមួយចំនួនទៀតដែលបានគាំទ្រវិស័យកសិកម្មនិងការអភិវឌ្ឍប្រកបដោយនិរន្តរភាពយ៉ាងសកម្ម ដែលមានដូចជាធនាគារអភិវឌ្ឍន៍អាស៊ី (ADB) អង្គការស្បៀងនិងកសិកម្មនៃសហប្រជាជាតិប្រចាំប្រទេសកម្ពុជា (FAO) សហភាពអឺរ៉ុប (EU) និងអង្គការកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ក៏ត្រូវបានសារទរយ៉ាងខ្លាំងចំពោះការចូលរួមដ៏មានតម្លៃរបស់ពួកគេ។

ជាចុងក្រោយ សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ក៏សូមថ្លែងអំណរគុណចំពោះការចូលរួមពីភាគីពាក់ព័ន្ធក្នុងវិស័យឯកជនមួយចំនួននៅក្នុងសិក្ខាសាលាពិគ្រោះយោបល់និងកិច្ចពិគ្រោះយោបល់ទ្វេរភាគី ដែលមានដូចជាសហព័ន្ធស្រូវអង្ករកម្ពុជា (CRF) សមាគមធនាគារនៅកម្ពុជា (ABC) សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) អ្នកផ្គត់ផ្គង់ម៉ាស៊ីនកសិកម្មនិងគ្រាប់ដំណាំគម្របដី គ្រឹះស្ថានហិរញ្ញវត្ថុ និងពាណិជ្ជករ នៃផលិតផលកសិកម្មប្រកបដោយសុវត្ថិភាព។ ការចូលរួមនិងមតិរបស់ភាគីពាក់ព័ន្ធ គឺពិតជាសំខាន់ណាស់នៅក្នុងការពង្រឹងការចូលរួមរបស់វិស័យឯកជននៅក្នុងការអភិវឌ្ឍកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព។

**សមាសភាពគណៈកម្មការតម្រង់ទិសរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា**

| ល.រ | នាម និង គោត្តនាម | តួនាទី និង ស្ថាប័ន | តំណែង |
|---|---|---|---|
| ១ | ឯកឧត្តម ឱម គឹមស៊ា | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ប្រធាន |
| ២ | លោកជំទាវ យ៉ើ អាស៊ីគីន | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣ | ឯកឧត្តម សួន តារា | អគ្គនាយករងនៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៤ | លោក អ៊ុក ណារ៉ាន់ | អគ្គនាយករងនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាននៃក្រសួងបរិស្ថាន | សមាជិក |
| ៥ | លោក ស៊ុំ វណ្ណសាន | អគ្គាធិការរងនៃអគ្គាធិការដ្ឋាន នៃក្រសួងកិច្ចការនារី | សមាជិក |
| ៦ | លោក យិន សារុធ | ប្រធាននាយកដ្ឋាននៃការងារធារាសាស្រ្តនិងទន្លេ នៃក្រសួងធនធានទឹកនិងឧត្តុនិយម | សមាជិក |
| ៧ | លោកស្រី សុខ សុទ្ធារី | ប្រធានរដ្ឋបាលនៃសភាពាណិជ្ជកម្មកម្ពុជា | សមាជិក |

**សមាសភាពគណៈកម្មការប្រតិបត្តិរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា**

| ល.រ | នាម និង គោត្តនាម | តួនាទី និង ស្ថាប័ន | តំណែង |
|---|---|---|---|
| ១ | ឯកឧត្តម ចាន់ សារុទ្ធ | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២ | ឯកឧត្តម ង៉ោ ប៊ុនថាន | សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម | អនុប្រធាន |
| ៣ | លោក ហូ ពុទ្ធា | អគ្គនាយករង នៃអគ្គនាយកដ្ឋានកសិកម្ម | អនុប្រធាន |
| ៤ | លោក សេង វ៉ាង | ប្រធាននាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម | សមាជិក |
| ៥ | លោក ជិន កុសល | ប្រធាននាយកដ្ឋានវិស្វកម្មកសិកម្ម | សមាជិក |
| ៦ | លោក ឡោ លីតួ | ព្រឹទ្ធបុរសមហាវិទ្យាល័យវិស្វកម្មកសិកម្ម | សមាជិក |
| ៧ | លោក ហុក លីដា | ព្រឹទ្ធបុរសរងមហាវិទ្យាល័យវិទ្យាសាស្រ្តកសិកម្ម | សមាជិក |
| ៨ | លោក ឡោ ប៊ុណ្ណា | នាយកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |
| ៩ | ល.ស្រី ហ៊ូ សុពណ៌ | អនុប្រធានន/ដផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០ | លោក Florent Tivet | អ្នកស្រាវជ្រាវសាស្រ្តប្រចាំប្រទេសកម្ពុជា នៃមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ | សមាជិក |
| ១១ | លោក Rajiv Pradhan | នាយកប្រចាំកម្ពុជា នៃអង្គការស្វីសខនថាក់ | សមាជិក |

## ១. សេចក្តីផ្តើម

វិស័យកសិកម្ម គឺជាវិស័យអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលទ្រទ្រង់កំណើនសេដ្ឋកិច្ច សន្តិសុខស្បៀងអាហារ ការអភិវឌ្ឍជនបទ និងភាពក្រីក្រនៃប្រទេសកម្ពុជា។ ការតាំងចិត្តយ៉ាងមុតមាំនៃរាជរដ្ឋាភិបាលកម្ពុជានៅក្នុងការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព ត្រូវបានឆ្លុះបញ្ចាំងយ៉ាងទូលំទូលាយនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (២០១៩ ២០២៣) បូករួមទាំងគោលនយោបាយកសិកម្មនិងគម្រោងផ្សេងៗ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងភាពមោះមុតមិនរាថយនៃប្រទេសកម្ពុជាផងដែរ នៅក្នុងការសម្រេចបាននូវគោលដៅដែលបានចែងនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs) អនុសញ្ញាអង្គការសហប្រជាជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែក្លាយជាវាលរហោឋាន (UNCCD) អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីជីវៈចម្រុះ (UNCBD) និងអនុសញ្ញាក្របខ័ណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។ លើសពីនេះទៅទៀត វិស័យកសិកម្មគឺជាវិស័យសំខាន់មួយដែលរួមចំណែកនៅក្នុងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាប្រឆាំងនឹងសំណឹកនៃដី អភិរក្សជីវៈចម្រុះជាតិ និងការកាត់បន្ថយនិងសម្របទៅនឹងបម្រែបម្រួលអាកាសធាតុ ដែលកិច្ចខិតខំប្រឹងប្រែងទាំងនេះ ក៏ត្រូវបានលើកឡើងនៅក្នុងវិធានការណ៍គោលនយោបាយពាក់ព័ន្ធមួយចំនួនផងដែរ។

ទោះជាយ៉ាងក៏ដោយ បើយោងតាមអង្គការស្បៀងអាហារនិងកសិកម្ម នៃអង្គការសហប្រជាជាតិ ផលិតកម្មស្បៀងពិភពលោកត្រូវបានគេរំពឹងទុកថានឹងកើនឡើងរហូតដល់ជិត៣០% នៅឆ្នាំ ២០៣០ និង ៥០% នៅឆ្នាំ ២០៥០ ឆ្លើយតបទៅនឹងតម្រូវការស្បៀងអាហារនាពេលអនាគត ដែលបណ្តាលមកពីកំណើនប្រជាជន កំណើនប្រាក់ចំណូលនៅតាមបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ និងការផ្លាស់ប្តូរលំនាំនៃការប្រើប្រាស់។ ដំណោះស្រាយមួយសម្រាប់ការកើនឡើងនៃផលិតកម្មស្បៀងអាហារ គឺការពង្រីកដីកសិកម្ម។ ក៏ប៉ុន្តែ ការផ្លាស់ប្តូរដែលទាក់ទងនឹងកសិកម្ម អាចបង្កនូវការសាយភាយឧស្ម័នផ្ទះកញ្ចក់ (GHG) និងការបាត់បង់ជីវៈចម្រុះ។ ការស្រាវជ្រាវ ក៏បានបង្ហាញផងដែរថា បម្រែបម្រួលអាកាសធាតុ ក៏អាចមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើការថយចុះនៃផលដំណាំនៅក្នុងរយៈពេលវែងថែមទៀតផង (FAO, 2017)។ ហេតុដូចនេះ ការបង្កើននូវប្រសិទ្ធិភាពនៃការប្រើប្រាស់ធនធានធម្មជាតិ គឺជាជំហានដ៏សំខាន់បំផុត ដើម្បីឆ្ពោះទៅកាន់ការសម្រេចបាននូវគោលដៅផលិតកម្មស្បៀងអាហារនិងបរិស្ថានប្រកបដោយនិរន្តរភាព ដែលមានន័យថា ផលិតកម្មស្បៀងអាហារនឹងត្រូវបានកើនឡើងតាមរយៈកំណើនទិន្នផល (ប្រពលវប្បកម្ម) ដោយភ្ជាប់ជាមួយនូវការការពារប្រព័ន្ធអេកូឡូស៊ី (WRI, 2018)។ ប្រការនេះ ទាមទារនូវប្រព័ន្ធនិងបច្ចេកវិទ្យាផលិតកម្មកសិកម្ម ដែលប្រកបដោយភាពច្នៃប្រឌិតនិងធន់នឹងអាកាសធាតុ ដើម្បីធានាបាននូវកំណើនផលិតភាព ព្រមទាំងឆ្លើយតបទៅនឹងការកាត់បន្ថយនិងការសម្របខ្លួនទៅនឹងបម្រែបម្រួលអាកាសធាតុ។

កសិកម្មអភិរក្ស ប្រពលវប្បកម្មនិរន្តរភាព និងកសិកម្មអេកូឡូស៊ីនាំមកនូវវិធីថ្មីមួយសម្រាប់ផលិតកម្ម កសិកម្មប្រកបដោយនិរន្តរភាព និងការរៀបចំដីធ្លី ព្រមទាំងការការពារជីវៈចម្រុះ និងការកើនឡើងនូវកាបូនសរីរាង្គនៃដី។ កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងកសិកម្មអេកូឡូស៊ី បង្កើនភាពធន់នៃប្រព័ន្ធផលិតកម្ម និងពង្រឹងសមត្ថភាពកសិករក្នុងការប្រឈមមុខនឹងបញ្ហាសេដ្ឋកិច្ចនិងវិបត្តិអាកាសធាតុ ព្រមទាំងផលប៉ះពាល់នៃបម្រែបម្រួលធាតុអាកាស។ ជាមួយនឹងលទ្ធផល ដែលបានបង្ហាញពីការស្រាវជ្រាវដែលទាក់ទងនឹងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព ដែលមានស្រាប់និងការគាំទ្រនៅលើកសិដ្ឋាននៅក្នុងប្រព័ន្ធក្សេត្របរិស្ថាន នៅក្នុងប្រទេសកម្ពុជាចាប់តាំងពីឆ្នាំ២០០៤ រាជរដ្ឋាភិបាលកម្ពុជា និងជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញនូវការតាំងចិត្តយ៉ាងមុតមាំរបស់ខ្លួន នៅក្នុងការលើកកម្ពស់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងកសិកម្មអេកូឡូស៊ី តាមរយៈការបង្កើតនូវវេទិការអន្តរក្រសួងនិងពហុភាគីមួយ ដែលមានឈ្មោះថា សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ដែលត្រូវបានទទួលការគាំទ្រតាមសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នាពាក់កណ្តាលឆ្នាំ២០២០។ គំនិតផ្តួចផ្តើមយុទ្ធសាស្ត្រនេះ គឺមានគោលបំណងសម្របសម្រួលប្រកបដោយប្រសិទ្ធភាព នូវការលើកកម្ពស់និងការអនុម័តនៃកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព នៃភាគីពាក់ព័ន្ធនៅក្នុងប្រទេសកម្ពុជា ក៏ដូចជារួមចំណែកក្នុងការសម្រេចបាននូវការតាំងចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព សន្តិសុខស្បៀងអាហារ ការប្រយុទ្ធប្រឆាំងនិងសំណឹកដី ការអភិរក្សជីវៈចម្រុះជាតិ និងការកាត់បន្ថយនិងការសម្របទៅនឹងការបម្រែបម្រួលអាកាសធាតុនៅក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (CSDGs) អនុសញ្ញារបស់អង្គការសហប្រជាជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែក្លាយជាវាលរហោឋាន (UNCCD) អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីជីវចម្រុះ (UNCBD) និងអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCC)។ ដើម្បីជាការណែនាំដល់ការសម្របសម្រួលជាអាទិភាពនៅក្នុងការអភិវឌ្ឍកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងដំណើរការប្រតិបត្តិនៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ផែនទីតម្រង់ទិសសម្រាប់ឆ្នាំ២០២២ដល់ឆ្នាំ២០២៦ ត្រូវបានផ្តួចផ្តើម និងអភិវឌ្ឍន៍ក្រោមជំនួយបច្ចេកទេសនិងថវិការបស់អង្គការស្វីសខនថាក់ និងមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD)។

## ១.១ គោលបំណងនៃផែនទីតម្រង់ទិស

គោលបំណងចម្បងនៃផែនទីតម្រង់ទិសនេះមានដូចជា៖

- ប្រែក្លាយចក្ខុវិស័យនិងបេសកកម្ម នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា អោយទៅជាគម្រោងកម្រិតខ្ពស់មួយ ដោយមានការកំណត់គោលបំណងយុទ្ធសាស្ត្រ និង

ការគូសបញ្ជាក់ពីសកម្មភាពអាទិភាព និងចំណុចដៅសំខាន់ៗដែលត្រូវសម្រេចបាននៅឆ្នាំ ២០២៦

- ទ្រទ្រង់គណៈកម្មការតម្រង់ទិស នៅក្នុងការណែនាំ ត្រួតពិនិត្យ និងតាមដាន ដំណើរការនៃការអន្តរាគមន៍ពាក់ព័ន្ធនិងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅប្រទេសកម្ពុជា
- ផ្តល់ទិសដៅយុទ្ធសាស្ត្រទៅដល់គណៈកម្មការប្រតិបត្តិ ដើម្បីគ្រោង អនុវត្តន៍ តាមដាន និងពិនិត្យសារជាថ្មីនូវសកម្មភាព ដើម្បីដោះស្រាយបញ្ហាប្រឈមសំខាន់ៗ និងអាទិភាពនៃកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព
- ដើរតួជាផែនការមេសម្របសម្រួល សម្រាប់ណែនាំសកម្មភាពកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព ដែលនឹងត្រូវអនុវត្តដោយភាគីពាក់ព័ន្ធផ្សេងៗនៅក្នុងប្រទេសកម្ពុជា
- បង្កើតតំបន់អាទិភាពសម្រាប់កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងភ្ជាប់បណ្តាញក្នុងចំណោមសមាជិក ដែលមានស្រាប់និង អ្នកពាក់ព័ន្ធ ដែលមានសក្តានុពលនៅក្នុងប្រទេសក៏ដូចជាក្នុងតំបន់។

## ១.២ គោលការណ៍ណែនាំ

ការបង្កើតឡើងនូវក្របខ័ណ្ឌនៃផែនទីតម្រង់ទិសរយៈពេល ៥ ឆ្នាំ របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា រួមបញ្ចូលនូវគោលការណ៍សំខាន់ៗដូចខាងក្រោម៖

- *អាចវាស់វែងបាន៖* គោលដៅដែលត្រូវសម្រេចបានមានបន្ទាត់ពេលវេលាច្បាស់លាស់ និងសូចនាករការអនុវត្ត ដើម្បីតាមដានវឌ្ឍនភាព
- *មានឥទ្ធិពល៖* ផ្តោតលើយុទ្ធសាស្ត្រ និងសកម្មភាព ដែលផ្តល់ឥទ្ធិពលខ្លាំងបំផុតសម្រាប់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងដែលគាំទ្រដោយយន្តការណ៍និរន្តរភាពរឹងមាំ
- *រួមបញ្ចូល៖* ជំរុញកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធ ដើម្បីទ្រទ្រង់និងផ្តល់អត្ថប្រយោជន៍ដល់កសិករខ្នាតតូច និងកសិករដែលជាស្ត្រី
- *ផ្អែកលើលទ្ធផល៖* លើកកម្ពស់គោលនយោបាយជាតិ និងស្របតាមអាណត្តិ និងអាទិភាពរបស់សមាជិក ព្រមទាំងផលប្រយោជន៍របស់ភាគីពាក់ព័ន្ធ
- *ភ្ជាប់ជាមួយពេលវេលា៖* ៥ឆ្នាំ (២០២២ ដល់ ២០២៦) ហើយអាចបន្តទៅមុខទៀត ដោយអាទិភាពនាពេលអនាគត នឹងត្រូវបានកំណត់ដោយគណៈកម្មការតម្រង់ទិសនិងគណៈកម្មការប្រតិបត្តិរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា។

## ១.៣ ដំណើរការរៀបចំ

ការបង្កើតឡើងនូវផែនទីតម្រង់ទិស របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា បានឆ្លងកាត់ដំណើរការយ៉ាងហ្មត់ចត់និងមានការចូលរួមយ៉ាងច្រើន តាំងពីខែតុលាឆ្នាំ២០២០ ដោយ

ចាប់ផ្ដើមចេញពីការត្រួតពិនិត្យឡើងវិញនូវឯកសារគម្រោងនិងរបាយការណ៍ស្រាវជ្រាវ ដែលពាក់ព័ន្ធនិងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព កសិកម្មអេកូឡូស៊ី ជីវចម្រុះ និងសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា បូករួមនឹងការពិគ្រោះយោបល់មួយចំនួនជាមួយនិងគណៈកម្មការប្រតិបត្តិនិងអនុគណៈកម្មការ នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ព្រមទាំងក្រុមអ្នកជំនាញទាំងកម្រិតជាតិនិងតំបន់។ ក្រុមអ្នកជំនាញក្នុងតំបន់និងអន្តរជាតិដែលបានចូលរួមពិគ្រោះយោបល់ មានដូចការិយាល័យប្រចាំតំបន់នៃមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD) ក្រុមសម្រាប់ការផ្លាស់ប្ដូរការស្រាវជ្រាវនិងបច្ចេកវិទ្យា (GRET) និងអង្គការស្បៀងអាហារនិងកសិកម្មនៃអង្គការសហប្រជាជាតិ (FAO) រួមទាំងសាកលវិទ្យាល័យ Kansas State university អង្គការសម្ព័ន្ធស្រាវជ្រាវសកល (GRA) និងមជ្ឈមណ្ឌលគ្រឿងយន្តកសិកម្មសមស្រប (CSAM) នៃគណៈកម្មាធិការអង្គការសហប្រជាជាតិផ្នែកសេដ្ឋកិច្ចសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP)។ សេចក្ដីព្រាងក្របខ័ណ្ឌផែនទីតម្រង់ទិស ត្រូវបានរៀបរៀងឡើងនិងបន្ទាប់មកត្រូវបានអភិវឌ្ឍនិងមានគោលបំណងសម្រាប់សិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ដែលបានគ្រោងរៀបចំនៅខែវិច្ឆិកាឆ្នាំ ២០២០។ ក៏ប៉ុន្តែសិក្ខាសាលានេះ ត្រូវបានពន្យាពេល២ដង ហើយជាចុងក្រោយក៏ត្រូវបានរំសាយវិញ ដោយសារគោរពទៅតាមវិធានការណ៍ការពារទប់ស្កាត់ការឆ្លងរាល ដាលនៃជម្ងឺកូវីត ១៩។

នៅក្នុងគ្រាលំបាក គណៈកម្មការប្រតិបត្តិរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា បានធ្វើការយ៉ាងជិតស្និទ្ធជាមួយនឹងក្រុមប្រឹក្សាពិគ្រោះយោបល់ និងរៀបចំការប្រជុំពិគ្រោះយោបល់នៅថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ ២០២១ ដោយមានការចូលរួមពីសមាជិក នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា អ្នករៀបចំគោលនយោបាយពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រសួងបរិស្ថាន (នាយកដ្ឋានជីវៈចម្រុះ) រួមទាំងភាគីពាក់ព័ន្ធដ៏ទៃទៀត ដូចជាអ្នកតំណាងវិស័យឯកជនមួយចំនួនមកពីសហព័ន្ធស្រូវអង្ករកម្ពុជា (CRF) សមាគមធនាគារនៅកម្ពុជា (ABC) និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា (CMA) ដើម្បីប្រមូលយកការចូលរួមដំណាក់កាលដំបូងសម្រាប់ចងក្រងឯកសារផែនទីតម្រង់ទិស។ លើសពីនេះទៅទៀត ខ្លឹមសារសំខាន់ៗនៃសេចក្ដីព្រាងផែនទីតម្រង់ទិសនេះ ត្រូវបានសម្រិតសម្រាំងនិងពិគ្រោះបន្ថែមទៀតទៅក្នុងកិច្ចប្រជុំទ្វេរភាគីតាមរយៈកិច្ចប្រជុំពិចម្ងាយមួយចំនួនទៀត ជាមួយនឹងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព (NCSD) នៃក្រសួងបរិស្ថាន (នាយកដ្ឋានបម្រែបម្រួលអាកាសធាតុនិងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា) ភាគីពាក់ព័ន្ធពីវិស័យឯកជន (សរុប១៣ ក្រុមហ៊ុន រួមទាំងអ្នកផ្គត់ផ្គង់ម៉ាស៊ីនកសិកម្មនិងគ្រាប់ពូជ គ្រឹះស្ថានហិរញ្ញវត្ថុ និងពាណិជ្ជករនៃផលិតផលកសិកម្មមានសុវត្ថិភាព) និងដៃគូអភិវឌ្ឍន៍សំខាន់ៗ (រួមមានទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការ (SDC) និងទីភ្នាក់ងារជំនួយអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ធនាគារ

អភិវឌ្ឍន៍អាស៊ី (ADB) អង្គការស្បៀងអាហារនិងកសិកម្មនៃសហប្រជាជាតិប្រចាំប្រទេសកម្ពុជា (FAO) សហភាពអ៊ឺរ៉ុប (EU) និងអង្គការកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ) ដើម្បីណែនាំនូវគំនិតនៃកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា និងដើម្បីយល់ដឹងពីចំណាប់អារម្មណ៍និងទស្សនៈវិស័យរបស់ពួកគេ ទៅលើកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព ដើម្បីកំណត់អាទិភាពសំខាន់ៗរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជាក្នុងរយៈពេល៥ ឆ្នាំខាងមុខនេះ។

## ២. សាវតានៃកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី

### ២.១ គំនិតនិងសារៈសំខាន់ នៃកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី

កសិកម្មអភិរក្ស គឺជាការអនុវត្តមួយនៃកសិកម្មអេកូឡូស៊ី[1] ដែលមានគោលបំណងធ្វើឱ្យផលិតភាពកសិកម្មទទួលប្រាក់ចំណេញនិងមានសន្តិសុខស្បៀងអាហារប្រសើរឡើងដោយមាននិរន្តរភាព ព្រមទាំងរក្សានិងពង្រឹងមូលដ្ឋានធនធាននិងបរិស្ថាន (Castella & Kibler, 2015)។ កសិកម្មអភិរក្ស ត្រូវបានកំណត់ដោយគោលការណ៍ចម្បង៣គឺ (១) ការភ្ជួររាស់ដីតិចតួចបំផុតឬមិនភ្ជួរតែម្តង (២) ការដាំដំណាំគម្របដីសរីរាង្គជាអចិន្ត្រៃយ៍ (សំណល់ដំណាំឬដំណាំគ្របដី) និង (៣) ការធ្វើពិពិធកម្មប្រភេទដំណាំ (វប្បកម្មឆ្លាស់ ដំណាំឆ្លាស់ជាដើម)។ គោលការណ៍ទាំងនេះ បង្ករអោយមានដំណើរការអេកូឡូស៊ី ដែលជាលំហូរឥតឈប់ឈរនៃសារធាតុសរីរាង្គស្រស់ៗ ដែលជំរុញភាពសម្បូរបែបនិងតួនាទីនៃភាវរស់ក្នុងដី ទម្រង់ដី និងកំណកស្រទាប់ដីសរីរាង្គ កាបូន (C) និងអាសូត (N) ដែលរួមចំណែកនៅក្នុងភាពធន់នៃប្រព័ន្ធ (Séguy et al., 2006) ។ ដោយផ្អែកលើគោលការណ៍ទាំងនេះ កសិ កម្មអភិរក្ស នាំមកនូវការអនុវត្តប្រកបដោយភាពច្នៃប្រឌិតនៅក្នុងប្រព័ន្ធផលិតកម្មកសិកម្ម ដែល ជួយទៅដល់ការពង្រឹងជីវៈចម្រុះ ការគ្រប់គ្រងធនធានដីធ្លី និងការអភិរក្សធនធានដី និងឈានទៅនាំមកនូវសមត្ថភាពនិងជីវភាពប្រសើរជាងមុននៃកសិករនិងសហគមន៍ក្នុងការធន់នឹងផលប៉ះពាល់បម្រែបម្រួលនៃអាកាសធាតុនិងវិបត្តិសេដ្ឋកិច្ច។ ភស្តុតាងជាក់ស្តែង បានបង្ហាញថា ទម្លាប់ការដាំដំណាំផ្អែកតាមកសិកម្មអភិរក្ស ជួយធ្វើអោយផលិតភាពដីនិងកម្លាំងពលកម្មប្រសើរឡើង នៅពេលដែលមានគ្រឿងយន្តកសិកម្មសមរម្យ ហើយនឹងធ្វើអោយមានផលវិជ្ជមានលើមុខងារជីវសាស្រ្តនៃដី ការប្រមូលផ្តុំសារធាតុសរីរាង្គនៃដី អត្រាចម្រោះទឹក និងវដ្តជីវជាតិ (Hok et al., 2015; Pheap, Lefèvre et al., 2019)។

កសិកម្មអភិរក្ស គ្របដណ្តប់ផ្ទៃដី ១៨០ លានហិចតា (១១% នៃដី ដែលអាចដាំដុះបានទូទាំងពិភពលោក) ដោយមានតំបន់ទៅតាមទ្វីបដូចជា៖ អាមេរិចខាងត្បូង ៦៩.២ លានហិចតា អាមេរិចខាង

[1] *ការអនុវត្តផ្អែកកសិកម្មអេកូឡូស៊ីនៅក្នុងបណ្តាប្រទេសមេគង្គ រួមមាន កសិកម្មសរីរាង្គ ការធ្វើកសិកម្មរួមបញ្ចូល គ្នា/ការធ្វើសួនដំណាំតាមផ្ទះ កសិកម្មអភិរក្ស ការគ្រប់គ្រងសត្វល្អិតរួមបញ្ចូលគ្នា (IPM) និងកសិរុក្ខកម្ម។*

ជើង ៦៣ លានហិចតា អាហ្វ្រិច ១.៥ លានហិចតា អ៊ឺរ៉ុប ៣.៦ លានហិចតា រុស្ស៊ីនិងអ៊ុយក្រែន ៥.៧ លានហិកតា អាស៊ី ១៤ លានហិចតា និង អូស្ត្រាលីនិងនូវែលសេឡង់ ២៣ លានហិកតា។ កំណើន នៃការប្រើប្រាស់ប្រព័ន្ធដាំដំណាំបែបកសិកម្មអភិរក្ស ត្រូវបានគេរំពឹងទុកនៅទូទាំងទ្វីបអាស៊ី នៅទសវត្សរ៍ខាងមុខ។ នៅក្នុងប្រទេសអាស៊ីជាច្រើន កសិកម្មអភិរក្សកំពុងតែត្រូវបានបញ្ចូលក្នុងកម្មវិធីអភិវឌ្ឍន៍កសិកម្មជាតិឬគាំទ្រដោយគោលនយោបាយសមស្របនិងការគាំទ្រពីស្ថាប័ន (Kassam et al., 2019)។

ម៉្យាងវិញទៀត ប្រពលវប្បកម្មនិរន្តរភាព គឺជាវិធីសាស្ត្រមួយ ដែលត្រូវបានគេស្គាល់យ៉ាងទូលំទូលាយថាជា "ការរួមបញ្ចូលគ្នានៃដំណើរការកសិកម្ម ដែលផលិតកម្មត្រូវបានរក្សាឬបង្កើនខណៈពេលដែលលទ្ធផលបរិស្ថានត្រូវបានធ្វើការពង្រឹង" (Pretty, 2018)។ គោលដៅចម្បង នៃប្រពលវប្បកម្មនិរន្តរភាព គឺប្រើប្រាស់ធនធានធម្មជាតិនិងមនុស្សឱ្យបានប្រសើជាងមុន ដូចជាដី ទឹក ជីវៈចម្រុះ ចំណេះដឹង និងបច្ចេកវិទ្យា ដូច្នេះការដាំដុះដីកាន់តែច្រើននិងការបាត់បង់ដើមទុនធម្មជាតិអាចត្រូវបានជៀសវាង។ ប្រពលវប្បកម្មនិរន្តរភាព ផ្អែកលើដំណាក់កាលមិនមែនលីនេអ៊ែរ (non-linear) ចំនួនបី ក្នុងការផ្លាស់ប្តូរឆ្ពោះទៅរកនិរន្តរភាពដូចជា៖ (១) ប្រសិទ្ធភាពធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់ធនធាននៅលើកសិដ្ឋាននិងនាំចូលធនធាន (២) ការជំនួសដោយផ្តោតលើបច្ចេកវិទ្យានិងការអនុវត្ត និង (៣) រចនាឡើងវិញ (ផ្លាស់ប្តូរ) ដំណើរការអេកូឡូស៊ីនិងការតភ្ជាប់ថ្នាក់(ពីចំការទៅទីផ្សារ)។ កន្លងមក ធ្លាប់មានភស្តុតាងថាកសិករ ដែលប្រើប្រាស់វិធានការផ្សេងៗរបស់ប្រពលវប្បកម្មនិរន្តរភាពអាចបង្កើនផលិតភាពតាមរយៈការអនុវត្តពូជដំណាំប្រភេទថ្មីនិងប្រសើរជាងមុន ដោយមានការផ្លាស់ប្តូរនូវការគ្រប់គ្រងក្សេត្រសាស្ត្រ-ក្សេត្របរិស្ថាន ឬពិពិធកម្មកសិដ្ឋានទៅជាប្រភេទដំណាំ សត្វចិញ្ចឹម ឬ ត្រីច្រើនប្រភេទ បន្ថែមទៅលើដំណាំចម្បងដែលមានស្រាប់។ និយាយម្យ៉ាងទៀត ប្រព័ន្ធប្រពលវប្បកម្មនិរន្តរភាព គួរតែអាចបង្កើតស្បៀង អាហារសរសៃ និងចំណីសត្វ បានច្រើនជាងមុន ប្រកបដោយនិរន្តរភាពជាមួយនឹងការប្រើប្រាស់ដីបន្ថែមជាអប្បបរមា ខណៈពេលការពារជីវចម្រុះនិងប្រព័ន្ធអេកូឡូស៊ី ដែលជាចំណុចកណ្តាលនៃកិច្ចខិតខំប្រឹងប្រែងជាសកលនៃការអភិវឌ្ឍន៍សន្តិសុខស្បៀងអាហារ។

កសិកម្មអេកូឡូស៊ី គឺជាវិធីសាស្ត្រជារួមមួយដែលផ្តោតលើដំណោះស្រាយបញ្ហាប្រឈមដ៏ស្មុគស្មាញនិងប្រទាក់ក្រឡាគ្នានៃភាពក្រីក្រ កង្វះខាតអាហារូបត្ថម្ភ ការសឹករេចរឹលនៃបរិស្ថាន និងបម្រែបម្រួលអាកាសធាតុ (Altieri, 2002)។ កសិកម្មអេកូឡូស៊ី មានគោលបំណងឆ្ពោះទៅរកការអភិវឌ្ឍចម្រុះប្រកបដោយចីរភាពនៅក្នុងវិមាត្រទាំងបីគឺ បរិស្ថាន សង្គម និង សេដ្ឋកិច្ច ព្រមទាំងចាត់ទុកការបង្កើតរួមគ្នានិងការចែករំលែកចំណេះដឹងជាគ្រឹះនៃការអន្តរាគមន៍ ដោយរួមបញ្ចូលវិទ្យាសាស្ត្រ ចំណេះដឹងប្រពៃណី និងការអនុវត្តចំណេះដឹងជាក់ស្តែងរបស់កសិករខ្នាតតូចនិងអ្នកពាក់ព័ន្ធដទៃ

ទៀត (FAO, 2018)។ កសិកម្មអេកូឡូស៊ី ផ្អែកលើវិធីសាស្ត្រទឹកដី (territorial approach) ដែលរួមបញ្ចូលគ្នានូវធាតុកសិកម្មអេកូឡូស៊ី សេដ្ឋកិច្ច និងសង្គម។ កសិកម្មអេកូឡូស៊ី អោយតម្លៃលើជីវៈចម្រុះ និងដំណើរការធម្មជាតិ (ដូចជាវដ្តនៃនីត្រូសែន កាបូន និងទឹក) ហើយចង់ធ្វើអោយមានកំណើននៃទិន្នផលស្បៀងអាហារ ដើម្បីអោយមានតុល្យភាពអាហាររូបត្ថម្ភ ពង្រឹងទីផ្សារស្មើភាពសម្រាប់ផលិតផលរបស់ពួកគេ លើកកម្ពស់ប្រព័ន្ធអេកូឡូស៊ី ដែលមានសុខភាពល្អនិងបង្កើនចំណេះ ដឹងផ្អែកលើចំណេះដឹងមូលដ្ឋានវិទ្យាសាស្ត្រ។ កសិកម្មអេកូឡូស៊ី ផ្អែកលើគោលការណ៍សំខាន់ ៥ យ៉ាង៖ (១) ការកែច្នៃឡើងវិញ (សារធាតុសរីរាង្គនិងវដ្តនៃសារធាតុចិញ្ចឹម) (២)កាត់បន្ថយការបាត់បង់ថាមពល ទឹក សារធាតុចិញ្ចឹម និងធនធានហ្សែន (៣) ភាពសម្បូរបែបនៃប្រភេទនិងធនធានហ្សែន (តាមពេលវេលានិងលំហនៅកម្រិតជីវាលនិងទេសភាព) (៤) បទប្បញ្ញត្តិនិង (៥) ការរួមបញ្ចូលគ្នាលើកកម្ពស់ដំណើរការនិងសេវាកម្មអេកូឡូស៊ីសំខាន់ៗ។

វិធីសាស្ត្រទាំងបីនេះ ត្រូវបានចាត់ទុកថាមានគោលការណ៍រូបវិទ្យាជីវៈនិងអនុញ្ញាតឱ្យរួមបញ្ចូលគ្នានូវភាពចម្រុះនៃខ្នាត ពីដី ទីវាល ដីស្រែ កសិដ្ឋាន ទេសភាព តំបន់ (រួមទាំងខ្សែច្រវាក់តម្លៃ) ការចូលរួមនៃសហគមន៍កសិករ សហករណ៍កសិកម្ម វិស័យឯកជនក្នុងស្រុក អាជីវកម្មកសិ-ពាណិជ្ជកម្ម និងអ្នកប្រើប្រាស់ ដើម្បីនាំមកទាំងកំណើនផលិតភាពនិងអត្ថប្រយោជន៍ដល់សេវាកម្មប្រព័ន្ធអេកូឡូស៊ី។ ដូច្នេះហើយ ការរចនាឡើងវិញនៃប្រព័ន្ធកសិអេកូឡូស៊ី គឺជាកិច្ចខិតខំប្រឹងប្រែងឥតឈប់ឈរនៃការផ្លាស់ប្តូរនិងការអភិវឌ្ឍ។ គោលនយោបាយសម្របសម្រួល ដើម្បីគ្រប់គ្រងជីវជាតិដី ប្រកបដោយនិរន្តរភាព ខណៈពេលដែលរក្សាបាននូវផលិតភាពនិងការផលិតអាហារ ដែលមានសុវត្ថិភាព និងមានដង់ស៊ីតេជីវជាតិ មានសារៈសំខាន់បំផុតដើម្បីឈានទៅដល់គោលដៅទាំងនេះ។

***តារាងទី១៖ សង្ខេបវិធីសាស្ត្រកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី***

| កម្រិត | ខ្នាត | គោលបំណង | វិធីសាស្ត្រ |
|---|---|---|---|
| បង្កើនប្រសិទ្ធភាព (ទឹក, សារធាតុចិញ្ចឹម ពលកម្ម និងដី) | ពីដីវាលទៅកសិដ្ឋាន | -ការចំណាយតិចនិង ផលប៉ះពាល់បរិស្ថានទាប<br>- បង្កើតឱកាសសេដ្ឋកិច្ចថ្មីសម្រាប់សហករណ៍កសិកម្ម និងវិស័យឯកជនក្នុងស្រុក | CI & SI និង កសិកម្មអេកូឡូស៊ី |
| ជម្រើសការអនុវត្ត និងការបញ្ចូលផ្សេងទៀត | ពីដីវាលទៅកសិដ្ឋាន | -គាំទ្រការផ្លាស់ប្តូរទៅការអនុវត្តផ្សេងទៀត<br>- កំណត់យន្តការហិរញ្ញវត្ថុ (កាបូន និងការទូទាត់សម្រាប់ទីផ្សារសេវាកម្មអេកូឡូហ្ស៊ី) | CI & SI និង កសិកម្មអេកូឡូស៊ី |
| រៀបចំប្រព័ន្ធអេកូឡូស៊ីឡើងវិញ | ដីទីវាល ទេសភាព តំបន់ (វិធីសាស្ត្រទឹកដី) | -កសាងនិរន្តរភាពនៅខ្នាតកសិដ្ឋាន<br>-បង្កើតការគាំទ្រផ្នែកសង្គម ស្ថាប័ន និងហិរញ្ញវត្ថុ | CI & SI និង កសិកម្មអេកូឡូស៊ី |
| បង្កើតឡើងវិញនូវបណ្តាញ រវាងកសិករខ្នាតតូច | ថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និងថ្នាក់ជាតិ | - ទំនាក់ទំនងដែលផ្ទាល់និងគាំទ្រគ្នាទៅវិញទៅមក<br>- ធ្វើកំណែទម្រង់សេដ្ឋកិច្ចក្នុងមូលដ្ឋាន បង្កើតឡើងវិញនូវតម្លៃនៃផលិតផលកសិកម្ម (ស្តង់ដា និងមាន | CI & SI និង កសិកម្មអេកូឡូស៊ី |

| | | | |
|---|---|---|---|
| និងអ្នកប្រើប្រាស់ | | លិខិតបញ្ជាក់/ស្លាកសញ្ញា)<br>- ជះឥទ្ធិពលលើតម្លៃនិងឥរិយាបទ | |

## ២.២ ប្រវត្តនៃការអភិវឌ្ឍកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ីនៅកម្ពុជា

ការអភិវឌ្ឍកសិកម្មអភិរក្សនៅកម្ពុជាទទួលបានអត្ថប្រយោជន៍ ពីការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុពីគម្រោងនិងកម្មវិធីអភិវឌ្ឍផ្សេងៗ ដោយមានការគាំទ្រផ្នែកស្ថាប័ននិងការប្តេជ្ញាចិត្តពីរាជរដ្ឋាភិបាលតាមរយៈក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ចាប់តាំងពីការចាប់ផ្តើមរចនានិងធ្វើតេស្តលើការដាំដំណាំ ដោយផ្អែកលើវិធីសាស្រ្តកសិកម្មអភិរក្សនៅក្នុងប្រព័ន្ធកសិអេកូឡូស៊ីផ្សេងគ្នានៅកម្ពុជាក្នុងឆ្នាំ ២០០៤ (យោងទៅលើឯកសារគម្រោងនិង Kong et al, ២០២០)។

ដោយយោងទៅលើអាំងឌីការទ័របន្ទាត់ពេលវេលានៃការអភិវឌ្ឍកសិកម្មអភិរក្ស ដូចនៅខាងក្រោម សកម្មភាពស្រាវជ្រាវទាក់ទងនិងកសិកម្មអភិរក្សដំបូងបំផុត បានចាប់ផ្តើមនៅឆ្នាំ ២០០៤ ហើយជាផ្នែកមួយនៃការធ្វើពិពិធកម្មដំណាំនិងគម្រោងអភិវឌ្ឍន៍ដំណាំកៅស៊ូខ្នាតតូច (SRDP) ដំណាក់កាលទី២ ដែលឧបត្ថម្ភថវិកាដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងអនុវត្តដោយអគ្គនាយកដ្ឋានកៅស៊ូ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងភាពជាដៃគូជាមួយមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ(CIRAD)។ ចាប់តាំងពីពេលនោះមកប្រទេសកម្ពុជាមានសមត្ថភាពធនធានមនុស្សចាំបាច់ ដែលមានចំណេះដឹងនិងបទពិសោធន៍បច្ចេកទេសលើវិធីសាស្រ្តកសិកម្មអភិរក្ស តាមរយៈការពិសោធន៍និងការធ្វើតេស្តសាកល្បងលើប្រព័ន្ធដំណាំគម្របដីប្រចាំឆ្នាំនៅតំបន់ខ្ពង់រាប ក៏ដូចជាការអភិវឌ្ឍនៃធនាគារហ្សែនដំណាំគម្របដី ដែលឈានទៅដល់ការចាប់ផ្តើមអភិរក្សហ្សែនដំណាំគម្របដីនៅឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម។

*រូបទី ១៖ តារាងពេលវេលានៃការអភិវឌ្ឍកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅកម្ពុជា*

| 2004 | 2008 | 2010 | 2014 | 2016 | 2018 | 2020 |
|---|---|---|---|---|---|---|
| • SRDP (2004-2008, AFD)<br>• ប្រព័ន្ធផលិតកម្មផ្អែកលើវិធីសាស្រ្ត CA ត្រូវបានបង្កើតឡើងនិងធ្វើតេស្តសាកល្បង ព្រមទាំងការអភិរក្សដំណាំគម្របដីនៅបុសខ្នុរ | • PADAC (2008-2012, AFD)<br>• PAMP (បុសខ្នុរ, AFD)<br>- ការសិក្សាតំបូងលើដីសេរីរាង្គ C | • SANREM-CRSP (2010-2014, USAID) | • PADAC ត្រូវបានប្តូរទៅជា CASC (រួមបញ្ចូលនៅក្រោម DALRM និងទទួលបានដីចំនួន 14.5 ហិចតា នៅបុសខ្នុរ) | • SIIL-USAID (ASMC, WAgN & CE SAIN) ផ្តោតលើ CA/SI<br>• CE SAIN ត្រូវបានបង្កើតឡើង (KSU, SIIL)<br>• ACTAE (2016-2019, AFD)<br>• EISOFUN (2016-2019, UNCCD/CCCA) | • CSAM (UN ESCAP) សិក្ខាសាលាកម្រិតតំបន់នៅឆ្នាំ 2018 & 2019<br>• CASF (2018-2021, USAID)<br>• MIGIP (តាំងពីឆ្នាំ 2017)<br>• CASIC ត្រូវបានផ្តួចផ្តើមឡើង | • CASIC ត្រូវបានដាក់អោយដំណើរការជាផ្លូវការនៅខែឧសភា ឆ្នាំ 2020<br>• WAT4CAM (2020-2024, AFD & EU)<br>• ASSET (2020-2025, AFD & EU) |

ចាប់តាំងពីឆ្នាំ ២០០៨ កសិកម្មអភិរក្ស ត្រូវបានអនុវត្តដោយអគ្គនាយកដ្ឋានកសិកម្ម នៅក្នុងគម្រោង PADAC (Projet d'Amélioration de l'Agriculture Cambodgienne) រយៈពេល៥ ឆ្នាំ ដែលទទួលបានការឧបត្ថម្ភផ្នែកថវិកាពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងជំនួយផ្នែកបច្ចេកទេសពីមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD)។ តំបន់គោលដៅសំខាន់ៗ មានទីតាំងស្ថិតនៅក្នុងខេត្តកំពង់ចាមនិងខេត្តបាត់ដំបង ដោយផ្តោតជាសំខាន់លើការរចនា ការលើកកម្ពស់ និងការវាយតម្លៃ នៃប្រព័ន្ធដាំដុះដំណាំតាមវិធីសាស្ត្រកសិកម្មអភិរក្ស សម្រាប់ផលិតកម្មដំណាំប្រចាំឆ្នាំនៅតំបន់ទំនាបនិងខ្ពង់រាប។ ក្រៅពីនេះ ក៏មានសកម្មភាពមួយចំនួន ដែលត្រូវបានអនុវត្តនៅខេត្តបាត់ដំបង តាមរយៈកម្មវិធីគ្រប់គ្រងកសិកម្មនិងធម្មជាតិប្រកបដោយនិរន្តភាព សហការគាំទ្រការស្រាវជ្រាវដោយកម្មវិធីគ្រប់គ្រងកសិកម្មនិងធម្មជាតិប្រកបដោយនិរន្តរភាព (SANREM - CSRP) ដែលទទួលបានការគាំទ្រផ្នែកថវិកាពីទីភ្នាក់ងារជំនួយអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ ២០១៤ និងនៅក្រោមភាពជាដៃគូរវាងនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD) និងសាកលវិទ្យាល័យបច្ចេកវិទ្យានិងកសិកម្មរដ្ឋការ៉ូលីណាខាងជើង (NC A&T)។ នៅឆ្នាំ២០០៩ មានការពិសោធន៍រយៈពេលវែងត្រូវបានអនុវត្តនិងការស្រាវជ្រាវលើដីសរីរាង្គកាបូន ត្រូវបានផ្តួចផ្តើមឡើងនៅស្ថានីយ៍បុសខ្នុរ ក្រោមកម្មវិធីសកម្មភាពកសិកម្មអេកូឡូស៊ីពហុប្រទេស (PAMPA) ដែលឧបត្ថម្ភថវិកាដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD)។

ដោយផ្អែកលើការវាយតម្លៃលើការរៀបចំស្ថាប័ននៅចុងបញ្ចប់នៃគម្រោង PADAC មជ្ឈមណ្ឌលសេវាកម្មកសិកម្មអភិរក្ស (CASC) ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៤ ជាផ្នែកមួយនៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម នៃអគ្គនាយកដ្ឋានកសិកម្ម និងមានការគាំទ្រពីមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD)។ នៅឆ្នាំ ២០១៦ អគ្គនាយកដ្ឋានកសិកម្ម បានផ្តល់ដីចំនួន ១៤.៥ ហិកតា ដល់នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម ដែលមានទីតាំងនៅក្នុងស្ថានីយ៍ផលិតកម្មគ្រាប់ពូជដំណាំខ្ពង់រាបចំការលើ ស្ថិតនៅក្នុងស្រុកចំការលើ ខេត្តកំពង់ចាម។ ដីមួយផ្នែកដែលភាគច្រើនគេស្គាល់ថាជាស្ថានីយ៍ស្រាវជ្រាវកសិកម្មអភិរក្សបុសខ្នុរតាំងពីឆ្នាំ២០១៦នេះ ត្រូវបានប្រើប្រាស់សម្រាប់ការស្រាវជ្រាវនិងការបណ្តុះបណ្តាល និងការថែរក្សាធនាគារហ្សែន ដែលមានដើមនិងគ្រាប់ពូជដំណាំគម្របដី ដែលមានតែមួយគត់នៅក្នុងប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ ២០១៤ មជ្ឈមណ្ឌលសេវាកម្មកសិកម្មអភិរក្ស បានពង្រីកសេវាកម្មទាក់ទងនិងកសិកម្មអភិរក្សរបស់ខ្លួន (រួមទាំងម៉ាស៊ីនដាំដោយមិនបាច់ភ្ជួរ) ដល់កសិករដាំដំណាំស្រូវ ពោត និងដំឡូងមី នៅក្នុងខេត្តបាត់ដំបង។

ក្នុងឆ្នាំ ២០១៦ មន្ទីរពិសោធន៍នវានុវត្តន៍ប្រកបដោយនិរន្តរភាព (SIIL) ក្រោមការឧបត្ថម្ភថវិកាពីទីភ្នាក់ងារជំនួយអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងសម្របសម្រួលដោយសាកលវិទ្យាល័យ Kansas State University (KSU) បានជួយគាំទ្រកិច្ចសហប្រតិបត្តិការរវាងគម្រោងផ្សេងៗ (គម្រោងសម្ព័ន្ធគ្រឿងយន្តកសិកម្មសមស្របសម្រាប់ប្រពលវប្បកម្មប្រកបដោយនិរន្តរភាព – ASMC និងគម្រោងស្ត្រីក្នុងបណ្តាញកសិកម្ម – WAgN) និងរួមចំណែកក្នុងការបង្កើតឡើងនូវមជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាពនិងអាហារូបត្ថម្ភ (CE SAIN) នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្នុងគោលបំណងពង្រីកកសិកម្មអភិរក្សនិងនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជាទៅក្នុងប្រព័ន្ធកសិកម្មអេកូឡូស៊ីផ្សេងៗគ្នានៅទូទាំងប្រទេស។

ក្រោយពីបានបង្កើតឡើងនៅក្នុងខែសីហាឆ្នាំ ២០១៦ មជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាពនិងអាហារូបត្ថម្ភ មានគោលបំណងធ្វើអោយប្រសើរឡើងនូវសន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅក្នុងប្រទេសម្ពុជា តាមរយៈការទ្រទ្រង់ការស្រាវជ្រាវនិងការអប់រំអំពីកសិកម្ម និងការលើកកម្ពស់នវានុវត្តន៍។ មជ្ឈមណ្ឌល បានធ្វើការយ៉ាងជិតស្និទ្ធជាមួយសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដើម្បីបង្កើននូវចំណេះដឹងនិងជំនាញនៃបុគ្គលិករដ្ឋក្នុងផ្នែកកសិកម្ម និងដើម្បីជំរុញកំណើននៅក្នុងវិស័យឯកជន។ មជ្ឈមណ្ឌលនេះ ក៏ផ្តល់ការគាំទ្រផ្នែកការសម្របសម្រួលដល់មន្ទីរពិសោធន៍នវានុវត្តន៍ស្បៀងសម្រាប់អនាគត (Feed the Future Innovation Labs) ដៃគូអនុវត្តរបស់ប្រទេសកម្ពុជា និងទីភ្នាក់ងារជំនួយអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងកម្មវិធីរបស់រដ្ឋាភិបាល ម្ចាស់ជំនួយ និងវិស័យឯកជនផ្សេងៗ។ មជ្ឈមណ្ឌល បានបង្កើតឧទ្យានបច្ចេកវិទ្យាចំនួន ៥ ដែលរួមបញ្ចូលទាំងទាំងការគាំទ្រដល់ស្ថានីយ៍បុសខ្នុរផងដែរ។

គម្រោងសម្ព័ន្ធគ្រឿងយន្តកសិកម្មសមស្របសម្រាប់ប្រពលវប្បកម្មប្រកបដោយនិរន្តរភាព ដោយមានការគាំទ្រពីទីភ្នាក់ងារជំនួយអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) តាមរយៈកម្មវិធីស្បៀងសម្រាប់អនាគត (Feed the Future) គម្រោងសម្ព័ន្ធគ្រឿងយន្តកសិកម្មសមស្របសម្រាប់ប្រពលវប្បកម្មប្រកបដោយនិរន្តរភាព ត្រូវបានផ្តួចផ្តើមឡើងនៅឆ្នាំ២០១៦ សម្រាប់ការសិក្សាស្រាវជ្រាវលើការរចនានិងបង្កើតគំរូម៉ាស៊ីនដាំគ្រាប់ពូជសម្រាប់កសិករ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម នាយកដ្ឋានវិស្វកម្មកសិកម្ម មជ្ឈមណ្ឌលសេវាកម្មកសិកម្មអភិរក្សនៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម និងមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD)។ គោលបំណងរួម នៃគម្រោងនេះគឺ ដើម្បីធ្វើប្រពលវប្បកម្មលើប្រព័ន្ធដាំដុះរបស់កសិករខ្នាតតូចនិងដំណើរការលើកសិដ្ឋានតាមរយៈយន្តកម្មប្រកបដោយនិរន្តរភាព។

មួយវិញទៀត គម្រោងស្ត្រីក្នុងបណ្តាញកសិកម្ម (WAgN) កម្ពុជា មានគោលបំណងលើកកម្ពស់ស្ត្រី និងធ្វើអោយប្រសើរឡើងនូវអាហារូបត្ថម្ភ រយៈការលើកកម្ពស់ការចូលរួមរបស់ស្ត្រីនៅក្នុងសាកវប្ប

កម្មតាមបែបប្រពលវប្បកម្មនិរន្តរភាពនិងខ្សែច្រវាក់តម្លៃស្រូវ។ ដើម្បីសម្រេចបាននូវគោលដៅនេះ គម្រោងផ្តោត លើការធ្វើឱ្យប្រសើរឡើងនូវស្ថានភាពសេដ្ឋកិច្ចសង្គមនិងអាហារូបត្ថម្ភរបស់ស្ត្រីនិងគ្រួសារ ព្រមទាំងកំណត់អត្តសញ្ញាណនិងពង្រឹងបច្ចេកវិទ្យា ដែលមានស្រាប់និងសក្តានុពលការអនុវត្តនិងគោលនយោបាយ ដែលជួយលើកកម្ពស់ដល់ការផលិតអាហារមានជីវជាតិនិងទីផ្សារព្រមទាំងការពារធនធានកសិកម្មអេកូឡូស៊ី។

លើសពីនេះ គម្រោងផ្សេងទៀត ដែលរួមចំណែកដល់ការលើកកម្ពស់កសិកម្មអភិរក្សនិងកសិកម្មអេកូឡូស៊ីនៅកម្ពុជាមានដូចជា គម្រោងដំណើរឆ្ពោះទៅរកការផ្លាស់ប្តូរកសិកម្មអេកូឡូស៊ីអន្តរកាលនៅអាស៊ីអាគ្នេយ៍ (ACTAE) ដែលឧបត្ថម្ភដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ក្នុងឆ្នាំ ២០១៥-២០១៨ និងគម្រោងប្រពលវប្បកម្មអេកូឡូស៊ីនិងសេវាកម្មនៃប្រព័ន្ធអេកូឡូស៊ីដី(EISOFUN) ក្រោមអនុសញ្ញារបស់អង្គការសហប្រជាជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែក្លាយជាវាលរហោឋាន (UNCCD) និងកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ក្នុងឆ្នាំ ២០១៦-២០១៨។

ក្រៅពីគំនិតផ្តួចផ្តើមនិងគម្រោងទាំងនេះ មជ្ឈមណ្ឌលគ្រឿងយន្តកសិកម្មសមស្រប នៃអង្គការសហប្រជាជាតិ (CSAM) ដែលជាស្ថាប័នប្រចាំតំបន់នៃគណៈកម្មការសេដ្ឋកិច្ចនិងសង្គមរបស់អង្គការសហប្រជាជាតិសម្រាប់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP) បានសហការជាមួយអគ្គនាយកដ្ឋានកសិកម្មនិងដៃគូដទៃទៀត រៀបចំសិក្ខាសាលាថ្នាក់តំបន់សម្រាប់អាស៊ីនិងប៉ាស៊ីហ្វិកនៅឆ្នាំ២០១៨ និងវគ្គបណ្តុះបណ្តាលថ្នាក់តំបន់មួយទៀតនៅឆ្នាំ២០១៩ លើប្រធានបទទាក់ទងគ្រឿងយន្តកសិកម្មក្នុងការងារកសិកម្មអភិរក្ស។ វគ្គបណ្តុះបណ្តាលថ្នាក់តំបន់នៅឆ្នាំ២០១៩ ដែលបានប្រមូលផ្តុំអ្នកចូលរួមចំនួន ៣៧ នាក់មកពី ១៨ ប្រទេសក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក បានផ្តួចផ្តើមកំណត់នូវតម្រូវការសម្រាប់វគ្គបណ្តុះបណ្តាលនាពេលអនាគត ដែលត្រូវផ្តល់ជូនដោយមជ្ឈមណ្ឌលសេវាកម្មកសិកម្មអភិរក្សនៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មនិងដៃគូរបស់ខ្លួន ដើម្បីទាញយកអត្ថប្រយោជន៍ពីប្រវត្តិដ៏យូរអង្វែងរបស់ស្ថានីយបុសខ្នុរ។

ក្នុងកំឡុងពេល នៃការអភិវឌ្ឍកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ីឆ្ពោះទៅរកចក្ខុវិស័យប្រកបដោយនិរន្តរភាព វាមានសារៈសំខាន់ណាស់ក្នុងការទាក់ទាញឱ្យមានការចូលរួមពីតួអង្គផ្សេងៗក្នុងវិស័យឯកជនតាមខ្សែច្រវាក់តម្លៃកសិកម្មក្នុងការផ្តល់បច្ចេកវិទ្យា ការបញ្ជូលចំណេះដឹងអំពីប្រតិបត្តិការ និងការទទួលបានហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ដំណើរការផ្លាស់ប្តូរកសិករបន្ថែមលើសេវាកម្មដែលផ្តល់ដោយមជ្ឈមណ្ឌលសេវាកម្មកសិកម្មអភិរក្ស នៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម។ ដូច្នេះសេវាកម្មកសិកម្មអភិរក្ស ដែលមានថ្លៃឈ្នួលតាមរយៈគម្រោងគម្រោងការផ្តល់សេវាបច្ចេកទេសកសិកម្មអភិរក្សដោយមានការបង់ថ្លៃសេវាកម្ម (CASF) ឧបត្ថម្ភដោយទីភ្នាក់ងារជំនួយអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ (USAID) និងអនុវត្តដោយមជ្ឈមណ្ឌលឧត្តម

ភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាពនិងអាហារូបត្ថម្ភ (CE SAIN) ក្នុងភាពជាដៃគូជាមួយនាយកដ្ឋានវិស្វកម្មកសិកម្ម មជ្ឈមណ្ឌលសេវាកម្មកសិកម្មអភិរក្សនៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD) និងអង្គការស្វីសខនថាក់ ក្នុងឆ្នាំ ២០១៨-២០២១ រួមជាមួយកម្មវិធីកំណើនដោយបរិយាប័ន្ននិងនវានុវត្តន៍នៃតំបន់មេគង្គ (MIGIP) ដែលត្រូវបានឧបត្ថម្ភថវិកាដោយទីភ្នាក់ងារស្វីស សម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC) និងអនុវត្តដោយអង្គការស្វីសខនថាក់តាំងពីឆ្នាំ២០១៧ បានជួយសម្រួលដល់ការចូលរួមរបស់វិស័យឯកជន និងបានរួមចំណែកក្នុងការធ្វើពាណិជ្ជកម្មម៉ាស៊ីនកសិកម្មនិងផលិតកម្មពូជដំណាំគម្របដី។

បន្ថែមពីនេះ ការគ្រប់គ្រងធនធានទឹកនិងដំណើការផ្លាស់ប្តូរប្រព័ន្ធអេកូឡូស៊ីនៅកម្ពុជា (WAT4CAM) គឺជាគម្រោងមានរយៈពេល៤ ឆ្នាំ (២០២០-២០២៤) ដែលឧបត្ថម្ភថវិកាដោយទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងសហភាពអឺរ៉ុប (EU) ក្នុងគោលបំណងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រនិងដើម្បីគាំទ្រដល់ការធ្វើកសិកម្មប្រកបដោយភាពច្នៃប្រឌិត ដែលស្របតាមអាកាសធាតុនៅក្នុងខេត្តចំនួន៥។ សមាសធាតុមួយក្នុងចំណោមសមាសធាតុទាំងបួនរបស់គម្រោងផ្តោតលើការអនុវត្តកសិកម្មប្រកបដោយភាពច្នៃប្រឌិតនិងខ្សែច្រវាក់តម្លៃស្រូវ ដែលគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិងអគ្គនាយកដ្ឋានកសិកម្ម។ នៅក្នុងសមាសធាតុកសិកម្មនេះ អនុសមាសភាគមួយផ្តោតលើការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍ (R4D) លើអនុវិស័យកសិអេកូឡូស៊ីក្រោមការដឹកនាំរបស់មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD)។ អនុសមាសភាគស្រាវជ្រាវសម្រាប់ការអភិវឌ្ឍ (R4D) មានគោលបំណងស្វែងរកវិធីសាស្ត្រអន្តរាគមន៍និងប្រព័ន្ធដាំដុះថ្មីៗ ដែលត្រូវនឹងគោលការណ៍នៃកសិអេកូឡូស៊ីសម្រាប់ស្រូវដែលមានប្រព័ន្ធស្រោចស្រព។

អ្វីដែលសំខាន់បំផុតនោះគឺ គម្រោងនិងកម្មវិធីដែលពាក់ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព បានពិភាក្សានិងផ្តួចផ្តើមក្នុងឆ្នាំ២០១៨ ស្តីពីការបង្កើតសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា (CASIC) ដែលត្រូវបានគាំទ្រដោយរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងបានបើកដំណើរការជាផ្លូវការនៅពាក់កណ្តាលឆ្នាំ២០២០។ ព័ត៌មាននិងរចនាសម្ព័ន្ធលម្អិតរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា នឹងត្រូវបង្ហាញនៅក្នុងផ្នែកទី ៤។

នៅថ្នាក់តំបន់ ប្រទេសកម្ពុជាបានចូលរួមយ៉ាងសកម្មនៅក្នុងវេទិកានិងគំនិតផ្តួចផ្តើមក្នុងតំបន់មួយ

ចំនួនរួមមាន កសិកម្មអេកូឡូស៊ីនៅអាស៊ីអាគ្នេយ៍ (ASEA)[2] មជ្ឈមណ្ឌលគ្រឿងយន្តកសិកម្មសមស្រប នៃអង្គការសហប្រជាជាតិ (CSAM)[3] និងបណ្ដាញសិក្សាកសិកម្មអេកូឡូស៊ីនៅតំបន់អាស៊ីអាគ្នេយ៍ (ALiSEA)[4]។ នាពេលថ្មីៗនេះសហភាពអឺរ៉ុប (EU) និងភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) បានផ្ដល់មូលនិធិដល់គម្រោងផ្លាស់ប្ដូរប្រព័ន្ធសុវត្ថិភាពស្បៀងអាហារនិងកសិកម្មអេកូឡូស៊ី (ASSET) នៅក្នុងបណ្ដាប្រទេសអាស៊ីអាគ្នេយ៍ចំនួន៤ រួមមានកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម ក្នុងឆ្នាំ ២០២០-២០២៥។ គម្រោងផ្លាស់ប្ដូរប្រព័ន្ធសុវត្ថិភាពស្បៀងអាហារនិងកសិកម្មអេកូឡូស៊ី គឺជាគម្រោងដែលសហការអនុវត្តដោយក្រុមសម្រាប់ផ្លាស់ប្ដូរការស្រាវជ្រាវនិងបច្ចេកវិទ្យា (GRET) និងមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD) ក្រោមភាពជាដៃគូជាមួយអង្គការក្នុងស្រុកមួយចំនួន ដែលនៅក្នុងប្រទេសកម្ពុជា រួមមាន វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា (ITC) នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម អង្គការស្វីសខនថាក់ UNI4Coo និងមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD)។ គោលបំណងចម្បងរបស់គម្រោងផ្លាស់ប្ដូរប្រព័ន្ធសុវត្ថិភាពស្បៀងអាហារនិងកសិកម្ម គឺដើម្បី "ទាញយកសក្ដានុពលនៃកសិអេកូឡូស៊ីនៅអាស៊ីអាគ្នេយ៍ សម្រាប់ផ្លាស់ប្ដូរប្រព័ន្ធស្បៀងអាហារនិងកសិកម្មទៅជាប្រព័ន្ធមួយ ដែលប្រកបដោយនិរន្តរភាព ហើយជាពិសេសមានសុវត្ថិភាពនិងរួមបញ្ចូលគ្នា" (ព័ត៌មានគម្រោងផ្លាស់ប្ដូរប្រព័ន្ធសុវត្ថិភាពស្បៀងអាហារនិងកសិកម្ម)។

## ២.៣ លទ្ធផលនៃការអភិវឌ្ឍកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងកសិកម្មអេកូឡូស៊ីនៅកម្ពុជា

ការអភិវឌ្ឍកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ក្នុងរយៈពេលពីរទសវត្សរ៍កន្លងមកនេះ មានលទ្ធផលគួរឱ្យកត់សម្គាល់ យោងតាមនវានុវត្តន៍បច្ចេកទេស ការគាំទ្រប្រតិបត្តិការ និងផលប៉ះពាល់ជាក់ស្ដែងលើដីនិងបរិស្ថាន ដែលអាចសង្កេតឃើញបាននៅក្នុងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងប្រព័ន្ធកសិកម្មអេកូឡូស៊ីនៅកម្ពុជា។

នវានុវត្តន៍បច្ចេកទេសរួមមាន ប៉ុន្តែមិនកំណត់ចំពោះចំណុចដូចខាងក្រោម៖

- កាត់បន្ថយការភ្ជួររាស់ដោយប្រើសំណល់ដំណាំមុនៗ និងការធ្វើពិពិធកម្មដំណាំដើម្បីបញ្ឈប់សំណឹកដីនិងប្រយុទ្ធប្រឆាំងនឹងការរេចរឹលដី ដែលបង្កឡើងដោយការភ្ជួររាស់

[2] *ពីមុនត្រូវបានគេស្គាល់ថាជាបណ្ដាញកសិកម្មអភិរក្សនៅអាស៊ីអាគ្នេយ៍ ដែលគ្របដណ្ដប់ប្រទេសចំនួន៨ រួមទាំងប្រទេសកម្ពុជាផងដែរ។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល* www.cansea.org.vn and https://www.cirad.fr/en/our-research/platforms-in-partnership-for-research-and-training/list-of-platforms/asea.
www.cansea.org.vn and https://www.cirad.fr/en/our-research/platforms-in-partnership-for-research-and-training/list-of-platforms/asea.

[3] *តំណាងដោយនាយកដ្ឋានវិស្វកម្មកសិកម្ម សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល* http://www.un-csam.org.

[4] *គ្របដណ្ដប់ប្រទេសចំនួន៩ រួមទាំងប្រទេសកម្ពុជា។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើល* https://ali-sea.org.

- ការប្រើប្រាស់ដំណាំគម្របដី ដើម្បីដោះស្រាយបញ្ហាកង្វល់ជុំវិញការប្រើប្រាស់ថ្នាំសម្លាប់ស្មៅខុសបច្ចេកទេសនិងហួសកម្រិត
- ការណែនាំអំពីការផលិតបន្លែ ផ្អែកលើកសិកម្មអភិរក្ស រួមជាមួយប្រព័ន្ធស្រោចស្រពដោយតំណក់ទឹក
- ការកំណត់អត្តសញ្ញាណល្បាយដំណាំគម្របដីល្អបំផុត យោងតាមប្រព័ន្ធអេកូឡូស៊ី ប្រព័ន្ធកសិកម្ម និងសេវាកម្មអេកូឡូស៊ីរំពឹងទុក ដើម្បីគាំទ្រដល់ផលិតភាពនិងស្ថិរភាព បើប្រៀបធៀបទៅនឹងដំណាំគម្របដីតែមួយប្រភេទ និង
- ការណែនាំបច្ចេកទេសសាបព្រួសបៃតង (green sowing technique) ដើម្បីបង្កើនភាពបត់បែននៃប្រតិបត្តិការកសិកម្ម កាត់បន្ថយថ្លៃដើមនៃផលិតកម្ម និងធ្វើឱ្យប្រសើរឡើងនូវទឹក សារធាតុចិញ្ចឹម និងការគ្រប់គ្រងស្មៅធៀបទៅនឹងការសាបព្រួសនៅលើកាកសំណល់រុក្ខជាតិងាប់។ ការសាបព្រួសបៃតង គឺជាផ្លូវឆ្ពោះទៅរកប្រព័ន្ធដាំដុះកសិកម្មអភិរក្សសរីរាង្គ។

ម៉្យាងវិញទៀត ការគាំទ្រផ្នែកប្រតិបត្តិការជាច្រើន ត្រូវបានដាក់ឱ្យដំណើរការ រួមមាន៖
- ការសម្របសម្រួលដល់កសិករក្នុងការទទួលបានគ្រឿងយន្តកសិកម្មសមស្របសម្រាប់កសិកម្មអភិរក្សនិងសេវាកម្មកសិកម្មអភិរក្ស (ឧបករណ៍កៀរពង្រាបដីអោយរាបស្មើ ម៉ាស៊ីនដាំដោយមិនបាច់ភ្ជួរ ម៉ាស៊ីនព្រោះគ្រាប់ និងឧបករណ៍កិនពង្រាបដំណាំគម្របដី) ដែលត្រូវបានណែនាំ ធ្វើតេស្តសាកល្បង និងធ្វើអោយស្របទៅនឹងលក្ខខណ្ឌក្នុងស្រុក ដោយមានការយកចិត្តទុក ដាក់យ៉ាងជាក់លាក់ចំពោះសហករណ៍កសិកម្មនិងអ្នកផ្តល់សេវាកម្មក្នុងស្រុក ដើម្បីបង្កើនសេវា កម្មម៉ាស៊ីនកសិកម្មដល់កសិករ
- ការសម្របសម្រួលដល់កសិករក្នុងការទទួលបានសម្ភារៈដំណាំគម្របដី ដែលមានលក្ខណៈចម្រុះនិងចំហរ ដែលផ្តល់ដោយធនាគារហ្សែន (បច្ចុប្បន្នកំពុងអភិរក្ស ៥២ ប្រភេទដែលមាន ៣៣៥ ពូជនៃសេនេទិកដំណាំ) និងគ្រប់គ្រងដោយមជ្ឈមណ្ឌលសេវាកម្មកសិកម្មអភិរក្ស នៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម ដល់សហគ្រាសនិងកសិករក្នុងស្រុក ដើម្បីផលិតគ្រាប់ពូជដំណាំគម្របដី បំពេញតាមតម្រូវការសម្រាប់ការទទួលយកក្នុងការអនុវត្តកសិកម្មអភិរក្ស។
- ការវិនិយោគលើដើមទុនសង្គមនិងការសិក្សារួម ដើម្បីបង្កើនការសម្របខ្លួននិងការអនុម័ត និង
- ការលើកកម្ពស់ការរួមបញ្ចូលគ្នានិងការសម្របសម្រួលអន្តរវិស័យនិងក្នុងចំណោមអ្នកពាក់ព័ន្ធតាមរយៈការសន្ទនាគោលនយោបាយតាមរយៈវេទិកា ដែលជំរុញដោយសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា។

មិនមានទិន្នន័យទូទាំងប្រទេស ទាក់ទងនឹងការទទួលយកកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែផ្អែកលើទិន្នន័យគម្រោង ដែលមានស្រាប់និងប្រមូលបានដោយ

របាយការណ៍មជ្ឈមណ្ឌលសេវាកម្មកសិកម្មអភិរក្ស នៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម ក្នុងឆ្នាំ២០២០ (*នៅក្នុងសេចក្តីព្រាងកំណត់សម្គាល់របស់ខ្លួនទៅរដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ*) មានចំនួន៩៥៩គ្រួសារ ដែលកំពុងអនុវត្តសមាសធាតុផ្សេងៗគ្នានៃគោលការណ៍កសិកម្មអភិរក្សនៅលើដីស្រែសរុបរបស់ពួកគេចំនួន ១.០២២ហិកតា ដោយរួមមាន អ្នកដែលកំពុង ប្រើឧបករណ៍ធ្វើដីអោយរាបស្មើ (១៦៨ហិកតា) ប្រើប្រាស់ដំណាំគម្របដី ដើម្បីធ្វើឱ្យដីប្រសើរឡើងមុនផលិតកម្មពោត ស្រូវ ដំឡូងជ្វា និងសណ្តែក (៦០ ហិកតា) ប្រើសេវាកម្មម៉ាស៊ីនដាំដោយមិនបាច់ភ្ជួរ (៦៥០ហិកតា) ដាំដំណាំចំណីសត្វដើម្បីបង្កើនប្រាក់ចំណូលនិងធ្វើឱ្យដីប្រសើរឡើង (២ ហិកតា) ប្រើដំណាំគម្របដី ដើម្បីកែលម្អដីបន្ទាប់ពីការប្រមូលផលស្រូវ (១០៦ហិកតា) ផលិតដំណាំគម្របដីសម្រាប់កសិដ្ឋានផ្ទាល់ខ្លួននិងចែកចាយ (៣២ហិកតា) និងពិសោធន៍សាកល្បងលើការធ្វើពិពិធកម្មដំណាំគ្រាប់ (សណ្តែក ពោត និងបន្លែ) បន្ទាប់ពីការប្រមូលផលស្រូវ (៤.៥ហិកតា)។

ការពិសោធន៍នៅស្ថានីយ៍បុសខ្នុរនិងទីតាំងកសិដ្ឋាននានា បានបង្ហាញថាប្រព័ន្ធផលិតកម្មដែលផ្អែកលើកសិកម្មអភិរក្ស មិនត្រឹមតែធ្វើឱ្យការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវធនធាននិងធាតុចូលកសិកម្ម (ដី ទឹក ជី និងថ្នាំសំលាប់សត្វល្អិត/ថ្នាំសំលាប់ស្មៅ) និងផលិតភាពប្រសើរឡើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានផលវិជ្ជមានចំពោះការស្តារសុខភាពដី សុវត្ថិភាព និងសន្តិសុខស្បៀង ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ ភស្តុតាងពីការស្រាវជ្រាវ ការពិសោធន៍ និងការផ្សព្វផ្សាយមួយចំនួន ដែលបានធ្វើឡើងនៅក្នុងប្រព័ន្ធកសិកម្មអេកូឡូស៊ីផ្សេងៗ នៅក្នុងប្រទេសកម្ពុជាត្រូវបានសង្ខេបនៅក្នុងតារាងខាងក្រោម។

**តារាងទី២៖ ភស្តុតាងនៃឥទ្ធិពលសេដ្ឋកិច្ច កសិកម្ម និង បរិស្ថាននៃការអនុវត្តកសិកម្មអភិរក្ស**

| ឥទ្ធិពល | ការរៀបរាប់ពីឥទ្ធិពល |
|---|---|
| ឥទ្ធិពលលើសំណឹកដី ការប្រើប្រាស់ធាតុចូលនិងប្រាក់ចំណេញសុទ្ធ នៃផលិតកម្មពោតតំបន់ខ្ពង់ រាបនៅរតនៈមណ្ឌល (បាត់ដំបង) | ការកាត់បន្ថយសំណឹកដីប្រចាំឆ្នាំ កើតឡើងរហូតដល់ ៩២.៧% ក្នុងឆ្នាំទីមួយនៃការផ្លាស់ប្តូរមកវិធីសាស្ត្រកសិកម្មអភិរក្ស |
| | កាត់បន្ថយការប្រើប្រាស់ជីគីមីបាន ៤២% ឬ ៥០ដុល្លារ ក្នុង១ហិកតា |
| | កាត់បន្ថយចំណាយផលិតកម្មសរុបបានប្រមាណ ១០% ក្នុង១ហិកតា |
| | បង្កើតប្រាក់ចំណេញសុទ្ធបាន ១២% ឬ១១៧ ដុល្លារ ក្នុង ១ហិកតា |
| ឥទ្ធិពលលើទិន្នផលនិងប្រាក់ចំណេញសុទ្ធនៃផលិតកម្មស្រូវអាស្រ័យទឹកភ្លៀង (ស្រូវផ្ការំដួល) នៅបាណន់ (បាត់ដំបង) | បង្កើនទិន្នផលមធ្យមបាន ០.៨ តោន ក្នុង១ហិកតា |
| | បង្កើនប្រាក់ចំណេញសុទ្ធបានប្រមាណ ២០០ដុល្លារ ក្នុង១ហិចតា |

| | |
|---|---|
| ការកើនឡើងនៃកាបូនសរីរាង្គដី (SOC) និងប្រភាគកាបូន | បង្កើនជាមធ្យម ៥១០គីឡូក្រាមនៃកាបូន (C) និង ១៣០ គីឡូក្រាមនៃអាសូត (N) ក្នុង១ហិកតាក្នុង១ឆ្នាំនៅជម្រៅ 0-៤០ សង់ទីម៉ែត្រ ក្នុងរយៈពេល ៣ឆ្នាំ នៃការប្រើប្រាស់វិធី សាស្ត្រCA ក្រោមផលិតកម្មស្រូវដោយស្រោចស្រពនៅលើដី Yellow Podzol ស្ថិតនៅស្ទឹងជីនិត (កំពង់ធំ) |
| | បង្កើនស្តុក SOC ចាប់ពី ៦% ទៅ ២៨% នៅស្រទាប់ដីខាងលើ ដែលតំណាងអោយ៤០០ គីឡូក្រាមនៃ (C) និង ៧៥ គីឡូក្រាមនៃ (N) ក្នុងមួយហិកតាក្នុងមួយឆ្នាំនៅជម្រៅ 0-២០ សង់ទីម៉ែត្រ ក្នុងរយៈពេល ៤ ឆ្នាំនៃការប្រើប្រាស់ CA នៅក្នុងប្រព័ន្ធដាំដុះសណ្តែកសៀងនិងពោតនៅលើដីក្រហម (Red Oxisol) នៅស្ថានីយបុសខ្នុរ (Hok et al., 2015) |
| | បង្កើនស្តុកសរីរាង្គ (C) ពី ៥៦% ទៅ ១២៧% នៅក្នុងស្រទាប់ ដីខាងលើ (Hok et al., 2015) |
| | បង្កើន labile-C និងរំលាយសរីរាង្គ (C) ពី ២០% ទៅ ៦០% នៅក្នុងស្រទាប់ដីខាងលើ (Hok et al., 2018) |
| សារធាតុចិញ្ចឹមនីត្រូសែន ($NH4^+$ & $NO3^-$) ដែលមាននៅក្នុងដី | កើនឡើងជាងពីរដង ដែលបង្ហាញពីការកើនឡើងនៃវដ្តនៃសារធាតុចិញ្ចឹមនៅក្នុងដី និងការដែលវាមានទំនាក់ទំនងជាមួយនឹងការប្រើប្រាស់ដំណាំគម្របដី (ធាតុចូលជីវម៉ាសនិង បម្លែងអាសូត) និងការបញ្ឈប់ការភ្ជួរដី ដែលបង្កើនស្ថិរភាព និងភាពសកម្មនៃមីក្រូសរីរាង្គទាំងនោះក្នុងដី (Pheap, Lefèvre et al., 2019) |
| ការកើនឡើងនៃបណ្តុំអតិសុខុមប្រាណនៅក្នុងដី | បង្កើនទ្វេដងនៃដង្ហើមដី (0-១០ សង់ទីម៉ែត្រ) បង្ហាញពីចំនួនបណ្តុំអតិសុខុមក្នុងកម្រិតខ្ពស់ជាងមុន ដែលចូលរួមក្នុងសារធាតុសរីរាង្គនិងវដ្តអង្គចិញ្ចឹម ក៏ដូចជាការគ្រប់គ្រងសត្វចង្រៃនិងជម្ងឺផងដែរ (Pheap, Lefèvre et al., 2019) |
| | បង្កើនសកម្មភាពអង់ស៊ីមដីដោយការប្រើប្រាស់កសិកម្មអភិរក្ស ពី ១៨% ទៅ ៤៩% (Hok et al., 2018) |
| ឥទ្ធិពលលើរចនាសម្ព័ន្ធដី | បង្កើនទ្វេដងនៃការផ្តុំគ្នានៃបំណាស់ដី (0-១០ សង់ទីម៉ែត្រ) ដែលនាំអោយប្រហោងរន្ធនៃដីកើនឡើង ដែលជួយដល់ការជ្រាបចូលក្នុងដីនៃទឹកនិងអុកស៊ីសែន (Pheap, Lefèvre et al., 2019) |

| | |
|---|---|
| ឥទ្ធិពលលើការជ្រាបចូលនៃទឹក | បង្កើនអត្រាជ្រាបចូលក្នុងដីនៃទឹក២ដង (ដីក្រហម នៅបុសខ្នុរនិងរតនៈមណ្ឌលខេត្តបាត់ដំបង) (ទឹក១២៥ មីល្លីម៉ែត្រក្នុងមួយនាទីក្រោមការគ្រប់គ្រងធម្មតា ២៦៥មីល្លី ម៉ែត្រនៃការជ្រាបចូលនៃទឹកក្នុងមួយនាទីក្រោមការគ្រប់គ្រងរបស់កសិកម្មអភិរក្ស) |

*<u>ប្រភព៖</u> កំណត់សំគាល់នៃមជ្ឈមណ្ឌលសេវាកម្មកសិកម្មអភិរក្ស នៃនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម ខែកុម្ភៈ ឆ្នាំ ២០២១ Hok et al. (2015; 2018) និង Pheap, Lefèvre et al. (2019)*

## ៣. ក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍កសិកម្មប្រកបដោយនិរន្តរភាព

ឯកសារផែនទីតម្រង់ទិសនេះ ត្រូវបានដឹកនាំដោយគោលដៅអភិវឌ្ឍន៍ជាតិនិងអាទិភាពនានា ហេតុដូច្នេះក៏មានការរួមចំណែកដល់ការសម្រេចបាននូវគោលនយោបាយនិងយុទ្ធសាស្ត្រសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសឯកសារពាក់ព័ន្ធនឹងការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាព ការប្រយុទ្ធប្រឆាំងនឹងការសឹករេចរឹលដី ការអភិរក្សជីវចម្រុះ និងការសម្របខ្លួននិងការកាត់បន្ថយទៅនឹងការផ្លាស់ប្តូរអាកាសធាតុ។ ក្របខ័ណ្ឌគោលនយោបាយចម្បង ដែលពាក់ព័ន្ធនិងសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ត្រូវបានរៀបចំឡើងដោយឯកសារគោលនយោបាយដូចខាងក្រោម៖

- **យុទ្ធសាស្ត្រចតុកោណទី ៤** ប្រកាសពីការប្តេជ្ញាចិត្តជារួមរបស់រាជរដ្ឋាភិបាលក្នុងការ (១) ការអភិវឌ្ឍវិស័យកសិកម្ម ដើម្បីធានាសន្តិសុខស្បៀងនិងផ្លាស់ប្តូរទៅជា" វិស័យប្រពលវប្បកម្មដែលមានផលិតភាពខ្ពស់និងពាណិជ្ជកម្ម" និង (២) និរន្តរភាពបរិស្ថាននិងការត្រៀមខ្លួនដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុក្នុងការលើកកម្ពស់ប្រសិទ្ធភាព "ការប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព ដោយអនុវត្តគោលការណ៍នៃការប្រើប្រាស់និងផលិតកម្មប្រកបដោយនិរន្តរភាព" ។

- **ផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ (NSDP) ឆ្នាំ (២០១៩-២០២៣)** ដាក់ចេញសកម្មភាពអាទិភាពសម្រាប់អាទិភាពសំខាន់ៗនៅក្នុងយុទ្ធសាស្ត្រចតុកោណ ផ្តោតលើការអភិវឌ្ឍវិស័យកសិកម្ម។ ដើម្បីនិយាយពីនេះ បច្ចេកទេសកសិកម្មទំនើបនិងការអភិវឌ្ឍបច្ចេកវិទ្យា គឺជាគន្លឹះក្នុងការបង្កើននិរន្តរភាពនៃបរិមាណផលិតផល គុណភាពនិងការធ្វើពិពិធកម្មប្រកបដោយនិរន្តរភាព ស្របពេលដែលការធ្វើឱ្យប្រសើរឡើងនូវអាហារូបត្ថម្ភ ការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងឆ្លើយតបទៅនឹងតម្រូវការទីផ្សារក្នុងស្រុក តំបន់ និងអន្តរជាតិ។

- **ក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា (CSDGs) ឆ្នាំ (២០១៦-២០៣០)** រួមមានគោលដៅទាក់ទងនឹងសន្តិសុខស្បៀង អាហារូបត្ថម្ភ និងការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព ដែលជួយបង្កើនផលិតភាពនិងផលិតកម្ម ជួយរក្សាប្រព័ន្ធ

អេកូឡូស៊ី និងសមត្ថភាពក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងធ្វើឱ្យប្រសើរឡើងវិញនូវគុណភាពដី (គោលដៅ) ២) និងការប្រើប្រាស់ប្រកបដោយនិរន្តរភាពនៃប្រព័ន្ធអេកូឡូស៊ីនៅលើដី រួមទាំងការគ្រប់គ្រងព្រៃឈើ ការប្រយុទ្ធប្រឆាំងនឹងការសឹករេចរឹលដី និងការបញ្ឈប់នូវការបាត់បង់ជីវៈចម្រុះ (គោលដៅទី ១៥) ។

- **ផែនការអភិវឌ្ឍយុទ្ធសាស្ត្រកសិកម្ម (២០១៩-២០២៣)** គូសបញ្ជាក់ពីគោលបំណងយុទ្ធ សាស្ត្រ ដើម្បីលើកកម្ពស់ទំនើបកម្មកសិកម្ម ការប្រកួតប្រជែង គុណភាព សុវត្ថិភាព អាហារូបត្ថម្ភ ព្រមទាំងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាពនៃដីធ្លី ព្រៃឈើ និងធន ធានជលផល។ ភាពធន់នឹងអាកាសធាតុនិងនិរន្តរភាព ស្ថិតក្នុងចំណោមគោលការណ៍ស្នូល ក្នុងការសម្របសម្រួលនិងកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងបញ្ហាទាក់ទងនឹងធនធាន ដីកសិកម្ម។

- **សេចក្តីព្រាងផែនការមេវិស័យកសិកម្មឆ្នាំ២០៣០** (ដែលនឹងត្រូវបញ្ចប់) រំលឹកឡើងវិញនូវអាទិភាពក្នុងធ្វើឱ្យប្រសើរឡើងផលិតភាពកសិកម្ម ការធ្វើពិពិធកម្ម ប្រពលវប្បកម្ម ការធ្វើទំនើបកម្មនិងពាណិជ្ជកម្ម ដោយរក្សានិរន្តរភាពនៃការផលិតកម្មដំណាំនិងប្រព័ន្ធអេកូឡូស៊ី។

- **កម្មវិធីសកម្មភាពជាតិ (NAP) ដើម្បីប្រយុទ្ធប្រឆាំងនឹងការរេចរឹលដី (២០១៨-២០២៧)** មានគោលបំណងរួមចំណែកក្នុងការការពារនិងដោះស្រាយបញ្ហាសឹករេចរឹលដី ក្រោមកាតព្វកិច្ចនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែក្លាយជាវាលរហោឋាន (UNCCD) ក្នុងគោលបំណងអភិរក្សនិងការពារកសិកម្មអេកូឡូស៊ី។ គោលបំណងយុទ្ធសាស្ត្រមួយក្នុងចំណោមគោលដៅយុទ្ធសាស្ត្រទាំងបួនរបស់កម្មវិធីសកម្មភាពជាតិ ផ្តោតលើការគ្រប់គ្រងដីកសិកម្មប្រកបដោយប្រសិទ្ធភាពនិងនិរន្តរភាព។

- **គោលនយោបាយជាតិស្តី ពីការលូតលាស់បៃតង** (អភិវឌ្ឍន៍ក្នុងឆ្នាំ ២០១៣) សង្កត់ធ្ងន់លើសុខមាលភាពនិងការរស់នៅរបស់ប្រជាជនក្នុងការធ្វើសុខដុមនីយកម្មនៃសុវត្ថិភាពអេកូឡូស៊ី តាមរយៈកំណើននៃការអភិវឌ្ឍបៃតង។ ម៉្យាងវិញទៀត **ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីកំណើនបៃតង (២០១៣-២០៣០)** គូសបញ្ជាក់ពីគោលការណ៍កំណើនបៃតង រួមទាំងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាពនិងប្រសិទ្ធភាព ជាពិសេសសំដៅលើ "កសិកម្មបៃតង" ដើម្បីកាត់បន្ថយការប្រើប្រាស់សារធាតុគីមី "**កសិកម្មអភិរក្ស**" ការកែលម្អគុណភាពដី និងការកាត់បន្ថយសំណឹកដី និង "**កសិកម្មអេកូឡូស៊ី**" ដើម្បីបង្កើនទិន្នផលជាមួយការថយចុះផលប៉ះពាល់អវិជ្ជមានដល់បរិស្ថាន។

- **ផែនការយុទ្ធសាស្ត្រសម្រាប់ការផ្លាស់ប្តូរអាកាសធាតុកម្ពុជា (២០១៤-២០២៣)** គឺជាក្របខ័ណ្ឌថ្នាក់ជាតិ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនិងគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងគោលបំណងផ្លាស់ប្តូរប្រទេសកម្ពុជាឆ្ពោះទៅរកមាគ៌ាអភិវឌ្ឍន៍បៃតងដោយលើកកម្ពស់ការអភិវឌ្ឍកាបូនកម្រិតទាបនិងបច្ចេកវិទ្យា។ គោលបំណងពាក់ព័ន្ធមួយចំនួនរួមមានការលើកកម្ពស់ភាពធន់នៃអាកាសធាតុតាមរយៈការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធផលិតកម្មកសិកម្ម កាត់បន្ថយភាពងាយរងគ្រោះចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការលើកកម្ពស់ការទូទាត់សម្រាប់សេវាកម្មប្រព័ន្ធអេកូឡូស៊ី និងការវិភាគអំពីជម្រើសនៃការបំភាយកម្រិតទាបនិងប្រភពនៃការបញ្ចេញ។

- **ផែនការសកម្មភាពអាទិភាពនៃការប្រែប្រួលអាកាសធាតុសម្រាប់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (២០១៦-២០២០)** បង្ហាញពីសកម្មភាពពាក់ព័ន្ធមួយចំនួន រួមមានការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធកសិកម្មប្រកបដោយនិរន្តរភាព ការលើកកម្ពស់បច្ចេកវិទ្យាឆ្លាតវៃសមស្របនឹងអាកាសធាតុ ដើម្បីបង្កើនផលិតភាពនិងការសម្របខ្លួននិងការកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍប្រព័ន្ធចំណេះដឹងនិងព័ត៌មានវិទ្យា ស្តីពីការប្រែប្រួលអាកាសធាតុនិងការប្រើប្រាស់សេណារីយ៉ូសេដ្ឋកិច្ចសង្គមនិងអាកាសធាតុ រួមបញ្ចូលគ្នាជាគំរូអាកាសធាតុ ការប្រើប្រាស់ដី និងការបង្កើតប្រព័ន្ធគណនេយ្យកាបូនសម្រាប់វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

- **យុទ្ធសាស្ត្រនិងផែនការសកម្មភាពជីវៈចម្រុះជាតិ (NBSAP)** (បង្កើតឡើងក្នុងឆ្នាំ ២០០២ និងធ្វើបច្ចុប្បន្នភាពនៅខែកុម្ភៈឆ្នាំ ២០១៦) ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះជីវៈចម្រុះក្រោមអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីជីវចម្រុះ(UNCBD)។ យុទ្ធសាស្ត្រនិងផែនការសកម្មភាពជីវៈចម្រុះជាតិ រួមមានប្រធានបទ ស្តីពីកសិកម្មប្រកបដោយនិរន្តរភាពនិងផលិតកម្មសត្វ តម្រូវការក្នុងការលើកកម្ពស់ការយល់ដឹងជាសាធាណៈ អំពីតម្លៃនិងសារៈសំខាន់នៃទំនិញ/សេវាកម្ម ដែលផ្តល់ដោយជីវចម្រុះកសិកម្ម ក៏ដូចជាការគាំទ្រក្នុងការស្រាវជ្រាវកំណត់ប្រព័ន្ធកសិកម្មសមស្របបំផុតសម្រាប់ប្រព័ន្ធអេកូឡូស៊ីផ្សេងៗ តាមរយៈការដោះស្រាយ ការគ្រប់គ្រងទឹក ទុនចំណាយលើការប្រើប្រាស់ ការការពារដី ផលិតកម្មគ្រាប់ពូជ ការរួមបញ្ចូលប្រព័ន្ធកសិកម្ម។ល។

- **របាយការណ៍ចូលរួមចំណែករបស់កម្ពុជា** (NDC) ដែលបានធ្វើបច្ចុប្បន្នភាពនៅឆ្នាំ២០២០ ពីរបាយការណ៍ចូលរួមចំណែករបស់កម្ពុជាដំបូងរបស់ខ្លួនក្នុងឆ្នាំ ២០១៥ បង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុនិងការពន្លឿន

ការផ្លាស់ប្តូរទៅជារបៀប នៃការអភិវឌ្ឍប្រកបដោយនិរន្តរភាពនៃការប្រើប្រាស់កាបូនកម្រិតទាបក្រោមគោលការណ៍អនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ។ យោងតាមរបាយការណ៍ធ្វើបច្ចុប្បន្នភាពពីរឆ្នាំដំបូងរបស់កម្ពុជា (BUR) ដែលបានដាក់ជូននៅខែសីហាឆ្នាំ២០២០ វិស័យកសិកម្មតំណាងឱ្យវិស័យបញ្ចេញឧស្ម័នធំជាងគេទី២ (បន្ទាប់ពីព្រៃឈើនិងការប្រើប្រាស់ដីផ្សេងទៀត - FOLU) នៅកម្ពុជា និងជាកត្តាជំរុញដ៏សំខាន់សម្រាប់ការបង្កើនឧស្ម័នផ្ទះកញ្ចក់ (GHG) ការបំភាយឧស្ម័ន គឺជាការអភិវឌ្ឍនៃការដាំដុះស្រូវ ដែលកម្រិតសកម្មភាពនិងការបំភាយឧស្ម័នកើនឡើងក្នុងអត្រា ២.៥ ក្នុងកំឡុងឆ្នាំ ១៩៩៤-២០១៦។ របាយការណ៍ចូលរួមចំណែករបស់កម្ពុជា ដែលបានធ្វើបច្ចុប្បន្នភាព កំណត់គោលដៅកាត់បន្ថយការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យកសិកម្ម ដែលជាការប៉ាន់ប្រមាណថាការកាត់បន្ថយការបំភាយចំនួន ៦,២ លានតោន $CO_2$/ឆ្នាំ ឬ ២៣% នៅឆ្នាំ ២០៣០ (ក្រោមសេណារីយ៉ូ NDC)[5] ។ វិធានការបន្ស៊ាំបន្ថយពាក់ព័ន្ធមួយចំនួនត្រូវបានផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយកម្មវិធីសកម្មភាពជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការសឹករេចរឹលដី (NAP) រួមទាំង" កសិកម្មអភិរក្ស" (សំដៅលើការគ្រប់គ្រងដីកសិកម្មប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព) និងការបញ្ចូលកសិកម្មសរីរាង្គនិងជីកំប៉ុស និងបច្ចេកវិទ្យាដាក់ជីទៅក្នុងដីឱ្យមានប្រសិទ្ធភាព ក៏ដូចជាការលើកកម្ពស់ការផលិតចំណីសត្វ ដើម្បីគាំទ្រដល់ការផលិតគោក្របី។ ម្យ៉ាងវិញទៀតវិធានការបន្សាំនិងការបន្ស៊ាំបន្ថយផ្សេងទៀត រួមមានសកម្មភាពទាក់ទងនឹងការផ្លាស់ប្តូរកសិអេកូឡូស៊ីនៅតំបន់ខ្ពង់រាបខេត្តបាត់ដំបង (សកម្មភាពបន្សាំលេខ១) បង្កើនប្រសិទ្ធភាពនិងនិរន្តរភាពនៃបច្ចេកទេសគ្រប់គ្រង ដីកសិកម្ម (កសិកម្មអភិរក្ស សកម្មភាពកាត់បន្ថយលេខ ២៥) ការធ្វើឱ្យប្រសើរឡើងនូវសេវាកម្មគាំទ្រនិងការពង្រឹងសមត្ថភាពផលិតកម្មដំណាំ ដែលធន់នឹងការប្រែប្រួលអាកាសធាតុនិងការបង្កើតភាពធន់នឹងការប្រែប្រួលអាកាសធាតុលើការផលិតនិងការកែច្នៃដំឡូងមី។ ល។ ហើយយោងទៅលើពាក្យគន្លឹះដូចជាកសិកម្មអភិរក្ស កសិកម្មអាកាសធាតុឆ្លាតវៃ រួមបញ្ចូលទាំងវិធានការចម្រុះគ្រប់គ្រងដំណាំ (IPM) ការអនុវត្តកសិកម្មល្អ (GAP) ការធ្វើកសិកម្មសរីរាង្គ វេទិកាស្រូវអង្ករប្រកបដោយនិរន្តរភាព (SRP) ប្រព័ន្ធប្រពលវប្បកម្មស្រូវតាមគោលការណ៍ធម្មជាតិ (SRI)។ល។

## ៤. ទម្រង់ស្ថាប័ននិងរចនាសម្ព័ន្ធរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា

ដូចដែលបានរៀបរាប់នៅក្នុងផ្នែកមុន ការបង្កើតសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព

---

[5] *ការកាត់បន្ថយការបំភាយប៉ាន់ស្មាន (ជាមួយ FOLU) នៅឆ្នាំ២០៣០ ក្រោមសេណារីយ៉ូ NDC នឹងមានប្រមាណ 64.6 លាន tCO2e ក្នុងមួយឆ្នាំ (កាត់បន្ថយ 41.7% ដែលក្នុងនោះ 59.1% គឺមកពី FOLU)។* (*source: Updated NDC, 2020*).

កម្ពុជា ត្រូវបានផ្តួចផ្តើមឡើងនៅខែសីហាឆ្នាំ២០១៨ ដោយក្រុមនៃបណ្តាអង្គភាព ដែលមានចំណាប់អារម្មណ៍ក្នុងការចូលរួមគ្នានិងចែករំលែក ក្នុងការងារកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ដោយផ្អែកលើការយល់ដឹងនិងខិតខំប្រឹងប្រែងប្រមូលផ្តុំរួមគ្នា ដើម្បីប្រែក្លាយកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងការអនុវត្តកសិកម្មអេកូឡូស៊ី ទៅជាការបណ្តាក់ទុនពាណិជ្ជកម្មនិងត្រូវបានដាក់ក្នុងរបៀបវារៈគោលនយោបាយ។ គោលបំណងទាំងពីរនេះ គឺជាការបំពេញបន្ថែមដល់កិច្ចខិតខំប្រឹងប្រែងដែលមានស្រាប់ នៃការរៀបចំប្រព័ន្ធដាំដំណាំ ការវាយតម្លៃគុណភាពរបស់ដី និងវិស្វកម្មកសិកម្ម ហើយវាក៏លើសពីការកំណត់របស់រាជរដ្ឋាភិបាលកម្ពុជានិងអ្នកអនុវត្តការអភិវឌ្ឍន៍ (beyond the domain of RGC and development practitioners)។ ជាលទ្ធផល ការបង្កើតសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា គឺមានការអះអាងបញ្ជាក់គ្រប់គ្រាន់ក្នុងការដើរតួនាទីនាំមុខគេ ក្នុងការប្រមូលផ្តុំអ្នកពាក់ព័ន្ធទាំងអស់រួមទាំងវិស័យសាធារណៈ វិស័យឯកជន (អ្នកផលិតគ្រាប់ពូជ/អ្នកផ្គត់ផ្គង់ អ្នកផលិតគ្រឿងម៉ាស៊ីន/អ្នកចែកចាយ ស្ថាប័ន ហិរញ្ញវត្ថុជាដើម) កសិករ សហករណ៍កសិកម្ម ស្ថាប័នស្រាវជ្រាវ និងស្ថាប័នអប់រំសិក្សា។ តួនាទីដ៏សំខាន់របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជានេះ នឹងជួយបង្កើតវេទិកាមួយសម្រាប់បណ្តាញអង្គភាព ដែលមានការចាប់អារម្មណ៍លើកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ីរួមគ្នា។ នេះនឹងជួយដោះស្រាយបញ្ហា នៃសកម្មភាពស្ទួនគ្នា ធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងរវាងភាគីពាក់ព័ន្ធ ក្នុងការលើកកម្ពស់ការយល់ដឹងអំពីកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងការអនុវត្តកសិកម្មអេកូឡូស៊ី នឹងទទួលបាននូវប្រភពគាំទ្រចាំបាច់ ដែលនឹងជួយកសិករក្នុងការបង្កើនល្បឿននៃការស្រូបយកបច្ចេកវិទ្យារបស់ពួកគេ។

ចាប់តាំងពីពេលនោះមក គំនិតផ្តួចផ្តើមនេះត្រូវបានពិភាក្សាហើយដំណើរការត្រូវបានគ្រោងទុកដែលឈានទៅដល់ការអនុម័តជាផ្លូវការ របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា តាមសេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ លេខ២០១ សសរ.កសក ចុះថ្ងៃទី២១ ខែឧសភាឆ្នាំ ២០២០ (សូមមើលឧបសម្ព័ន្ធទី ១) និងការបើកដំណើរការជាផ្លូវការនៅខែមិថុនាឆ្នាំ ២០២០ ។

## ៤.១ ចក្ខុវិស័យ

ចក្ខុវិស័យរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា គឺដើម្បីក្លាយជាវេទិកាមួយសម្រាប់លើកកម្ពស់ការងារកសិកម្មអភិរក្សនិងការពង្រឹងនិរន្តរភាព ឈានឆ្ពោះទៅរកការផ្លាស់ប្តូរជាកសិកម្មអេកូឡូស៊ីនៅកម្ពុជានិងអាស៊ីអាគ្នេយ៍។

## ៤.២ បេសកកម្ម

បេសកកម្មរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា គឺសម្របសម្រួលនិងគាំទ្រការស្រាវជ្រាវសម្រាប់ការអភិវឌ្ឍន៍។ វិនិយោគលើការគ្រប់គ្រងចំណេះដឹង បង្កើតបរិយាកាសអំណោយផលសម្រាប់ការសន្ទនាគោលនយោបាយ និងភាពជាដៃគូរវាងរដ្ឋនិងឯកជន ការបង្កើតតម្លៃ និងស្វែងយល់ពីឱកាសទីផ្សារ និងបង្កើនកិច្ចសហការរវាងភាគីពាក់ព័ន្ធផ្សេងៗក្នុងអនុវិស័យកសិកម្មអភិរក្ស ការពង្រឹងនិរន្តរភាព និងអនុវិស័យកសិកម្មអេកូឡូស៊ី។

## ៤.៣ អភិបាលកិច្ចនិងរចនាសម្ព័ន្ធប្រតិបត្តិរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា

សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ត្រូវបានបង្កើតឡើងក្រោមការដឹកនាំរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងគ្រប់គ្រងដោយគណៈកម្មការតម្រង់ទិសដឹកនាំ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមជាមួយសមាជិកមកពីក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងកិច្ចការនារី ក្រសួងធនធានទឹកនិងឧតុនិយម និងសភាពាណិជ្ជកម្មកម្ពុជា ។ គណៈកម្មការតម្រង់ទិស មានតួនាទីសំខាន់ក្នុងការដឹកនាំនិងត្រួតពិនិត្យវឌ្ឍនភាព នៃការងារកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងការអភិវឌ្ឍន៍កសិកម្មអេកូឡូស៊ីនៅកម្ពុជា ដោយមានការទទួលខុសត្រូវចម្បងក្នុងការត្រួតពិនិត្យនិងអនុម័តផែនការសកម្មភាព ថវិកា និងរបាយការណ៍របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា។

នៅកម្រិតអនុវត្ត សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ដឹកនាំដោយគណៈកម្មការប្រតិបត្តិ ដែលមានប្រធានគណៈកម្មការប្រតិបត្តិពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមានតំណាងមកពីសាកលវិទ្យាល័យភូមិន្ទកសិកម្មនិងអគ្គនាយកដ្ឋានកសិកម្មជាអនុប្រធាន និងមានសមាជិកមកពីនាយកដ្ឋានវិស្វកម្មកសិកម្ម នាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍកសិកម្មកម្ពុជា នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អង្គការស៊ីសខនថាក់ និងមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD)។ ការទទួលខុសត្រូវចម្បងរបស់គណៈកម្មការប្រតិបត្តិ គឺត្រូវអភិវឌ្ឍនិងតាមដានការអនុវត្តផែនការសកម្មភាព ផ្តល់ដំបូន្មាន និងជួយសម្រួលរាល់សកម្មភាពពាក់ព័ន្ធការងារកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងសកម្មភាពទាក់ទងទៅនឹងកសិកម្មអេកូឡូស៊ី ទំនាក់ទំនងនិងសហការជាមួយទីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធ ដៃគូអភិវឌ្ឍ វិស័យឯកជន និងអ្នកពាក់ព័ន្ធដ៏ទៃទៀតនៅក្នុងការងារកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងការអន្តរាគមន៍ទាក់ទងនឹងកសិកម្មអេកូឡូស៊ី។

រូបទី២៖ រចនាសម្ព័ន្ធរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា




គណៈកម្មការប្រតិបត្តិសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ត្រូវបានគាំទ្រដោយលេខាធិការដ្ឋាន ដែលជួយនឹងគាំទ្រដល់ការងារប្រតិបត្តិការរួមរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា និងការសម្របសម្រួលផ្ទៃក្នុងទូទាំងជាមួយអនុគណៈកម្មការចំនួន ៤ គឺ (១) គ្រប់គ្រងចំណេះដឹង (២) សម្របសម្រួលនិងបណ្តាញ (៣) លើកកម្ពស់កសិកម្មអភិរក្ស និង ( ៤) ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍។ អនុគណៈកម្មការនីមួយៗ ត្រូវបានដឹកនាំដោយអង្គភាពរដ្ឋាភិបាលផ្សេងៗគ្នា និងសហការដឹកនាំ/គាំទ្រដោយវិស័យឯកជនឬអង្គការអភិវឌ្ឍន៍។ អនុគណៈកម្មការនីមួយៗមានតួនាទីនិងការទទួលខុសត្រូវជាក់លាក់ (ដូចបានរៀបរាប់ខាងក្រោម) សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ជួយនិងគាំទ្រសមាជិកអនុគណៈកម្មការរបស់ខ្លួនហើយមិនអនុវត្តសកម្មភាពណាមួយក្រោមតួនាទីនិងភារកិច្ចរបស់អនុគណៈកម្មការរបស់ខ្លួនឡើយ។

- **អនុគណៈកម្មការគ្រប់គ្រងចំណេះដឹង** (Sub-committee on Knowledge Manageme) ដឹកនាំដោយមជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាពនិងអាហារូបត្ថម្ភ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ទទួលខុសត្រូវក្នុងការបង្កើតឃ្លាំងទិន្នន័យ ព័ត៌មាន និងចំណេះដឹងពាក់ព័ន្ធទាក់ទងនឹងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងកសិកម្មអេកូឡូស៊ី ព្រមទាំងមជ្ឈមណ្ឌលច្រកចេញចូលតែមួយ សម្រាប់អ្នកពាក់ព័ន្ធក្នុងការចូលប្រើឃ្លាំងទិន្នន័យបែបនេះ។
- **អនុគណៈកម្មការសម្របសម្រួលនិងបណ្តាញ** (Sub-committee on Coordination and Networking) ដឹកនាំដោយនាយកដ្ឋានវិស្វកម្មកសិកម្ម ដោយមានការគាំទ្រពីអង្គការស៊ើស

ខនថាក់ ទទួលខុសត្រូវក្នុងការកំណត់អត្តសញ្ញាណនិងការភ្ជាប់ទំនាក់ទំនងទៅនឹងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងអ្នកពាក់ព័ន្ធ តួអង្គទីផ្សារ ដើម្បីប្រមូលផ្តុំនូវធនធានដែលមានទាំងអស់ ដែលនឹងជួយពង្រឹងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងការអភិវឌ្ឍកសិកម្មអេកូឡូស៊ី។

- **អនុគណៈកម្មការលើកកម្ពស់កសិកម្មអភិរក្ស** (Sub-committee on Promotion) ដឹកនាំដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការគាំទ្រពីអង្គការស្វីសខនថាក់ ទទួលខុសត្រូវចំពោះសកម្មភាព ដែលនឹងគាំទ្រដល់ការស្រាវជ្រាវ ការបណ្តុះបណ្តាលនិងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ទាក់ទងនឹងការគាំទ្រជាក់ស្តែងនៅសហគមន៍នៅមូលដ្ឋាន។
- **អនុគណៈកម្មការស្រាវជ្រាវដើម្បីអភិវឌ្ឍន៍** (Sub-committee on Research for Development) សហការដឹកនាំដោយនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្មនិងមជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD) ទទួលខុសត្រូវក្នុងការប្រមូលផ្តុំអង្គការស្រាវជ្រាវជាច្រើន ដែលសកម្មក្នុងអនុវិស័យកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី (ប្រព័ន្ធដាំដំណាំ ដំណាំគម្របដី គ្រឿងយន្តកសិកម្ម និងការគ្រប់គ្រងទឹក) ដើម្បីធ្វើឱ្យប្រសើរឡើងនៃការមើលឃើញលើចំណេះដឹង វិទ្យាសាស្ត្រ និងនាំមកនូវភស្តុតាងផ្អែកលើវិទ្យាសាស្ត្រ ដើម្បីគាំទ្រដល់ការសន្ទនាគោលនយោបាយ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងបរិស្ថាន និងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព) និងការចូលរួមរបស់វិស័យឯកជន និងដើម្បីគាំទ្រការធ្វើឱ្យប្រសើរឡើងនូវហេដ្ឋារចនាសម្ព័ន្ធនិងធនធាននៅស្ថានីយបុសខ្នុរ។

លើសពីនេះគណៈកម្មការប្រតិបត្តិ ក៏ទទួលបានការគាំទ្រពីអង្គភាពបង្អែក/ទ្រទ្រង់បច្ចេកទេស (Technical Reference and Support Unit) ដែលនឹងមានអ្នកជំនាញនិងអ្នកអាជីព មកពីបណ្តាអង្គការផ្សេងៗជាច្រើន។ អង្គការមួយចំនួន ដែលនឹងត្រូវស្នើសុំឱ្យចូលរួមក្នុងអង្គភាពនេះរួមមាន មជ្ឈមណ្ឌលស្រាវជ្រាវកសិកម្មបារាំងសម្រាប់ការអភិវឌ្ឍអន្តរជាតិ (CIRAD ) អង្គការស្វីសខនថាក់ សហព័ន្ធកសិកម្មអភិរក្សអឺរ៉ុប (ECAF) សមាគមកសិកម្មអភិរក្សសហរដ្ឋអាមេរិក មជ្ឈមណ្ឌលកែលម្អពោតនិងស្រូវសាលីអន្តរជាតិ (CIMMYT) អង្គការស្បៀងអាហារនិងកសិកម្ម នៃអង្គការសហប្រជាជាតិ (FAO) មជ្ឈមណ្ឌលគ្រឿងយន្តកសិកម្មសមស្រប នៃអង្គការសហប្រជាជាតិ (UN CSAM) វិទ្យាស្ថានចិនសម្រាប់ការអភិរក្សភ្ជួររាស់ដី (CICT)។ល។ ផ្ទុយទៅវិញ សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា នៅតែមានទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍសំខាន់ៗរួមមាន ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍន៍ (AFD) ទីភ្នាក់ងារជំនួយអាមេរិកសម្រាប់ការអភិវឌ្ឍន៍អន្តរជាតិ (USAID) ទីភ្នាក់ងារស្វីសសម្រាប់ការអភិវឌ្ឍនិងសហប្រតិបត្តិការ (SDC) សហភាពអឺរ៉ុប (EU) អង្គការស្បៀង

អាហារនិងកសិកម្ម នៃអង្គការសហប្រជាជាតិ (FAO) និងមជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ (ACIAR) ជាដើម ដែលបានសកម្មក្នុងការគាំទ្រកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងការអភិវឌ្ឍកសិអេកូឡូស៊ីនៅកម្ពុជានិងតំបន់។

## ៥. ការវិភាគ SWOT នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា

ការវិភាគអំពី "ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស និងការគម្រាមកំហែង" (SWOT) របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ត្រូវបានធ្វើឡើងដោយមានអ្នកពាក់ព័ន្ធមួយចំនួន រួមមានទាំងសមាជិកខាងក្នុង នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា និងអ្នកពាក់ព័ន្ធខាងក្រៅ ដូចជាដៃគូអភិវឌ្ឍ វិស័យឯកជន និងក្រុមអ្នកជំនាញ។ ការវិភាគ SWOT (បង្ហាញខាងក្រោម) រួមមានការពិនិត្យផ្ទៃក្នុងអំពីចំណុចខ្លាំងនិងចំណុចខ្សោយ របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា និងទិដ្ឋភាពទូទៅតាមវិស័យ នៃឱកាសនិងការគំរាមកំហែង។ ការវិភាគនេះ ដាក់ចេញជាមូលដ្ឋានសំខាន់សម្រាប់អាទិភាពនៃការអភិវឌ្ឍឯកសារផែនទីតម្រង់ទិសរយៈពេល ៥ ឆ្នាំរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា។

**តារាងលេខ៣៖ ការវិភាគ SWOT របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា**

| ភាពខ្លាំង | ភាពខ្សោយ |
|---|---|
| • ការស្រាវជ្រាវយូរអង្វែងដើម្បីអភិវឌ្ឍការស្រាវជ្រាវនៅក្នុង CA & SI និងកសិកម្មអេកូឡូស៊ីនៅក្នុងប្រទេសនិងតំបន់ ទាំងនៅស្ថានីយ៍បុស្សខ្នុរ និងដោយមានការគាំទ្រពីកសិដ្ឋាន។<br>• ការយល់ព្រមជាផ្លូវការពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូច្នេះវាជាភាពជាម្ចាស់របស់រាជរដ្ឋាភិបាល។<br>• ផ្សំឡើងពីភាពខ្លាំង នៃគណៈកម្មការតម្រង់ទិសនិងគណៈកម្មការប្រតិបត្តិដ៏រឹងមាំ មកពីភ្នាក់ងាររដ្ឋាភិបាលពាក់ព័ន្ធនឹងអង្គភាពសិក្សាស្រាវជ្រាវ អង្គភាពអប់រំ/វិទ្យាស្ថានស្រាវជ្រាវ អង្គការក្រៅរដ្ឋាភិបាល និងសភាពាណិជ្ជកម្ម។ | • មិនមានគម្រូនិរន្តរភាពប្រតិបត្តិការច្បាស់លាស់ទេ ព្រោះ CASIC គឺជាវេទិកាមិនមែនជាអង្គការទេ<br>• ភាពមើលឃើញមានកម្រិត នៃ CA & SI និង/ឬកសិកម្មអេកូឡូស៊ី នៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ទោះបីជាមានអាទិភាពទូទៅលើការអភិវឌ្ឍកសិកម្មប្រកបដោយនិរន្តរភាពក៏ដោយ<br>• អវត្តមាននៃផែនការមេ ក្នុងការចង្អុលបង្ហាញនិងការអភិវឌ្ឍ CA & SI កសិកម្មអេកូឡូស៊ី<br>• ដំណាក់កាលដំបូង នៃការកៀរគរអ្នកពាក់ព័ន្ធ ក្នុងការសម្របសម្រួល និងការចូលរួម<br>• កង្វះខាតហិរញ្ញវត្ថុនិងធនធានមនុស្សដែលគាំទ្រកិច្ចខិតខំប្រឹងប្រែងដល់ការអភិវឌ្ឍនិង |

| | |
|---|---|
| • បង្កើតក្រុមអ្នកជំនាញដែលមានចំណេះដឹង និងសមត្ថភាពបច្ចេកទេសក្នុង CA & SI និង តំបន់កសិកម្មអេកូឡូស៊ី ដែលមានស្រាប់។<br>• ការការចូលរួមយ៉ាងរឹងមាំនៃបណ្ដានាយកដ្ឋានក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (រួមទាំងការគាំទ្រដ៏មានសក្ដានុពលពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ដើម្បីគាំទ្រដល់ការលើកកម្ពស់និងផ្សព្វផ្សាយ CA & SI និង កសិកម្មអេកូឡូស៊ីឲ្យកាន់តែទូលំទូលាយ។ | ការលើកកម្ពស់កាន់តែទូលាយដល់ CA & SI និងកសិកម្មអេកូឡូស៊ី<br>• កង្វះការវាយតម្លៃតំបន់សម្រាប់តំបន់អាទិភាពសមស្របសម្រាប់ CA & SI និងការអនុវត្តកសិកម្មអេកូឡូស៊ី<br>• កង្វះប្រព័ន្ធព័ត៌មាន តាមដានវឌ្ឍនភាពរបស់ CA & SI និងកសិកម្មអេកូឡូស៊ី។ |
| **ឱកាស** | **ការគម្រាមកំហែង** |
| • ការបង្កើនការចំណាប់អារម្មណ៍និងការគាំទ្រពីដៃគូអភិវឌ្ឍន៍និងគំនិតផ្តួចផ្តើម/កម្មវិធីតំបន់ក្នុងអនុវិស័យកសិកម្មអេកូឡូស៊ី<br>• ការទទួលយក CA & SI និងកសិកម្មអេកូឡូស៊ី ដោយកសិករបង្ហាញលទ្ធផលគួរឱ្យជឿជាក់នៃការអនុវត្តកសិកម្មនិងសេដ្ឋកិច្ច<br>• នវានុវត្តន៍ នៃដំណើរការផ្លាស់ប្តូរឆ្ពោះទៅរកកសិកម្មអេកូឡូស៊ី<br>• ផលប៉ះពាល់ជាវិជ្ជមានរបស់ CA & SI និងការអនុវត្តកសិកម្មអេកូឡូស៊ី លើដីកាបូន ប្រសិទ្ធភាពនៃការប្រើប្រាស់ទឹក ការសម្របខ្លួន និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ (ការបំភាយឧស្ម័នផ្ទះកញ្ចក់)។<br>• ការបង្កើនប្រាក់ចំណូលនិងចំណាប់អារម្មណ៍របស់អ្នកប្រើប្រាស់ចំពោះផលិតផលកសិកម្មប្រកបដោយសុវត្ថិភាព។ | • ការយល់ដឹងតិចតួចអំពី CA និង SI ក្នុងចំណោមកសិករ វិស័យឯកជន និងអ្នកពាក់ព័ន្ធដទៃទៀត រួមទាំងការយល់ច្រឡំអំពីការអនុវត្ត CA និង SI<br>• និន្នាការបញ្ចៀសហានិភ័យនិងអាកប្បកិរិយារង់ចាំមើលរបស់កសិករដែលរារាំងការអនុម័តដំបូង ដើម្បីផ្លាស់ប្តូរទៅ CA & SI និងការអនុវត្តកសិកម្មអេកូឡូស៊ី<br>• កង្វះយន្តការហិរញ្ញវត្ថុ (វិញ្ញាបនប័ត្រ ស្លាកទីផ្សារកាបូន និង PES) ដើម្បីផ្តល់រង្វាន់ដល់កសិករ ដែលវិនិយោគលើការកែលម្អដីនិងតួអង្គទីផ្សារក្នុងការគាំទ្រដល់ដំណើរការផ្លាស់ប្តូរ។<br>• ការចូលរួមមានកំណត់ ពីវិស័យឯកជនតាមខ្សែច្រវាក់ផ្គត់ផ្គង់និងហិរញ្ញប្បទានដើម្បីជួយសម្រួលនិងពន្លឿនការទទួលយក CA និង SI ដោយកសិករ។ |

## ៦. ផែនទីតម្រង់ទិសរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា សម្រាប់ឆ្នាំ ២០២២-២០២៦

### ៦.១ គោលបំណងរួម

គោលនយោបាយពាក់ព័ន្ធសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា ចក្ខុវិស័យ និងបេសកកម្ម របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជានិងការវិភាគ SWOT បង្កើតទិសដៅយុទ្ធសាស្ត្រនិងអាទិភាពនៃផែនទីតម្រង់ទិសរយៈពេល៥ឆ្នាំ របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា។ ជាលទ្ធផលគោលបំណងរួមរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា សម្រាប់ឆ្នាំ ២០២២-២០២៦ **គឺពង្រឹងការសម្របសម្រួលនិងគាំទ្រភាគីពាក់ព័ន្ធក្នុងគោលបំណងលើកកម្ពស់អនុវិស័យកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនៅកម្ពុជា ដើម្បីឈានទៅរកការធ្វើទំនើបកម្មកសិកម្មនិងការផ្លាស់ប្តូរឆ្ពោះទៅរកកសិកម្មអេកូឡូស៊ី។**

ជាមួយនឹងគោលបំណងរួមនេះ សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា តាមរយៈការអនុវត្តសកម្មភាពដោយអនុគណៈកម្មការរបស់ខ្លួន មានបំណងសម្រេចបាននូវគោលដៅសំខាន់ៗនៅត្រឹមឆ្នាំ២០២៦៖

- ការគ្របដណ្តប់កាន់តែទូលំទូលាយ នៃកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងការយល់ដឹងអំពីកសិកម្មអេកូឡូស៊ី ការអប់រំ និងកិច្ចខិតខំប្រឹងប្រែងពង្រីកទៅដល់កសិករនិងអ្នកពាក់ព័ន្ធ។
- បង្កើនផ្ទៃដីកសិកម្មក្រោមការអនុវត្តពេញលេញឬដោយផ្នែកកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព
- ការកំណត់អាទិភាពតំបន់ដីកសិកម្មសម្រាប់កម្មវិធីអនុវត្តកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី
- សមាហរណកម្មកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ចូលទៅក្នុងរបៀបវារៈគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា (រួមទាំងគោលនយោបាយយុទ្ធសាស្ត្រនិងផែនការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ) កាន់តែរឹងមាំថែមទៀត ។

### ៦.២ គោលបំណងយុទ្ធសាស្ត្រ

ដើម្បីសម្រេចបាននូវគោលបំណងរួមនេះ សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជាកំណត់គោលបំណងយុទ្ធសាស្ត្រសំខាន់បី ដែលមានទំនាក់ទំនងនិងគាំទ្រគ្នាទៅវិញទៅមក៖

១. ពង្រឹងសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា និងសម្របសម្រួលជាមួយនឹងភាគីពាក់ព័ន្ធ

២. បង្កើនចំណេះដឹងនិងការស្រាវជ្រាវ លើកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី

៣. ធ្វើឱ្យប្រសើរឡើងនិងពង្រីកសេវាកម្មកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិង កសិកម្មអេកូឡូស៊ី

នៅក្រោមគោលដៅយុទ្ធសាស្ត្រនីមួយៗ មានលទ្ធផលរំពឹងទុកនិងសកម្មភាពអាទិភាពមួយចំនួន។ ដោយសារសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា មិនអនុវត្តសកម្មភាពណាមួយ ឡើយ ប៉ុន្តែសម្របសម្រួលសកម្មភាពតាងនាមឱ្យនាមសមាជិករបស់ខ្លួន។ សកម្មភាពដែលបាន រៀបរាប់នៅក្នុងផ្នែក ៦.៣ - ៦.៦ ត្រូវបានអនុវត្តជាចម្បងដោយសមាជិករបស់ខ្លួន។ ទោះជាយ៉ាង ណាក៏ដោយ មានសកម្មភាពមួយចំនួន ដែលនឹងអនុវត្តដោយលេខាធិការដ្ឋាន នៃសម្ព័ន្ធកសិកម្ម អភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជាផងដែរ។

រូបទី៣៖ គោលបំណងនិងលទ្ធផលរំពឹងទុកនៃផែនទីតម្រង់ទិសរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជាសម្រាប់ឆ្នាំ ២០២២-២០២៦



## ៦.៣ គោលបំណងយុទ្ធសាស្ត្រទី១៖ សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជានិងភាគីពាក់ព័ន្ធត្រូវបានពង្រឹងនិងសម្របសម្រួល

គោលបំណងយុទ្ធសាស្ត្រនេះ មានគោលដៅពង្រឹងសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជានិងសមាជិករបស់ខ្លួន ដើម្បីគាំទ្រសកម្មភាពរបស់អនុគណៈកម្មការជំរុញកិច្ចសន្ទនាគោលនយោបាយសម្រាប់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកាន់តែច្រើន និងការធ្វើសមាហរណកម្ម/ស្រូបយកកសិកម្មអេកូឡូស៊ី ដោយអ្នកបង្កើតគោលនយោបាយ ដើម្បីធ្វើឱ្យកិច្ចសហប្រតិបត្តិការក្នុងតំបន់កាន់តែស៊ីជម្រៅនិងធានានិរន្តរភាពហិរញ្ញវត្ថុ។ លទ្ធផលរំពឹងទុកចំនួនបួននឹងត្រូវបានគាំទ្រដោយសកម្មភាពអាទិភាពមួយចំនួន ដូចរៀបរាប់ខាងក្រោម។

**តារាងទី៤៖ សកម្មភាពអាទិភាពនៅក្រោមគោលបំណងយុទ្ធសាស្ត្រទី១**

| លទ្ធផលរំពឹងទុក | សកម្មភាពអាទិភាព |
|---|---|
| ១.១ សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ត្រូវបានពង្រឹងនិងផ្តល់ការគាំទ្រដល់អនុគណៈកម្មការ | ១.១.១ ធ្វើការប្រជុំជាទៀងទាត់ជាមួយគណៈកម្មការតម្រង់ទិសគណៈកម្មការប្រតិបត្តិ និងអនុគណៈកម្មការ ដើម្បីពិភាក្សាលើវឌ្ឍនភាព បញ្ហាប្រឈម និងការគាំទ្រចាំបាច់។ |
| | ១.១.២ រៀបចំដំណើរទស្សនកិច្ចសម្រាប់គណៈកម្មការតម្រង់ទិសគណៈកម្មការប្រតិបត្តិ និងអនុគណៈកម្មការ ព្រមទាំងអ្នកពាក់ព័ន្ធដទៃទៀត |
| ១.២ កិច្ចសន្ទនានយោបាយត្រូវបានពង្រឹង សម្រាប់ការធ្វើសមាហរណកម្មកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី និងការទទួលយក | ១.២.១ ធ្វើនិងបង្ហាញពីការវាយតម្លៃផលប៉ះពាល់សេដ្ឋកិច្ចរបស់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងការអនុម័តលើអនុវិស័យកសិកម្មអេកូឡូស៊ី ដល់អ្នកបង្កើតគោលនយោបាយតាមរយៈសេចក្តីសង្ខេបគោលនយោបាយ |
| | ១.២.២ រៀបចំវេទិកាថ្នាក់ជាតិរដ្ឋនិងឯកជន ជាមួយអ្នកបង្កើតគោលនយោបាយពាក់ព័ន្ធវិស័យឯកជន និងដៃគូអភិវឌ្ឍន៍ |
| | ១.២.៣ បន្តធ្វើការជាមួយលេខាធិការដ្ឋាន នៃកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងការរេចរឹលដីធ្លី (NAP) ដើម្បីបំពេញបន្ថែម<br>កិច្ចខិតខំប្រឹងប្រែងនិងសកម្មភាពរួមគ្នា ដើម្បីប្រយុទ្ធប្រឆាំងការរេចរឹលដីកសិកម្ម |
| | ១.២.៤ ជាសេនាធិការឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីរួមបញ្ចូលកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិង |

| | |
|---|---|
| | កសិកម្មអេកូឡូស៊ី ទៅក្នុងគោលនយោបាយយុទ្ធសាស្ត្រនិងផែនការទាក់ទងនឹងវិស័យកសិកម្ម |
| | ១.២.៥ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គនាយកដ្ឋានកសិកម្ម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីទទួលបានការចូលរួមពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្នុងការអនុវត្តកម្មវិធីផ្សព្វផ្សាយរបស់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី |
| | ១.២.៦ បង្កើតកិច្ចសហប្រតិបត្តិការជាមួយក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយភ្ជាប់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ជាមួយផែនការសកម្មភាពនិងយុទ្ធសាស្ត្រជីវៈចម្រុះជាតិនិងរបាយការណ៍ចូលរួមចំណែករបស់កម្ពុជា តាមរយៈការពិគ្រោះយោបល់ទ្វេភាគី ផ្អែកលើលទ្ធផលការស្រាវជ្រាវនិងការរួមបញ្ចូលគោលនយោបាយ |
| | ១.២.៧ ទំនាក់ទំនងជាមួយវេទិការកិច្ចសន្ទនាគោលនយោបាយដែលមានស្រាប់ដូចជាក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម កិច្ចសន្ទនាថ្នាក់ជាតិ ស្តីពីប្រព័ន្ធស្បៀងប្រកបដោយនិរន្តរភាព។ល។ |
| ១.៣ កិច្ចសហការក្នុងតំបន់ត្រូវបានរក្សានិងពង្រឹងជាមួយលទ្ធភាពទទួលបានរបស់ក្រុមអ្នកជំនាញ | ១.៣.១ រក្សាកិច្ចសហប្រតិបត្តិការក្នុងតំបន់នាពេលបច្ចុប្បន្នជាមួយ ASEA ALiSEA និង UN-CSAM រួមទាំង R4D រៀបចំការបណ្តុះបណ្តាលថ្នាក់តំបន់ (នៅស្ថានីយ៍បុសខ្នុរ និងតំបន់ផ្សព្វផ្សាយនានាដែលមានសក្តានុពល ប្រែក្លាយជាមជ្ឈមណ្ឌលបណ្តុះបណ្តាលថ្នាក់តំបន់) គំនិតផ្តួចផ្តើមតស៊ូមតិរួមគ្នានៅថ្នាក់តំបន់។ល។ |
| | ១.៣.២ រួមបញ្ចូលក្រុមអ្នកជំនាញ ដើម្បីគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពបច្ចេកទេសរបស់សមាជិកនិងដៃគូរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា |
| | ១.៣.៣ រៀបចំសិក្ខាសាលា ការបណ្តុះបណ្តាល សន្និសីទថ្នាក់តំបន់ ក្នុងកិច្ចសហការជាមួយបណ្តាញក្នុងតំបន់ និង/ឬ ដៃគូរ |

| | |
|---|---|
| ១.៤ និរន្តរភាពហិរញ្ញវត្ថុទទួលបាន | ១.៤.១ បង្កើតយុទ្ធសាស្ត្រឧបត្ថម្ភ ផ្តោតលើកញ្ចប់យុទ្ធសាស្ត្រសម្រាប់ការរៃអង្គាសថវិកាតាមព្រឹត្តិការណ៍ |
| | ១.៤.២ ស្វែងយល់ពីយន្តការហិរញ្ញវត្ថុដែលមានស្រាប់និងថ្មី ជាមួយទីភ្នាក់ងាររដ្ឋាភិបាល វិស័យឯកជន និងដៃគូអភិវឌ្ឍន៍នានា ដើម្បីគាំទ្រដល់អនុគណៈកម្មាការ ក្នុងការអនុវត្តសកម្មភាពជាអាទិភាព |
| | ១.៤.៣ រក្សាការចូលរួមចំណែកពីស្ថាប័នដោយស្ម័គ្រចិត្តពីគណៈកម្មការតម្រង់ទិសនិងគណៈកម្មការប្រតិបត្តិ ក្នុងរយៈពេលជាច្រើនឆ្នាំដើម្បីគាំទ្រដល់ប្រតិបត្តិការរួមរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា |
| | ១.៤.៤ សិក្សារចនាសម្ព័ន្ធសមាជិកភាពនិងអត្ថប្រយោជន៍ ជាពិសេសលទ្ធភាពក្នុងការអនុវត្តនៅដំណាក់កាលបន្តទៀត នៃការអភិវឌ្ឍរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា។ |

## ៦.៤ គោលបំណងយុទ្ធសាស្ត្រទី២៖ ចំណេះដឹងនិងការស្រាវជ្រាវលើកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងកសិកម្មអេកូឡូស៊ី ត្រូវបានលើកកម្ពស់

គោលបំណងយុទ្ធសាស្ត្រនេះ មានគោលបំណងលើកកម្ពស់ការគ្រប់គ្រងចំណេះដឹងនិងការស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍លើបច្ចេកវិទ្យានិងការច្នៃប្រឌិតដែលទាក់ទងនឹងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ដើម្បីងាយស្រួលនឹងសម្របខ្លួនដោយភាគីពាក់ព័ន្ធ។ លើសពីនេះអនុគណៈកម្មការនីមួយៗនឹងត្រូវពង្រឹងដើម្បីកៀរគរសមាជិកនិងដៃគូរ ដើម្បីចូលរួមជាមួយសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា។ លទ្ធផលរំពឹងទុកចំនួន៤ នឹងសម្រេចបានដោយអនុវត្តសកម្មភាពដូចខាងក្រោម។

**តារាងទី ៥៖ សកម្មភាពអាទិភាពក្រោមគោលបំណងយុទ្ធសាស្ត្រ ២**

| លទ្ធផលរំពឹងទុក | សកម្មភាពអាទិភាព |
|---|---|
| ២.១ លទ្ធផលស្រាវជ្រាវចងក្រងជាមួយវិធីសាស្ត្រផ្ទេរ | ២.១.១ បង្កើតកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងមូលដ្ឋានទិន្នន័យកសិកម្មអេកូឡូស៊ី (ឬប្រព័ន្ធគ្រប់គ្រងចំណេះដឹង) ដោយប្រើបញ្ជីឈ្មោះ នៃអ្នកពាក់ព័ន្ធ |

| | |
|---|---|
| បច្ចេកវិទ្យាសម្រាប់អ្នកទស្សនា/អ្នកស្តាប់គោលដៅ | ២.១.២ បង្កើតឯកសារបច្ចេកទេសនិងសម្ភារៈអប់រំ ដើម្បីចងក្រងឯកសារនិងសម្រួលលទ្ធផលស្រាវជ្រាវសម្រាប់ការបណ្តុះបណ្តាលនិងគោលបំណងសិក្សា (ក្នុងកិច្ចសហការជាមួយអនុគណៈកម្មការដទៃទៀត) |
| | ២.១.៣ ចែករំលែកព័ត៌មានតាមរយៈវេទិកាផ្សេងៗគ្នារបស់រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងបណ្តាញក្នុងតំបន់ និងតាមរយៈការធ្វើទស្សនកិច្ច/ការធ្វើបទបង្ហាញ ក៏ដូចជាសន្និសីទជាតិនិងអន្តរជាតិ (ភ្ជាប់យ៉ាងជិតស្និទ្ធជាមួយមុខងារផ្សព្វផ្សាយ)។ |
| | ២.១.៤ គាំទ្រការធ្វើសមាហរណកម្មកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ទៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិនៃគ្រឹះស្ថានឧត្តមសិក្សា ដែលផ្តល់ជូនមុខជំនាញកសិកម្មនិងបរិស្ថាននិងកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី។ |
| ២.២ ស្រាវជ្រាវអំពីប្រព័ន្ធកសិកម្មអេកូឡូស៊ីនិងបច្ចេកវិទ្យាថ្មីៗ ដើម្បីឆ្លើយតបទៅនឹងភាពធន់នឹងអាកាសធាតុ និងការជំរុញសេដ្ឋកិច្ច | ២.២.១ យន្តការគាំទ្រដើម្បីកំណត់អាទិភាពស្រាវជ្រាវនិងបន្តការស្រាវជ្រាវលើប្រព័ន្ធដាំដុះប្រកបដោយភាពច្នៃប្រឌិត ការប្រមូលកាបូនដី ការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ការកែលម្អដី បច្ចេកវិទ្យាថ្មី (ដើម្បីធ្វើឱ្យប្រសើរឡើងនូវទិន្នផល ដើម្បីឱ្យមានភាពធន់នឹងសត្វល្អិតនិងអាកាសធាតុ ដើម្បីឱ្យមានកម្លាំងពលកម្ម/ទឹកប្រកបដោយប្រសិទ្ធភាព និងត្រូវបានតម្រង់ទិសទៅរកការអនុវត្តកសិកម្មល្អ ស្តង់ដារសរីរាង្គ និងស្តង់ដារសុវត្ថិភាពផ្សេងទៀត។ ល។ ) និងការស្រាវជ្រាវ/ការសិក្សាពាក់ព័ន្ធផ្សេងទៀត។ |
| | ២.២.២ គាំទ្រការស្រាវជ្រាវ ការអភិរក្ស និងការចែករំលែកផលិតផលដំណាំសំខាន់និងដំណាំគម្របដី ធនាគារហ្សែនដំណាំ។ |
| | ២.២.៣ គាំទ្រការធ្វើតេស្ត/ការសម្របខ្លួន នៃគ្រឿងយន្តកសិកម្មសមស្រប ផ្អែកលើទេសភាព (landscapes) ក្នុងស្រុកនិងតំបន់។ |
| | ២.២.៤ គាំទ្រដល់ការធ្វើឲ្យប្រសើរឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធនិងធនធាននៅស្ថានីយ៍បុសខ្នុរ មជ្ឈមណ្ឌលស្រាវជ្រាវពាក់ព័ន្ធ និងសាកលវិទ្យាល័យផ្សេងទៀត។ |
| ២.៣ ការកំណត់តំបន់យុទ្ធសាស្ត្រជាអាទិភាពសម្រាប់កសិកម្មអភិរក្សនិងប្រពល | ២.៣.១ ធ្វើការវាយតម្លៃតំបន់ដីកសិកម្ម ដើម្បីសម្រួលដល់ការលើកកម្ពស់ការអនុវត្តន៍បច្ចេកវិទ្យាប្រកបដោយភាពសមស្របនិង |

| | |
|---|---|
| វប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី | ប្រសិទ្ធភាពនៅក្នុងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងកសិកម្មអេកូឡូស៊ី។ |

## ៦.៥ គោលបំណងយុទ្ធសាស្ត្រទី ៣៖ សេវាកម្មកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ីមានភាពប្រសើរឡើងនឹងត្រូវបានពង្រឹក

គោលបំណងយុទ្ធសាស្ត្រនេះ មានបំណងធ្វើឱ្យប្រសើរឡើងនូវសេវាកម្ម ដែលទាក់ទងទៅនឹងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី តាមរយៈគំរូម៉ូដែលពង្រីកការលើកកម្ពស់ការយល់ដឹងក្នុងចំណោមភាគីពាក់ព័ន្ធ និងការវិនិយោគពីវិស័យឯកជន ដើម្បីគាំទ្រនិងពន្លឿនដំណើរការផ្លាស់ប្តូររបស់កសិករ។ លទ្ធផលរំពឹងទុកចំនួនបីនិងសកម្មភាពមួយចំនួន ត្រូវបានគូសបញ្ជាក់នៅក្នុងតារាងខាងក្រោម។

**តារាងទី ៦៖ សកម្មភាពអាទិភាពក្រោមគោលបំណងយុទ្ធសាស្ត្រ ៣**

| លទ្ធផលរំពឹងទុក | សកម្មភាពអាទិភាព |
|---|---|
| ៣.១ គំរូម៉ូដែលប្រកបដោយភាពច្នៃប្រឌិតត្រូវបានផ្សព្វផ្សាយ | ៣.១.១៖ ផ្សព្វផ្សាយគំរូម៉ូដែល (ប្រព័ន្ធដែលមានស្រាប់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ដើម្បីភ្ជាប់អ្នកពាក់ព័ន្ធផ្សេងៗ (មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សហករណ៍កសិកម្ម អ្នកផ្តល់សេវាកម្មក្នុងស្រុក និងកសិករឈានមុខ) ដើម្បីគាំទ្រដល់ការផ្ទេរចំណេះដឹងនិងបច្ចេកវិទ្យាដល់កសិករ។ |
| | ៣.១.២៖ គាំទ្រដល់ដំណើរការនៃការបណ្តុះបណ្តាលគ្រូបង្គោលជាទៀងទាត់ ក្រោមគំរូម៉ូដែលផ្សព្វផ្សាយ។ |
| | ៣.១.៣៖ ធ្វើការជាមួយរាជរដ្ឋាភិបាលនិងម្ចាស់ជំនួយ/កម្មវិធីជំនួយកសិកម្ម ដូចជា CHAIN, Harvest, CAVAC, ASPIRE, AIMS, ISA, S3, ASMC, ASSET, WAT4CAM។ល។ និងវិស័យឯកជនដើម្បីធ្វើសមាហរណកម្មកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ទៅក្នុងកម្មវិធីកសាងសមត្ថភាពដែលត្រូវផ្តល់ជូនដល់អ្នកផលិតគោលដៅ។ |
| ៣.២៖ ការយល់ដឹងពីអ្នកពាក់ព័ន្ធលើកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ត្រូវបានពង្រឹង | ៣.២.១៖ ផលិតវីដេអូផ្សព្វផ្សាយ/សម្ភារផ្សព្វផ្សាយ (រួមទាំងសក្ខីកម្មនិងឯកសារពីកសិករ) ហើយដាក់នៅលើប្រព័ន្ធផ្សព្វផ្សាយ គេហទំព័រវេបសាយ និងប្រព័ន្ធផ្សព្វផ្សាយសង្គមរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា អគ្គនាយកដ្ឋានកសិកម្ម និង/ឬក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកពាក់ព័ន្ធផ្សេងទៀត។ |

| | |
|---|---|
| | ៣.២.២៖ ធ្វើកិច្ចពិភាក្សាតុមូលស្តីពីកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី និងប្រធានបទទាក់ទង តាមទូរទស្សន៍ វិទ្យុ និងវេទិការផ្សព្វផ្សាយសង្គមផ្សេងៗ។ |
| | ៣.២.៣៖ រៀបចំពិព័រណ៌កសិកម្មជាប្រចាំ និងការចុះពិនិត្យផ្ទាល់ដល់អ្នកពាក់ព័ន្ធ ដើម្បីលើកកម្ពស់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី គ្រឿងយន្តកសិកម្ម រុក្ខជាតិជីវៈចម្រុះ និងផលិតផលចុងក្រោយ។ |
| | ៣.២.៤៖ គាំទ្រការអនុវត្តការធ្វើការបង្ហាញនៅទីវាលជាមួយសហករណ៍កសិកម្ម។ |
| ៣.៣៖ ការវិនិយោគពីតួអង្គឯកជនក្នុងការគាំទ្រនិងចូលរួមក្នុងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី | ៣.៣.១៖ ធ្វើការប្រជុំនិងរៀបចំទស្សនកិច្ចសិក្សាដោយមានការចូលរួមពីវិស័យឯកជនរួមទាំងអ្នកផ្គត់ផ្គង់ និងតួអង្គទីផ្សារ (អ្នកទិញ) និងសមាគមអាជីវកម្ម និងសមាគមអាជីវកម្មជំណាំជាក់លាក់ និងវេទិកាឯកជនដែលមានស្រាប់។ |
| | ៣.៣.២៖ គាំទ្រវិស័យឯកជន ដើម្បីកែលម្អលទ្ធភាពទទួលបានបច្ចេកវិទ្យា ដែលត្រូវនឹងគោលការណ៍កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី និងគាំទ្រការតភ្ជាប់រវាងស្ថាប័នហិរញ្ញវត្ថុ អ្នកផ្គត់ផ្គង់ និងកសិករ ដើម្បីទទួលបានហិរញ្ញវត្ថុនិងទំនាក់ទំនងទីផ្សារ។ |
| | ៣.៣.៣៖ គាំទ្រការសិក្សាអំពីយន្តការហិរញ្ញវត្ថុ ដើម្បីផ្តល់រង្វាន់ដល់កសិករនិងវិស័យឯកជន សម្រាប់ការចូលរួមរបស់ពួកគេនិងការទទួលយកកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី។ |

## ៧. តួនាទីនិងចំណាប់អារម្មណ៍របស់ភាគីពាក់ព័ន្ធក្នុងការអនុវត្តផែនទីតម្រង់ទិសរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា

### ៧.១ អ្នកពាក់ព័ន្ធផ្ទៃក្នុងរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** (MAFF) ដើរតួនាទីយ៉ាងសំខាន់នៅក្នុងរចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រងរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ដូច្នេះហើយធានាបាននូវបរិយាកាសអំណោយផលសម្រាប់ការអនុវត្តផែនទីតម្រង់ទិសរយៈពេល៥ឆ្នាំ ទាក់ទងនឹងធនធានមនុស្ស និងហិរញ្ញវត្ថុ។ ការប្តេជ្ញាចិត្តនេះត្រូវបានបង្ហាញយ៉ាងច្បាស់ក្នុងការគាំទ្រដល់ការគ្រប់គ្រងកំពូលកម្រិតខ្ពស់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលដឹកនាំដោយគណៈកម្ម

ការតម្រង់ទិសនិងគណៈកម្មការប្រតិបត្តិ របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព កម្ពុជាជាមួយតំណាងសមាជិកមកពីអគ្គនាយកដ្ឋានកសិកម្ម នាយកដ្ឋាន និងអង្គភាពដទៃទៀត នៃ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

**គណៈកម្មការតម្រង់ទិស នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា** ទទួលខុសត្រូវ ក្នុងការផ្តល់ទិសដៅនិងត្រួតពិនិត្យវឌ្ឍនៈភាពនៃការអនុវត្តផែនទីតម្រង់ទិស និងដើរតួនាទីឈាន មុខគេក្នុងការសម្របសម្រួលការសន្ទនាគោលនយោបាយនៅក្នុងរាជរដ្ឋាភិបាល និងការចូលរួម របស់ភាគីពាក់ព័ន្ធនៅគ្រប់វិស័យ។ សមាជិកនៃគណៈកម្មការតម្រង់ទិស ដែលមកពីស្ថាប័នផ្សេងៗ គ្នា (ក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន ក្រសួងក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងកិច្ចការនារី) និងវិស័យឯកជន (សភាពាណិជ្ជកម្មកម្ពុជា) គឺជាតួអង្គសំខាន់ ដែលផ្តល់នូវទស្សនវិស័យទូលំ ទូលាយនិងការប្តេជ្ញាចិត្តរបស់អន្តរក្រសួង ក្នុងការគាំទ្រកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងការអភិវឌ្ឍកសិកម្មអេកូឡូស៊ីនៅកម្ពុជា។

**គណៈកម្មការប្រតិបត្តិ នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា** ទទួលខុសត្រូវ ក្នុងការត្រួតពិនិត្យការអនុវត្តផែនទីតម្រង់ទិស ដោយការសម្របសម្រួល ការរួមបញ្ចូលគ្នា និងការ គាំទ្រដល់អនុគណៈកម្មការរបស់ខ្លួនក្នុងការអភិវឌ្ឍនិងការអនុវត្តផែនការសកម្មភាពរបស់ខ្លួន។ គណៈ កម្មការប្រតិបត្តិ ក៏ដើរតួយ៉ាងសំខាន់ក្នុងការសម្របសម្រួលនិងទំនាក់ទំនងរាល់សកម្មភាពទាក់ទង នឹងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី និងទំនាក់ទំនង/បណ្តាញជា មួយភាគីពាក់ព័ន្ធ។

**លេខាធិការដ្ឋាន**មួយ ត្រូវបានបង្កើតឡើង ដើម្បីគាំទ្រដល់ប្រតិបត្តិការរួមរបស់សម្ព័ន្ធកសិកម្មអភិ រក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជានិងការសម្របសម្រួលផ្ទៃក្នុងទូទៅ ជាមួយអនុគណៈកម្មការ ទាំងបួន។

**អនុគណៈកម្មការទាំងបួន នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា** កំពុងដំណើរ ការក្រោមគណៈកម្មការប្រតិបត្តិ និងមានការគាំទ្រពីលេខាធិការដ្ឋាន ជាអង្គភាពបច្ចេកទេសដឹកនាំ ការអនុវត្តសកម្មភាពអាទិភាពតាមគោលដៅយុទ្ធសាស្ត្រនីមួយៗ ដោយមានការគាំទ្រផ្នែកបច្ចេក ទេសនិងហិរញ្ញវត្ថុពីដៃគូសក្តានុពល ដូចមានបង្ហាញក្នុងតារាងឧបសម្ព័ន្ធ ម៉ាទ្រីសផែនទីតម្រង់ទិស របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា។

### ៧.២ អ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត

បន្ថែមពីលើសមាជិកនិងអ្នកពាក់ព័ន្ធជិតដិតរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព កម្ពុជា ក៏មានភាគីពាក់ព័ន្ធខាងក្រៅសំខាន់ៗដទៃទៀត ដែលបង្ហាញពីការចូលរួមនិងការរួមចំណែក

ដ៏មានសក្តានុពលចំពោះការអនុវត្តផែនទីតម្រង់ទិសរយៈពេល៥ឆ្នាំរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ហើយរួមមានបញ្ចូលដូចខាងក្រោម ប៉ុន្តែមិនកំណត់ចំពោះ៖

**អគ្គនាយកដ្ឋាន នាយកដ្ឋាន និងវេទិកាផ្សេងទៀតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- នាយកដ្ឋានដទៃទៀតនៃអគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមាន៖ នាយកដ្ឋានដំណាំស្រូវ នាយកដ្ឋានដំណាំឧស្សាហកម្ម នាយកដ្ឋានសាកវប្បកម្មនិងដំណាំបន្ទាប់បន្សំ នាយកដ្ឋានពូជដំណាំ និងនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម គឺជាភាគីពាក់ព័ន្ធសំខាន់ៗ ដែលគួរមានចំណាប់អារម្មណ៍និងសក្តានុពលក្នុងការពង្រីកវិសាលភាពប្រកបដោយភាពច្នៃប្រឌិតរបស់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងផលិតកម្ម ផ្អែកលើកសិកម្មអេកូឡូស៊ី ដែលបានកំណត់សម្រាប់ដំណាំជាក់លាក់។
- អង្គភាពសក្តានុពលផ្សេងទៀតរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដូចជាអគ្គនាយកកៅស៊ូ ដើម្បីពិនិត្យឡើងវិញនូវសារៈសំខាន់របស់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងការបន្សាំកសិកម្មអេកូឡូស៊ីនៅក្នុងចម្ការកៅស៊ូ នាយកដ្ឋានកសិ-ឧស្សាហកម្ម ដើម្បីចូលរួមជាមួយសម្បទានដីសេដ្ឋកិច្ច នាយកដ្ឋានផែនការនិងស្ថិតិ ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងក្នុងការគាំទ្រតស៊ូមតិគោលនយោបាយ ក៏ដូចជារដ្ឋបាលព្រៃឈើនិងអគ្គនាយកដ្ឋានសុខភាពនិងផលិតកម្មសត្វ។
- លេខាធិការដ្ឋាន នៃកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងការរេចរឹលដីធ្លី បង្ហាញពីកិច្ចសហការបំពេញបន្ថែមជាមួយសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា រួមជាមួយនឹងគោលដៅចុងក្រោយ នៃការអភិរក្សគុណភាពដីក្រោមអនុសញ្ញារបស់អង្គការសហប្រជាជាតិ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែក្លាយជាវាលរហោឋាន។
- ស្ថានីយ៍និងមជ្ឈមណ្ឌលស្រាវជ្រាវផ្សេងទៀត ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានកសិកម្ម មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង/ឬក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺជាដៃគូដ៏មានសក្តានុពលក្នុងការគាំទ្រដល់ការពង្រីកសកម្មភាពស្រាវជ្រាវនៅតាមទីកន្លែងនិងប្រព័ន្ធកសិកម្មអេកូឡូស៊ីខុសៗគ្នា ដូច្នេះហើយវាដើរតួជាអ្នកតំណាងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងជាមជ្ឈមណ្ឌលលើកកម្ពស់កសិកម្មអេកូឡូស៊ីសម្រាប់ដំណាំនៅក្នុងទីតាំងជាក់លាក់។

**បណ្តាស្ថាប័នពាក់ព័ន្ធ**

- មានតម្រូវការសម្រាប់ក្រសួងមួយចំនួន ដើម្បីចូលរួមដូចជាក្រសួងមហាផ្ទៃ ក្រសួងបរិស្ថាន និងក្រសួងធនធានទឹកនិងឧតុនិយម ដើម្បីចូលរួមក្នុងរចនាសម្ព័ន្ធរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ក្នុងគោលបំណងកំណត់ទិសដៅការត្រួតពិនិត្យនិងការផ្តល់អនុសាសន៍សម្រាប់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងការអភិវឌ្ឍកសិ

កម្មអេកូឡូស៊ី ដើម្បីលើកកម្ពស់ការសម្របសម្រួលអន្តរក្រសួងនិងការអនុវត្តកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងកសិកម្មអេកូឡូស៊ីនៅកម្ពុជា។

### ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព

- ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ជាពិសេសនាយកដ្ឋានជីវចម្រុះ និងនាយកដ្ឋានការប្រែប្រួលអាកាសធាតុ គឺជាចំណុចបង្គោលសម្រាប់អនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីជីវចម្រុះ (UN-CBD) និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC)។ ដូច្នេះ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ដើរតួយ៉ាងសំខាន់ក្នុងការសហការជាមួយសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា សម្រាប់គោលដៅរួមមួយក្នុងការធ្វើឱ្យប្រសើរឡើងនូវការអភិរក្សជីវៈចម្រុះនិងការបន្សាំនិងការប្រែប្រួលអាកាសធាតុតាមរយៈការលើកកម្ពស់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី។

### គ្រឹះស្ថានសិក្សានិងស្រាវជ្រាវ

- គ្រឹះស្ថានឧត្តមសិក្សាផ្តល់ជូនវគ្គសិក្សាលើមុខវិជ្ជាកសិកម្មនិងបរិស្ថាន ដូច្នេះវាដើរតួយ៉ាងសំខាន់ក្នុងការលើកកម្ពស់ចំណេះដឹងនិងការស្រាវជ្រាវទាក់ទងនឹងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ក្នុងចំណោមនិស្សិត អ្នកស្រាវជ្រាវវ័យក្មេង និងបញ្ញវន្ត និងការអភិវឌ្ឍន៍ធនធានមនុស្សបច្ចេកទេស ដែលរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតលើអនុវិស័យដែលទាក់ទងនឹងកសិកម្មអេកូឡូស៊ីនិងការប្រែប្រួលអាកាសធាតុ។
- ទាំងនេះរួមមានបណ្តាគ្រឹះស្ថានក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមមាន (វិទ្យាស្ថានជាតិកសិកម្មព្រែកលៀបនិងវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម) និងបណ្តាគ្រឹះស្ថានដែលស្ថិតនៅក្រោមក្រសួងអប់រំ យុវជន និងកីឡា (សាកលវិទ្យាល័យជាតិបាត់ដំបង វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ សាកលវិទ្យាល័យហេងសំរិនត្បូងឃ្មុំ និងសាកលវិទ្យាល័យស្វាយរៀង។ ល។ ) ។
- គ្រឹះស្ថានបណ្ឌិតសភា/វេទិការនិងអង្គភាពស្រាវជ្រាវសក្តានុពលផ្សេងទៀតរួមមាន សន្និសីទថ្នាក់ជាតិស្តីពីការអភិវឌ្ឍកសិកម្មនិងជនបទ (NCARD) សន្និសីទអន្តរជាតិ ស្តីអំពីបរិស្ថាននិងការអភិវឌ្ឍន៍ជនបទ (ICERD) និងវិទ្យាស្ថានស្តារនីតិសម្បទានិងអភិរក្សបរិស្ថាន នៃសាកលវិទ្យាល័យកសិកម្មនៃក្រុងតូក្យូ (ERECON)។
- គ្រឹះស្ថានសិក្សាអន្តរជាតិ ក៏ដើរតួយ៉ាងសំខាន់ក្នុងការគាំទ្រដល់ការស្រាវជ្រាវនិងចំណេះដឹងទាក់ទងនឹងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិអេកូឡូស៊ីនៅកម្ពុជា។ នេះអាចជាការគាំទ្រដល់សកម្មភាពស្រាវជ្រាវរួមគ្នា លើការកសាងសមត្ថភាព និងការពិនិត្យឡើងវិញនូវចំណេះដឹងវិទ្យាសាស្ត្រ។

## ដៃគូអភិវឌ្ឍន៍

- ដៃគូអភិវឌ្ឍន៍ ដែលសកម្មក្នុងការផ្តល់មូលនិធិដល់គម្រោងនិងកម្មវិធីនាពេលបច្ចុប្បន្ននិងអនាគត ដែលទាក់ទងនឹងនិរន្តរភាពកសិកម្មអាកាសធាតុឆ្លាតវៃនិងកសិកម្មអេកូឡូស៊ី តែងតែជាតួអង្គសំខាន់បំផុតក្នុងការគាំទ្រអាទិភាព ដែលមានចែងនៅក្នុងឯកសារផែនទីតម្រង់ទិសនេះ។ ផលប្រយោជន៍អាចផ្តោតលើការគាំទ្រថវិកាសម្រាប់ការស្រាវជ្រាវលើដំណោះស្រាយប្រកបដោយភាពច្នៃប្រឌិត ចំពោះបញ្ហាគុណភាពដី ផលិតភាពភាពធន់នឹងអាកាសធាតុ -ល- និង/ឬការពិចារណាអំពីការណែនាំអំពីកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព និងការអនុវត្តកសិកម្មអេកូឡូស៊ី នៅក្នុងកិច្ចអន្តរាគមន៍គម្រោងរបស់ពួកគេនិងជាមួយអ្នកទទួលផលគោលដៅរបស់ពួកគេ។

## វិស័យឯកជន

- តួអង្គក្នុងវិស័យឯកជនមានសារៈសំខាន់យ៉ាងខ្លាំងក្នុងការផ្លាស់ប្តូរកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងការអភិវឌ្ឍកសិកម្មអេកូឡូស៊ី លើសពីវិធីសាស្រ្ត ដែលផ្តល់មូលនិធិដោយម្ចាស់ជំនួយនិងផ្អែកលើគម្រោង។ ដូច្នេះ ការវិនិយោគឯកជនបង្ហាញពីសក្តានុពលធំ ជាពិសេសការផ្គត់ផ្គង់បច្ចេកវិទ្យាសមស្រប (ពូជដំណាំគម្របដី គ្រឿងយន្តកសិកម្ម និងអ្នកផ្គត់ផ្គង់ផលិតផលជីវៈ) និងហិរញ្ញវត្ថុ (ស្ថាប័នហិរញ្ញវត្ថុ) ក្នុងការជួយសម្រួលនិងពន្លឿនការផ្លាស់ប្តូររបស់កសិករ ឆ្ពោះទៅរកកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងប្រព័ន្ធផលិតកម្មផ្អែកលើកសិកម្មអេកូឡូស៊ី។
- តួអង្គក្នុងវិស័យឯកជន ក៏ដើរតួនៅក្នុងកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងការលើកកម្ពស់កសិកម្មអេកូឡូស៊ីជាមួយអ្នកផលិត ដៃគូរបស់ពួកគេ (ក្នុងករណីពាណិជ្ជករ) និងអតិថិជនគោលដៅ (ក្នុងករណីអ្នកផ្គត់ផ្គង់បញ្ចូលនិងស្ថាប័នហិរញ្ញវត្ថុ) តាមរយៈទីផ្សារ/ការយល់ដឹង ការកសាងសមត្ថភាព និងបច្ចេកទេស គាំទ្រសកម្មភាព បញ្ជ្រាបបច្ចេកទេសកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងគោលគំនិត និងគោលការណ៍កសិកម្មអេកូឡូស៊ីទៅក្នុងកម្មវិធីដែលមានស្រាប់របស់ពួកគេ។
- ម៉្យាងវិញទៀត ពាណិជ្ជករគាំទ្រដល់ការផ្សាភ្ជាប់ទីផ្សារសម្រាប់ផលិតផលកសិកម្មប្រកបដោយសុវត្ថិភាពជាមួយនឹងគុណភាពល្អប្រសើរ និងទិន្នផលខ្ពស់ដែលត្រូវផ្តល់ជូន (ក្រោមកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងផលិតកម្មផ្អែកលើកសិកម្មអេកូឡូស៊ី) ដល់អ្នកប្រើប្រាស់ចុងក្រោយ ដោយបំពេញតាមស្តង់ដារនិងតម្រូវការសុខភាពមនុស្សទាំងក្នុងស្រុកនិងទីផ្សារនាំចេញ។

## ភាគីពាក់ព័ន្ធក្នុងតំបន់និងវេទិកា

- អ្នកពាក់ព័ន្ធក្នុងតំបន់មួយចំនួននិងវេទិកានានា (ASEA, ALiSEA, UN-CSAM, ASSET។ គឺជាតួអង្គ ដ៏មានសក្តានុពលក្នុងការគាំទ្រការអភិវឌ្ឍសមត្ថភាពបច្ចេកទេសរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជានិងពង្រីកកិច្ចសហការណ៍ឱ្យកាន់តែច្រើន ក្នុងការស្រាវជ្រាវ សកម្មភាពបណ្តុះបណ្តាល យុទ្ធនាការលើកកម្ពស់ការយល់ដឹង និងកិច្ចខិតខំប្រឹងប្រែងតស៊ូមតិនៅថ្នាក់តំបន់។

## ៨. យន្តការយុទ្ធសាស្ត្រសម្រាប់ការអនុវត្តផែនទីតម្រង់ទិស

ដើម្បីធានាបាននូវប្រសិទ្ធភាពនិងនិរន្តរភាព នៃការអនុវត្តផែនទីតម្រង់ទិស ចាំបាច់ត្រូវបង្កើតបរិយាកាសអំណោយផលនិងពង្រឹងសមត្ថភាពធនធានមនុស្ស រូបវន្ត បច្ចេកវិទ្យា ស្ថាប័ន និងសមត្ថភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជានិងសមាជិករបស់ខ្លួន។ គួរតែមានការពិគ្រោះយោបល់និងកិច្ចព្រមព្រៀងក្នុងចំណោមក្រុមអ្នកពាក់ព័ន្ធទាំងអស់របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា សម្រាប់ក្របខ័ណ្ឌមួយ ដើម្បីគ្រប់គ្រងភាពជាដៃគូ កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងការរួបរួមគ្នារវាងដៃគូដោយមានការពិពណ៌នាយ៉ាងច្បាស់អំពីតួនាទី ការទទួលខុសត្រូវ និងការរំពឹងទុករបស់ពួកគេ។ រចនាសម្ព័ន្ធស្ថាប័ននិងធនធាន ដែលមានស្រាប់នឹងត្រូវបានអនុវត្តនិងពង្រឹង ហើយរចនាសម្ព័ន្ធថ្មីនិងប្រភពមូលនិធិនឹងត្រូវបានកំណត់និងបង្កើតតាមតម្រូវការសម្រាប់ការអនុវត្តផែនទីតម្រង់ទិស។

### ៨.១ លក្ខខណ្ឌអនុញ្ញាត

- ការផ្សារភ្ជាប់ជាមួយនឹងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលមានស្រាប់គួរតែត្រូវបានបញ្ជាក់ឱ្យបានច្បាស់ ដើម្បីបង្ហាញពីសារៈសំខាន់របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា និងការអនុវត្តន៍របស់វាជាមួយនឹងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការអភិវឌ្ឍវិស័យកសិកម្មប្រកបដោយនិរន្តរភាព ការធ្វើទំនើបកម្មកសិកម្មនិងការធ្វើពិពិធកម្មកសិកម្ម ការបន្សាំនិងកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការផ្លាស់ប្តូរកសិកម្មអេកូឡូស៊ី។ គោលបំណងយុទ្ធសាស្ត្រទី ៣ នៃផែនទីតម្រង់ទិសនេះ រួមមានសកម្មភាពដែលបង្កើនភាពមើលឃើញនិងពង្រឹងការធ្វើសមាហរណកម្មកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ក្នុងក្របខ័ណ្ឌគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលអាចជួយគាំទ្រនិងពង្រឹងការអនុវត្តឡើងវិញនូវអាទិភាពផ្សេងទៀតនៅក្នុងផែនទីតម្រង់ទិសនេះ ហើយរួមចំណែកដល់ការសម្រេចបាននូវចំណុចដៅរួម។
- នៅកម្រិតនៃអនុវត្ត ភាពជាម្ចាស់ស្ថាប័ននិងការប្តេជ្ញាចិត្តរបស់សមាជិកសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា គឺមានសារៈសំខាន់ខ្លាំងនៅក្នុងបរិបទនៃការផ្តល់អាទិភាព

ប្រកួតប្រជែងនិងភាពស្មុគស្មាញផ្នែកនយោបាយក្នុងកំឡុងពេល នៃការអនុវត្តផែនទីតម្រង់ទិស។ ដូច្នេះវាមានសារៈសំខាន់សម្រាប់សមាជិកក្នុងការដាក់បញ្ចូលអាទិភាព នៃផែនទីតម្រង់ទិសទៅក្នុងសកម្មភាពស្ថាប័ននិងផែនការថវិការបស់ពួកគេ។

- ធនធានមនុស្សគ្រប់គ្រាន់និងមានសមត្ថភាព គួរត្រូវបានធានានៅក្នុងលេខាធិការដ្ឋាន (នៅក្នុងដំណាក់កាលក្រោយៗ នៃការអភិវឌ្ឍន៍សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា) ដើម្បីគាំទ្រប្រកបដោយយុទ្ធសាស្ត្រ ដែលមានប្រសិទ្ធភាពដល់ប្រតិបត្តិការ នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា និងអនុគណៈកម្មការរបស់ខ្លួនក្នុងដំណើរការផែនទីតម្រង់ទិស។
- សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា គួរតែបង្កើតនិងពង្រឹងយន្តការច្បាស់លាស់ក្នុងការទំនាក់ទំនងនិងការគ្រប់គ្រង ដើម្បីទទួលបានលទ្ធផលដោយធ្វើឱ្យប្រសើរឡើងនូវបណ្តាញទំនាក់ទំនង ដែលមានស្រាប់នៅក្នុងនិងទូទាំងអនុគណៈកម្មការនិងជាមួយគណៈកម្មការប្រតិបត្តិ ព្រមទាំងការពិចារណាលើយុទ្ធសាស្ត្រទំនាក់ទំនងផ្សេងៗទៀត ជាពិសេសការឈានទៅដល់ដៃគូខាងក្រៅនិងភាគីពាក់ព័ន្ធ ។ នេះគួរតែរួមបញ្ចូលយន្តការរាយការណ៍ច្បាស់លាស់ ការពិនិត្យឡើងវិញតាមកាលកំណត់ និងការកែសម្រួល (សូមមើលផ្នែកការត្រួតពិនិត្យនិងវាយតម្លៃ) ។

## ៨.២ ការកៀរគរធនធាន

ផែនទីតម្រង់ទិសនេះ គឺជាឧបករណ៍សំខាន់មួយសម្រាប់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ដើម្បីទាក់ទាញនិងកៀរគរទាំងជំនួយបច្ចេកទេសនិងធនធានហិរញ្ញវត្ថុពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទីភ្នាក់ងាររដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលជាតិនិងអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងជាពិសេសការវិនិយោគវិស័យឯកជន ដើម្បីរួមចំណែកដល់ការអនុវត្តនូវអាទិភាពសំខាន់ៗ នៅក្នុងប៉ុន្មានឆ្នាំខាងមុខនេះ។ ដូច្នេះការកៀរគរធនធាន គឺជាផ្នែកមួយដ៏ចាំបាច់សម្រាប់ប្រតិបត្តិការផែនទីតម្រង់ទិស និងសម្រេចបាននូវចំណុចដៅសំខាន់ ដែលពាក់ព័ន្ធ។ ប្រភពហិរញ្ញប្បទានចម្រុះ ត្រូវបានណែនាំ។

- សកម្មភាពអាទិភាពសំខាន់ៗ គួរតែត្រូវបានដាក់បញ្ចូល/បញ្ជ្រាបទៅក្នុងផែនការយុទ្ធសាស្ត្រថវិកានិងកម្មវិធីថវិកាប្រចាំឆ្នាំរបស់ទីភ្នាក់ងារនិងអង្គភាពរដ្ឋាភិបាលនីមួយៗ (ជាពិសេសក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ដោយផ្តល់អាទិភាពដល់សកម្មភាពសំខាន់និងពាក់ព័ន្ធ (គិតពីកម្រិតថវិកាប្រចាំឆ្នាំរបស់រដ្ឋាភិបាល) ។ តាមរយៈការធ្វើដូច្នេះ សកម្មភាពអាទិភាពសំខាន់ៗមួយចំនួន ប្រសិនបើមិនទាំងអស់ អាចត្រូវបានផ្តល់មូលនិធិដោយថវិការដ្ឋាភិបាល។

- សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា គួរបន្តយន្តការបច្ចុប្បន្នក្នុងការសហការជាមួយវេទិកាជាតិនិងអន្តរជាតិ និងដៃគូអភិវឌ្ឍន៍លើគម្រោង/កម្មវិធីថ្មីៗ ដើម្បីគាំទ្រដល់អនុគណៈកម្មការ ក្នុងការអនុវត្តសកម្មភាពអាទិភាពសំខាន់ៗរបស់ពួកគេ។
- សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា គួរពង្រីកវិសាលភាពនៃការកៀរគរធនធានតាមរយៈការបង្កើនភាពមើលឃើញនិងការយល់ដឹងអំពីកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី នៅក្នុងវេទិកាផ្សេងៗរបស់រដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍រួមទាំងក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក កិច្ចសន្ទនាថ្នាក់ជាតិ ស្តីពីប្រព័ន្ធស្បៀងប្រកបដោយនិរន្តរភាព លេខាធិការដ្ឋាននៃកម្មវិធីសកម្មភាពជាតិដើម្បីប្រយុទ្ធប្រឆាំងនឹងការសឹករេចរឹលដី និងយន្តការផ្សេងទៀតដែលធ្វើការលើការការពារជីវចម្រុះ និងការកាត់បន្ថយនិងការសម្របខ្លួនទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ (ឧទាហរណ៍ ក្រសួងបរិស្ថាននិងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព) រួមទាំងមូលនិធិទំនួលខុសត្រូវសង្គមសាជីវកម្ម ការបង់ប្រាក់សម្រាប់សេវាប្រព័ន្ធអេកូឡូស៊ី គំនិតផ្តួចផ្តើម REDD+ មូលនិធិអភិវឌ្ឍន៍បៃតង។ល។
- កិច្ចខិតខំប្រឹងប្រែងគួរតែផ្តោតលើការទាក់ទាញការចាប់អារម្មណ៍ និងការវិនិយោគបន្ថែមទៀតពីវិស័យឯកជន តាមរយៈការបន្តការគាំទ្រក្នុងការដោះស្រាយបញ្ហាប្រឈមរបស់វិស័យឯកជនទាំងផ្នែកបច្ចេកទេសនិងធុរកិច្ច ព្រមទាំងការតភ្ជាប់ទំនាក់ទំនងរវាងអ្នកផ្គត់ផ្គង់ធាតុចូល ស្ថាប័នហិរញ្ញវត្ថុ កសិករ និងអ្នកទិញតាមខ្សែច្រវាក់តម្លៃផលិតកម្ម។
- ជាមួយនឹងយុទ្ធសាស្ត្រឧបត្ថម្ភសាជីវកម្ម (គួរបញ្ជាក់ថាជាសកម្មភាពអាទិភាពមួយនៅក្នុងផែនទីតម្រង់ទិស) សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា អាចប្រមូលមូលនិធិតាមរយៈកញ្ចប់យុទ្ធសាស្ត្រនៃការផ្តល់មូលនិធិផ្អែកលើព្រឹត្តិការណ៍ ជាពិសេសពីវិស័យឯកជន ដែលចង់លើកកម្ពស់គុណភាពនិងទីផ្សាររបស់ពួកគេជាមួយក្រុមទស្សនិកជនជាក់លាក់នៅក្នុងព្រឹត្តិការណ៍ រៀបចំដោយសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា។
- នៅដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍន៍របស់ខ្លួន សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា គួរតែសិក្សាពីលទ្ធភាព ដើម្បីពង្រឹងរចនាសម្ព័ន្ធសមាជិកភាពនិងអត្ថប្រយោជន៍ ដើម្បីកៀរគរមូលនិធិបន្ថែមគាំទ្រដល់ប្រតិបត្តិការរួមរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជានិងការអនុវត្តសកម្មភាព។

### ៨.៣ ការវាយតម្លៃហានិភ័យនិងការគ្រប់គ្រង

សម្រាប់ការអនុវត្តសកម្មភាពជាអាទិភាពនៅក្នុងផែនទីតម្រង់ទិសរយៈពេល៥ឆ្នាំ របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ហានិភ័យមួយចំនួននិងយុទ្ធសាស្ត្រកាត់បន្ថយដែលត្រូវគ្នាត្រូវបានវិភាគនិងបង្ហាញនៅក្នុងតារាងខាងក្រោម។ ហានិភ័យមួយក្នុងចំណោមហានិភ័យបន្ទាន់

បំផុតនៅក្នុងបរិបទបច្ចុប្បន្ននិងប្រហែលជាប៉ុន្មានឆ្នាំខាងមុខនេះ នៅក្នុងកាលវិភាគផែនទីតម្រង់ទិស គឺភាពមិនច្បាស់លាស់ដែលបណ្តាលមកពីការរីករាលដាលនៃជំងឺកូវីដ ១៩ ។ ដូច្នេះសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា តម្រូវឱ្យបង្ហាញសមត្ថភាពគ្រប់គ្រងការសម្របខ្លួននិងការត្រៀមខ្លួន ដើម្បីកែសម្រួលវិធីសាស្ត្រការងារនិងវិធីសាស្ត្រក្នុងការឆ្លើយតបទៅនឹងបរិបទណាមួយ ជាពិសេសក្នុងដំណាក់កាលដំបូងនៃការអនុវត្តផែនទីតម្រង់ទិស។ ហានិភ័យដ៏សំខាន់មួយទៀតត្រូវបានផ្សារភ្ជាប់ជាមួយនឹងអាទិភាព ការប្តេជ្ញាចិត្តនិងធនធានរបស់រាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការគាំទ្រស្ថាប័ននិងសកម្មភាពអាទិភាព ដែលមានចែងនៅក្នុងឯកសារផែនទីតម្រង់ទិសនេះ។

**តារាងទី ៧៖ ការសន្ទត់ហានិភ័យនិងយុទ្ធសាស្ត្រកាត់បន្ថយ**

| ការសន្ទត់ហានិភ័យ | យុទ្ធសាស្ត្រកាត់បន្ថយហានិភ័យ |
|---|---|
| ផលប៉ះពាល់ជាបន្តបន្ទាប់នៃជំងឺកូវីដ -១៩ ទៅលើការផ្តល់អាទិភាពធន ធានរបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន | • បន្តវាយតម្លៃស្ថានភាពនិងកែសម្រួលវិធីសាស្ត្រ ផែនការការងារ និងថវិកាតាមតម្រូវការ<br>• ធានាបាននូវកម្រិតខ្ពស់នៃភាពបត់បែន និងសមត្ថភាពគ្រប់គ្រងការសម្របខ្លួន |
| ការផ្លាស់ប្តូរនៅក្នុងរាជរដ្ឋាភិបាល ផែនការយុទ្ធសាស្ត្រតាមវិស័យ និងក្រសួង និងការផ្លាស់ប្តូរមុខងារ និងការទទួលខុសត្រូវរបស់ស្ថាប័ន | • បន្តកិច្ចខិតខំប្រឹងប្រែងតស៊ូមតិប្រកបដោយប្រសិទ្ធភាពសម្រាប់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងការធ្វើសមាហរណកម្មកសិកម្មអេកូឡូស៊ីទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការរបស់រាជរដ្ឋាភិបាល<br>• កំណត់គោលដៅជាក់ស្តែងនិងផ្តល់អាទិភាពដល់ការ វិនិយោគធនធានមនុស្សក្នុងតំបន់យុទ្ធសាស្ត្រ<br>• ពិភាក្សា និងឈានដល់ការឯកភាពគ្នាលើសកម្មភាពអាទិភាពក្នុងចំណោមសមាជិក |
| ផលប៉ះពាល់នៃជំងឺកូវីដ១៩ លើដំណើរការនៃការផ្សព្វផ្សាយពង្រីកយល់ដឹង ការកសាងសមត្ថភាព និងព្រឹត្តិការណ៍ពិភាក្សាសន្ទនាគោលនយោបាយ | • បន្តវាយតម្លៃស្ថានភាពនិងកែសម្រួលវិធីសាស្ត្រ និងផែនការការងារឡើងវិញក្នុងការអនុវត្តព្រឹត្តិការណ៍សំខាន់ៗក្នុងវេទិកាតាមរយៈពីចម្ងាយ (virtual platforms) និងយុទ្ធនាការ |
| ភាពងាយរងគ្រោះដែលបណ្តាលមកពីគ្រោះមហន្តរាយធម្មជាតិ ការប្រែប្រួលអាកាសធាតុ និងការរេច | • បន្តកិច្ចខិតខំប្រឹងប្រែង និងការបង្កើនល្បឿននៃការស្រាវជ្រាវនិងការពិសោធន៍លើប្រព័ន្ធដំណាំ និងគ្រាប់ពូជដែលធន់នឹងផលប៉ះពាល់អាកាសធាតុ |

| | |
|---|---|
| រឹលនៃជីវចម្រុះ ដែលអាចប៉ះពាល់ដល់លទ្ធផលនៃបច្ចេកទេសដាំដុះ ដែលត្រូវបានផ្ទេរទៅឱ្យកសិករ | |

## ៨.៤ ការរួមបញ្ចូលរបស់កសិករខ្នាតតូចនិងស្ត្រី

ការរួមបញ្ចូលគ្នា គឺជាទិដ្ឋភាពដ៏សំខាន់មួយដែលរួមចំណែកដល់ការសម្រេចបាននូវចក្ខុវិស័យ ដែលមានចែងនៅក្នុងឯកសារគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជានិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាពិសេសសេចក្តីព្រាងផែនការមេក្នុងវិស័យកសិកម្ម។ វិស័យកសិកម្មនៅកម្ពុជា គួរតែត្រូវបានអភិវឌ្ឍដោយសមធម៌ ដោយមានការចូលរួមពីគ្រប់តួអង្គខ្សែច្រវាក់តម្លៃទាំងអស់ រួមទាំងកសិករខ្នាតតូច ដែលមានដីស្រែតូច សមត្ថភាពហិរញ្ញវត្ថុមានកំណត់ និងបញ្ហាប្រឈមទាក់ទងនឹងលក្ខខណ្ឌក្នុងផលិតកម្ម ការប្រកួតប្រជែង និងប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់។ គម្លាតយេនឌ័រក្នុងវិស័យកសិកម្ម ជាពិសេសលទ្ធភាពទទួលបានសេវាកម្មគាំទ្រនិងផ្សព្វផ្សាយកសិកម្ម នៅតែជាបញ្ហាប្រឈម ដែលត្រូវយកចិត្តទុកដាក់ដោយសារកត្តាមួយចំនួនដែលប្រឈមមុខនឹងស្ត្រី រួមទាំងទីតាំងឆ្ងាយនៃសេវាកម្មផ្សព្វផ្សាយ អក្ខរកម្មមានកំណត់ ខ្វះពេលវេលា ខ្វះសេវាថែទាំកុមារ។ បន្ទុកការងារគ្រួសារ អសមត្ថភាពក្នុងការធ្វើដំណើរឆ្ងាយពីផ្ទះ និងកត្តាវប្បធម៌សង្គមផ្សេងទៀត។ លើសពីនេះ អត្រាប្រើប្រាស់ឧបករណ៍/សម្ភារ និងបច្ចេកវិទ្យារបស់ស្ត្រីនៅតែទាបជាងបុរស។

ដោយយកបញ្ហាទាំងនេះរបស់កសិករខ្នាតតូចនិងស្ត្រី ផែនទីតម្រង់ទិសនេះ ផ្តោតលើបញ្ហារួមបញ្ចូលគ្នាលើការគាំទ្រលើលទ្ធភាពទទួលបានការសម្របសម្រួលបច្ចេកទេស តាមការចំណាយសមស្របទៅតាមសមត្ថភាពបច្ចេកទេសនិងហិរញ្ញវត្ថុរបស់កសិករខ្នាតតូចនិងស្ត្រី។ អនុគណៈកម្មការស្រាវជ្រាវ នៃសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា គួរតែផ្តោតការសិក្សាស្រាវជ្រាវរបស់ខ្លួនទៅលើកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ទាក់ទងនឹងបច្ចេកវិទ្យានិងបច្ចេកទេស ដែលងាយស្រួលយល់និងសម្របសម្រួលតាមបច្ចេកទេសនិងហិរញ្ញវត្ថុ។ ដើម្បីសម្រេចបាននូវប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុងការពង្រីកនិងការផ្សារភ្ជាប់ ក្នុងការផ្សព្វផ្សាយនិងទីផ្សារ (ការចូលរួមពីវិស័យឯកជន សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ផ្តោតលើការសម្របសម្រួលរបស់ខ្លួនជាមួយភាគីពាក់ព័ន្ធ ដែលធ្វើការជាមួយក្រុមអ្នកផលិត/បណ្តាញការងារ និងសហករណ៍កសិកម្ម ដែលជាមូលដ្ឋានសម្រាប់ផលិតកម្ម (ការទទួលបានកាន់តែប្រសើរឡើងចំពោះធាតុចូលកសិកម្មនិងសេវាកម្មគាំទ្រកសិកម្ម) និងការប្រមូលនិងផ្គត់ផ្គង់ខ្នាតធំទៅកាន់ទីផ្សារ ដើម្បីធានាបាននូវប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ជាង។

កម្មសិទ្ធិដីធ្លីនិងការគ្រប់គ្រងនិងការសម្រេចចិត្តទាក់ទងនឹងវិស័យកសិកម្ម ជាទូទៅត្រូវបានចូលរួមរួមគ្នាដោយបុរសនិងស្ត្រី មិនថាតិចឬច្រើន។ ការអនុវត្តកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាព

និងកសិកម្មអេកូឡូស៊ី រួមចំណែកដល់ការកាត់បន្ថយពេលវេលានិងការប្រើប្រាស់កម្លាំងពលកម្ម ព្រមទាំងការគ្រប់គ្រងដីធ្លីបានល្អប្រសើរនិងប្រកបដោយនិរន្តរភាពទាំងបុរសនិងស្ត្រី។ ដោយសារតែការពិត ដែលថាស្ត្រីដើរតួយ៉ាងសំខាន់ក្នុងការសម្រេចចិត្តរបស់គ្រួសារក្នុងការទទួលយកបច្ចេកទេសកសិកម្ម ជាពិសេសការសម្រេចចិត្តទាក់ទងនឹងការចំណាយ ស្ត្រីត្រូវការព័ត៌មានអំពីអត្ថប្រយោជន៍ហិរញ្ញវត្ថុរបស់កសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី។ ជាលទ្ធផល មុខងារការលើកកម្ពស់របស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា គួរតែធានាបាននូវព័ត៌មានគ្រប់គ្រាន់ ដែលផ្តល់ជូនដល់បុរសនិងស្ត្រីសម្រាប់ការវិភាគសេដ្ឋកិច្ច។

## ៩.ការត្រួតពិនិត្យនិងការវាយតម្លៃ

ផ្នែកត្រួតពិនិត្យនិងវាយតម្លៃ គឺជាផ្នែកសំខាន់មួយនៃឯកសារផែនទីតម្រង់ទិសនេះ។ លទ្ធផលរំពឹងទុកនិងចំណុចសំខាន់ៗ ដែលបានកំណត់នៅក្នុងផែនទីតម្រង់ទិសត្រូវបានប្រើ ដើម្បីរាយការណ៍អំពីវឌ្ឍនភាព នៃការអនុវត្តសកម្មភាពនិងតាមដានស្ថានភាពកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងការអភិវឌ្ឍកសិកម្មអេកូឡូស៊ីនៅកម្ពុជា។ ផែនទីតម្រង់ទិសនេះ នឹងត្រូវត្រួតពិនិត្យដោយគណៈកម្មការតម្រង់ទិសរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា (ដោយមានការអនុម័តជាចុងក្រោយដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) ហើយអនុវត្តដោយគណៈកម្មការប្រតិបត្តិរបស់សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា ជាពិសេសគឺអនុគណៈកម្មការនានា។ ការធ្វើរបាយការណ៍នឹងត្រូវធ្វើឡើងជាប្រចាំ ផ្អែកលើលទ្ធផលជាក់ស្តែងដោយប្រៀបធៀបទៅនឹងចំណុចគោលដែលបានកំណត់។

គួរកត់សំគាល់ថា ផែនទីតម្រង់ទិសនេះមានសកម្មភាពជាច្រើន ដែលនឹងត្រូវអនុវត្តនិងសហការជាមួយបណ្តានាយកដ្ឋាន ទីភ្នាក់ងារ និងអ្នកពាក់ព័ន្ធផ្សេងៗ ក្រោមគម្រោងនិងកម្មវិធីផ្សេងៗគ្នា។ ហេតុដូចនេះ តម្រូវឱ្យមានយន្តការសម្របសម្រួលដ៏រឹងមាំមួយ ប្រព័ន្ធទិន្នន័យឬប្រព័ន្ធព័ត៌មានត្រឹមត្រូវ និងការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធយ៉ាងទូលំទូលាយ។ ដូចនេះ គណៈកម្មការប្រតិបត្តិកំពុងដឹកនាំដំណើរការរៀបចំផែនការ ធ្វើរបាយការណ៍ ត្រួតពិនិត្យនិងការវាយតម្លៃ ដោយផ្អែកលើចំណុចគោលនានា ដែលបានកំណត់នៅក្នុងផែនទីតម្រង់ទិស ដោយមានការត្រួតពិនិត្យនិងកែសម្រួលតាមកាលកំណត់។ ការត្រួតពិនិត្យនិងការវាយតម្លៃ នឹងជូនដំណឹងដល់ក្រុមប្រតិបត្តិនិងអ្នកធ្វើសេចក្តីសម្រេចចិត្តជាមួយព័ត៌មានសំខាន់ៗទាក់ទងនឹងវឌ្ឍនភាព នៃគោលដៅដែលសម្រេចបាននិងមិនទាន់សម្រេចបាន ការប្រឈមឬរបាំង ឱកាសនិងមេរៀនបទពិសោធន៍ ដែលបានសិក្សាសម្រាប់ការអនុវត្តបន្តនិងការកែសម្រួលសកម្មភាពនៅក្នុងផែនទីតម្រង់ទិស ដែលនៅសេសសល់ រយៈពេលកំណត់ទាំងកម្រិតស្ថាប័ននិងអន្តរាគមន៍ ដែលមានភាពពាក់ព័ន្ធដោយផ្ទាល់ចំពោះអ្នកទទួលផល។ របាយការណ៍ទៀងទាត់និងក្របខ័ណ្ឌត្រួតពិនិត្យនិងវាយតម្លៃ ត្រូវបានស្នើឡើងនិងឯកភាពក្នុងដំណើរការអភិវឌ្ឍផែនទីតម្រង់ទិស ដែលរួមមាន៖

- ការធ្វើបច្ចុប្បន្នភាពឥតឈប់ឈរនៃប្រព័ន្ធទិន្នន័យកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពនិងកសិកម្មអេកូឡូស៊ី ឬកសិអេកូឡូហ្ស៊ីនិងប្រព័ន្ធព័ត៌មានវិទ្យា
- កិច្ចប្រជុំប្រចាំខែរបស់គណៈកម្មការប្រតិបត្តិ ជាមួយរបាយការណ៍សកម្មភាពប្រចាំខែនិងផែនការសម្រាប់ខែបន្ទាប់
- កិច្ចប្រជុំពាក់កណ្តាលឆ្នាំរបស់គណៈកម្មការតម្រង់ទិស ដែលមានរបាយការណ៍រយៈពេលប្រាំមួយខែនិងផែនការសម្រាប់រយៈពេល ៦ ខែបន្ទាប់
- របាយការណ៍លទ្ធផលប្រចាំឆ្នាំនិងផែនការប្រតិបត្តិការសម្រាប់ឆ្នាំបន្ទាប់
- ការពិនិត្យឡើងវិញពាក់កណ្តាលអាណត្តិ នៃផែនទីតម្រង់ទិស (នៅចុងឆ្នាំទី៣)
- ការវាយតម្លៃរយៈពេល៥ ឆ្នាំលើលទ្ធផលនិងផលប៉ះពាល់។

# ឯកសារយោង

Altieri, M.A. 2002. agroecology: the science of natural resource management for poor farmers in marginal environments. Agriculture, Ecosystems and Environment, 93: 1-24.

CASC/DALRM. 2021 [draft]. Brief note of CASC Achievements in 2020.

Castella J.C., & Kibler J.F. 2015. *Towards an agroecological transition in Southeast Asia: Cultivating diversity and developing synergies.* GRET, Vientiane, Lao PDR. 96 p.

Food and Agriculture Organization (FAO). 2017. *The future of food and agriculture: Trends and challenges.* Rome.

- - -. 2018. Catalyzing dialogue and cooperation to scale up Agroecology: outcomes of the FAO regional seminars on Agroecology. ISBN 978-92-5-130464-8.

Garcia, J., Chey, T. 2019. *Mid-term review of Cambodia Climate Change Strategic Plan (2014-2023).* Evaluation report for General Secretariat of National Council for Sustainable Development (NCSD).

Hok, L., Sá, J.C.M., Reyes, M., Boulakia, S., Tivet, F., Leng, V., Kong, R., Briedis, C., Hartman, D.D.C., Ferreira, L.A., Inagaki, T.M., Gonçalves, D.R.P., Bressan, P.T., 2018. Enzymes and C pools as indicators of C build up in short-term conservation agriculture in a savanna ecosystem in Cambodia. Soil & Tillage Research 177: 125-133.

Hok, L., Sá J.C.M., Boulakia S., Reyes M., Leng V., Kong R., Tivet F., Briedis C., Hartman D.D., Ferreira L.A., Magno T., Pheav S., 2015. Short-term conservation agriculture and biomass-C input impacts on soil C dynamics in a savanna ecosystem in Cambodia. Agriculture, Ecosystems and Environment 214: 54-67.

Jones, M., Leng, V., Ong, S., Mean, M., 2019. Gender technology assessment - Appropriate Scale Mechanization Consortium. Cambodia: Service provision for Conservation Agriculture. Feed the Future, Sustainable Intensification Innovation Lab. Kansas State University, Royal University of Agriculture of Cambodia, 16 p.

Kassam, A., Friedrich, T., Derpsch, R., 2019. Global spread of Conservation Agriculture, International Journal of Environmental Studies, 76:1, 29-51, DOI:10.1080/00207233.2018.1494927.

Kong, R., Canto G.B., Castella, J.C., Tivet, F., Seng, V. 2020 [draft]. *Evaluation of 10-year impacts of action-research promoting conservation agriculture in Cambodia.* Phase 1: preparation of the case study.

Kong, R., Castella, J.C., Suos, V., Leng, V., Pat, S., Diepart, J.C., Sen, R., Tivet, F., 2021. Investigating farmers' decision-making in adoption of conservation agriculture in the Northwestern uplands of Cambodia. Land Use Policy 105 (2021) 105404.

Kong, R., Castella, J.C., 2021. Farmers' resource endowment and risk management affect agricultural practices and innovation capacity in the Northwestern uplands of Cambodia. Agricultural Systems 190 (2021) 103067.

Kong, R., Diepart, J.C., Castella, J.C., Lestrelin, G., Tivet, F., Belmain, E., Bégué, A. 2019. Understanding the drivers of deforestation and agricultural transformations in the Northwestern uplands of Cambodia. Applied Geography, 102: p. 84-98. https://doi.org/10.1016/j.apgeog.2018.12.006.

Kong, R., Sar V., Leng V., Trang S., Boulakia S., Tivet F., Séguy L. 2016. Conservation agriculture for climate-resilient rainfed uplands in the Western regions of Cambodia: challenges, opportunities, and lessons from a 10-Year R and D program. In : Sajise Percy E. (ed.), Cadiz Maria Celeste H. (ed.),

Bantayan Rosario B. (ed.). Learning and coping with change: Case stories of climate change adaptation in Southeast Asia. Los Baños : SEARCA, p. 55-81.

Leng, V., Tanaka, H., Sugihara, S., Boulakia, S., Oikawa, Y., Kimura, S.D.B., Letourmy, P., Kong, R., Fujii, Y., Hok, L., Pheap, S., Seng, V., Tivet, F., forthcoming. Effect of Short-term Conservation Agriculture on Soil Organic C and N stocks, and Nutrient contents in Lowland Rice Agroecosystem in Cambodia.

MAFF. 2015. *Gender Mainstreaming Policy and Strategic Framework in Agriculture (2016-2020).*

- - -. 2016. *Climate Change Priorities Action Plan for Agriculture, Forestry and Fisheries Sector (2016-2020)*. Technical Working Group for Policy and Strategy to Respond to Climate Change of MAFF (TWG-CCAFF), March 2016.

- - -. 2018. *National Action Program (NAP) to Combat Land Degradation (2018-2027).*

- - -. 2019. *Agriculture Strategic Development Plan (2019-2023).*

- - -. 2020 [draft]. *Agriculture Sector Master Plan 2030: Modernization of Cambodia's Agriculture with Competitiveness, Inclusiveness, Resilience to Climate Change, and Sustainability.*

National Climate Change Committee. 2013. *Cambodia Climate Change Strategic Plan (2014-2023).*

National Council for Sustainable Development (NCSD) / Ministry of Environment (MoE). 2016. *National Biodiversity Strategy and Action Plan.* Department of Biodiversity, General Secretariat of NCSD, February 2016.

- - -. 2020. *First Biennial Update Report (BUR) of the Kingdom of Cambodia to the United Nations Framework Convention on Climate Change.*

- - -. 2020. *Cambodia's Updated Nationally Determined Contribution*.

National Council on Green Growth / Ministry of Environment (MoE). 2013. *National Policy on Green Growth.*

- - -. 2013. *National Strategic Plan on Green Growth (2013-2030).*

Pheap, S., Lefèvre, C., Thoumazeau, A., Leng, V., Boulakia, S., Koy, R., Hok, L., Lienhard, P., Brauman, A., Tivet, F., 2019. Multi-functional assessment of soil health under Conservation Agriculture in Cambodia. Soil & Tillage Research, 194, 104349.

Pretty, J., 2018. Intensification for redesigned and sustainable agricultural systems. Science 362, 908.

RGC. 2018. *Rectangular Strategy for Growth, Employment, Equity, and Efficiency: Building the Foundation towards Realizing the Cambodia Vision 2050 (Phase IV).* The Royal Government of Cambodia of the Sixth Legislature of the National Assembly, September 2018.

- - -. 2018. *Cambodian Sustainable Development Goals (CSDGs) Framework (2016-2030).* Council of Ministers, November 2018.

- - -. 2019. *National Strategic Development Plan (NSDP) (2019-2023): For Growth, Employment, Equity and Efficiency to Reach the Status of an Upper-middle Income Country by 2020.* Promulgated under Royal Kram 0719/011, July 2019.

Séguy, L., S. Bouzinac, et al. 2006. Direct-seeded tropical soil systems with permanent soil cover: Learning from Brazilian experience. Biological approach to sustainable soil systems. N. Uphoff, A. S. Ball, E. Fernandeset al, CRC Press, Taylor & Francis: 323-342.

Sumner, D., Christie, M.E., Boulakia, S., 2017. Conservation agriculture and gendered livelihoods in Northwestern Cambodia: decision-making, space and access. Agric Hum Values (2017) 34:347–362, DOI 10.1007/s10460-016-9718-z.

Vernet, P.A., Faysse, N., Suos, V., Oung, N., Son, S., Leng, V., Theng, D., Rendall, T., Lor, L., Reyes, R., Chan, S., Pradhan, R., Vang, S., Tivet, F., 2020. Investing in a no-till planter in Cambodia: A promising opportunity for various types of service providers? Asian Journal of Agricultural and Environmental Safety, forth-coming.

World Resource Institute (WRI). 2018. *Creating a sustainable food future: A menu of solutions to feed nearly 10 billion people by 2050. Synthesis Report.*

**ឧបសម្ព័ន្ធទី១**: សេចក្តីសម្រេចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីការបង្កើតគណៈកម្មការតម្រង់ទិសនិងគណៈកម្មការប្រតិបត្តិសម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ២០១ សសរ.កសក

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការតម្រង់ទិស និងគណៈកម្មការប្រតិបត្តិ**
**សម្ព័ន្ធកសិកម្មអភិរក្សនិងប្រពលវប្បកម្មនិរន្តរភាពកម្ពុជា**

**រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារ ភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រ និងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្មនិងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ. បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- យោងលិខិតលេខ២១៧៨ សជណ ចុះថ្ងៃព្រហស្បតិ៍ ១៤រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ



Scanned with CamScanner

[illegible]

- យោងលិខិតលេខ១១២៣ សជណ.ប.ស្ក ចុះថ្ងៃពុធ ៦កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងបរិស្ថាន
- យោងលិខិតលេខ១៧២៥ កកន/បល ចុះថ្ងៃពុធ ១២រោច ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៩ របស់ក្រសួងកិច្ចការនារី
